ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តព្រៃវែង

# អបអរសាទរទិវាជាតិអំណានលើកទី៦

## ១១ មីនា ២០២១

## ប្រធានបទ

# "តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ"



ឈ្មោះ **វ៉ឹក សាវន់**  ភេទ ប្រុស

ថ្ងៃខែឆ្នាំកំណើត៖ ០៩ កក្កដា ១៩៨១

តួនាទី៖ គ្រូឧទ្ទេស បម្រើការងារនៅ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង

ទំនាក់ទំនង៖ **០១៦ ២១០ ០០០**

Email: vek.savorn.rttc@moeys.gov.kh

# មាតិកា


**បញ្ជីខ្លឹមសារ** **ទំព័រ**

សេចក្តីផ្តើម ............................................................ ១

**១- តម្លៃលើផ្នែកអត្ថន័យ** ............................................................ ១

ក-តម្លៃឆ្លុះបញ្ចាំងពីវប្បធម៌-អរិយធម៌ និងអត្តសញ្ញាណជាតិ ............................................................ ២

ខ-តម្លៃឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រសង្គ្រាម ............................................................ ៦

គ-តម្លៃឆ្លុះបញ្ចាំងពីយុទ្ធវិធីគ្រប់គ្រងប្រទេស ............................................................ ១៣

**២- តម្លៃលើផ្នែកអត្ថរូប** ............................................................ ៣៣

ក- តម្លៃតំណែងនិពន្ធ ............................................................ ៣៣

ខ. តម្លៃសិល្ប៍រូបារម្មណ៍វិធី ............................................................ ៤១

គ.តម្លៃរឿងរាមកេរ្តិ៍ជាគំរូនៃការតែងនិពន្ធ ............................................................ ៤៥

**៣.តម្លៃលើផ្នែកអត្ថរស** ............................................................ ៤៨

ក.តម្លៃនៃបច្ចេករស ............................................................ ៤៨

ខ.តម្លៃនៃវិសេសរស ............................................................ ៥០

គ.តម្លៃសាមញ្ញរស ............................................................ ៥៤

ឃ.តម្លៃនៃសព្វរស ............................................................ ៥៤

**សន្និដ្ឋាន** ............................................................ ៥៨

**ឯកសារពិគ្រោះ** ............................................................ ៥៩

## សេចក្ដីផ្ដើម

រឿងរាមកេរ្តិ៍ គឺជារតនសម្បត្តិដ៏មានតម្លៃរបស់ប្រជាជនខ្មែរដែលបង្ហាញពីសកម្មភាព (ទាំងការស្រឡាញ់ ទាំងការឈឺចាប់) ពីលក្ខណៈតួអង្គ ពីទស្សនៈ ពីឆន្ទៈរបស់ខ្មែរ និងជាប្រភពនៃអក្សរសិល្ប៍ខ្មែរ។ រឿងរាមកេរ្តិ៍ត្រូវជនជាតិខ្មែរយើងនិយមចូលចិត្តតាំងពីសម័យបុរាណ ព្រោះយើងឃើញមានការយកដំណើររឿងរាមកេរ្តិ៍មកដាប់ឆ្លាក់នៅតាមជញ្ជាំងប្រាសាទ មកចារលើសាស្ត្រាស្លឹករឹត មកគូរជាគំនូរនៅតាមជញ្ជាំងព្រះវិហារមួយចំនួន ក៏ដូចជាការយកមកចងក្រងជាឯកសារ គម្ពីរ ក្បួនខ្នាត ដើម្បីមើលព្រេងវាសនានៅតាមវត្តអារាមជាដើម ដែលទាំងនេះជាសក្ខីកម្មនៃភាពល្បីល្បាញរបស់រឿងរាមកេរ្តិ៍។

តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍មានទាំងតម្លៃអត្ថន័យ តម្លៃអត្ថរូប និងតម្លៃអត្ថរសចំពោះសង្គមជាតិកម្ពុជា ពោលគឺជាច្រើនជំនាន់មកហើយដែលរឿងរាមកេរ្តិ៍ត្រូវបានខ្មែរជំនាន់ដើមនិទានតគ្នាពីមាត់មួយទៅមាត់មួយ ហើយស្ថិតនៅក្នុងក្រអៅបេះដូងរបស់ខ្មែរគ្រប់ៗគ្នាដោយផ្ទុកនូវចំណុចពិសេសជាច្រើនក្នុងវប្បធម៌ខ្មែរ ដែលបង្ហាញឱ្យឃើញនូវសារប្រយោជន៍ដែលគេអាច ទាញបានពីរឿងរាមកេរ្តិ៍។ ដោយសារតែរឿងរាមកេរ្តិ៍មានតម្លៃដ៏មហាសាលដូច្នេះហើយ ទើបយើងឃើញរឿងរាមកេរ្តិ៍ មាននៅស្ទើតែគ្រប់រូបភាពក្នុងសង្គមវប្បធម៌ខ្មែរ និងជាពិសេសគឺផ្នែកអត្ថន័យមានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងជីវភាពរស់នៅ ក៏ដូចជានៅក្នុងការអនុវត្តការដឹកនាំគ្រប់គ្រងសង្គមជាតិ ហើយក្នុងផ្នែកអត្ថរូបមានតម្លៃសម្រាប់អ្នកសិក្សាជំនាន់ក្រោយៗយកគំរូតាមក្នុងការតាក់តែងនិពន្ធស្នាដៃរបស់ខ្លួន ដែលអ្នកស្រាវជ្រាវនឹងធ្វើការសិក្សាស្រាវជ្រាវបង្ហាញជាលម្អិតនៅផ្នែកខាងក្រោមនេះ។

### ១- តម្លៃលើផ្នែកអត្ថន័យ

តាមរយៈផ្ទៃរឿងទាំងមូល អ្នកនិពន្ធបានបង្ហាញឱ្យយើងឃើញពីអត្ថន័យដែលជាការពន្យល់សេចក្តីនៃដំណើររឿង ឬការរៀបរាប់ពីលក្ខណៈ សកម្មភាពរបស់តួអង្គនៃរឿងដែលក្នុងនោះមានដូចជា សកម្មភាពរបស់តួអង្គព្រះរាម ដែលជាអវតារទី៧នៃព្រះវិស្ណុ ដោយបែងចែកដំណើរជីវិតរបស់ព្រះរាមជាបី ដំណាក់កាលគឺ៖

- យុវភាព ការសិក្សា ការរៀបចំគូស្រករ និងការនិរទេសខ្លួនរបស់ព្រះរាមដើម្បីដោះស្រាយវិបត្តិទំនាស់ដែលកើតមាននៅក្នុងវង្សត្រកូល និងដើម្បីប្រជារាស្ត្ររស់ក្នុងភាពស្ងប់សុខមានសន្តិភាព និងភាពសុខដុមរម្យនា។

- ព្រះរាមប្រឈមមុខនឹងសត្រូវរបួតទទួលបានជ័យជម្នះ។

-បរាជ័យភាពក្នុងការកសាងគ្រួសារសាជាថ្មីរបស់ព្រះរាម ដែលត្រូវព្រាត់ភរិយាជាទីស្រឡាញ់អស់មួយជីវិតដោយសារតែការមិនព្រមស្តាប់ហេតុផល។

ផ្អែកទៅលើដំណើរជីវិតទាំងបីដំណាក់កាលរបស់ព្រះរាម អ្នកនិពន្ធបានបង្ហាញឱ្យយើងឃើញពីអត្ថន័យមួយចំនួនដូចតទៅ៖

### ក-តម្លៃឆ្លុះបញ្ចាំងពីវប្បធម៌-អរិយធម៌ និងអត្តសញ្ញាណជាតិ

ថ្វីត្បិតតែរឿងរាមកេរ្តិ៍មានប្រភពពីរឿងរាមាយណៈរបស់ឥណ្ឌា តែខ្មែរបានធ្វើនិយកម្មរឿងនេះឱ្យមានលក្ខណៈជាតិខ្មែរ។ ដូច្នេះ ដំណើររឿងបានឆ្លុះបញ្ចាំងយ៉ាងច្រើនដែលបញ្ជាក់ពីតម្លៃវប្បធម៌-អរិយធម៌ និងអត្តសញ្ញាណជាតិខ្មែរដែលមានដូចជា៖

- **ព្រះរាជពិធីច្រត់ព្រះនង្គ័ល**

ជាទិដ្ឋភាពរួមនៃវប្បធម៌ និងអត្តសញ្ញាណជាតិខ្មែរដែលនិយមប្រារព្ធឡើងនៅរៀងរាល់ ដើមឆ្នាំនៃរដូវវស្សាក្នុងអត្ថន័យច្រើនយ៉ាងដូចជា៖

- ជាពេលនៃការចាប់ផ្តើមបើកនៃរដូវកាលកសិកម្ម ៖ បានន័យថា រដូវកាលកសិកម្មមកដល់ហើយ ដូច្នេះត្រូវចាប់ផ្តើមត្រៀមសម្ភារផ្សេងៗ ដើម្បីត្រៀមធ្វើស្រែចម្ការដូចជា នង្គ័ល រនាស់...ផ្គត់ផ្គង់ជីវភាព។ល។
- ការបញ្ជាក់ពីអត្ថន័យនៃជំនឿ លើការបួងសួងបន់ស្រន់ពីម្ចាស់ទឹកម្ចាស់ដីដើម្បីសុំទឹកភ្លៀងឱ្យបានគ្រប់គ្រាន់សម្រាប់បង្កបង្កើនផល។
- ការព្យាករណ៍ពីផលដំណាំប្រចាំឆ្នាំថ្មី (ចង្រៃអុតត្បាត និងប្រភេទដំណាំដែលអនុគ្រោះ)
- បង្ហាញពីប្រពៃណីនៃរបៀបធ្វើស្រែចម្ការរបស់ប្រជាជនខ្មែរ(ភ្ជួររាស់...)

ខ្លឹមសារនេះដូចមានបង្ហាញតាមរយៈដំណើររឿងរបស់អ្នកអង្គម្ចាស់ **វឌ្ឍឆាយាវង្ស** ខ្សែទី១ ទំព័រ៥-៦ បានបញ្ជាក់ថា៖

*“ដងនោះព្រះបាទមិថិលា ស្តេចធ្វើចរិយា បីដោយនូវក្រឹត្យដ៏ពិធី។*
*លុះពិសាខសុភតិត្ថិ ផ្ទុំមុខមន្ត្រី ប្រយោជន៍នូវប្រែពសុធា។*
*ដើម្បីនូវធ្វើឱ្យក្សេមប្រជា រាស្ត្ររដ្ឋដោយនា ក្រិតាធិការដ៏បុរាណ។*
*ស្តេចទ្រង់នង្គ័លហសមាន ព្រះឧសភរាជប៉ុរូហាន ដំណើរសីហានាទលេលា។*
*................................... ........................... .............................*
*ដងនោះឥសូរមិថិលា រៀបរាជយោធា នូវថ្វាត់នឹងថ្កានព្រះនគរ។*
*នៅរាជកញ្ញាសុបវរ ស្មើបុត្រដ៏ឧទរ ក៏លុះលើរាជពិភព ។”*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្សែទី១ ទំព័រ៥-៦)

- **ការជ្រើសរើសគូស្រករឱ្យកូនដោយមើលពីសមត្ថភាពកូនប្រុស**

ក្នុងផ្នត់គំនិតខ្មែរ ឪពុកម្តាយខ្មែរមុននឹងទុកដាក់កូនចៅឱ្យមានគូស្រករ ពិសេសគឺឪពុក

ម្តាយខាងកូនស្រីតែម្តង ឪពុកម្តាយខ្មែរតែងសម្លឹងពិនិត្យមើលពីសមត្ថភាពកូនប្រុស ដើម្បីជាការគិតគូរដល់សេចសុខសុភមង្គលរបស់កូនចៅ ជាការគិតគូរពីអនាគតរបស់កូនចៅ។ ព្រោះថា ការៀបអាពាហ៍ពិពាហ៍យកគ្នាជាប្តីប្រពន្ធមិនមែនរស់នៅជាមួយគ្នាមួយថ្ងៃពីរថ្ងៃទេ គឺមួយជីវិត ដូច្នេះត្រូវតែគិតគូរឱ្យបានវែងឆ្ងាយ។ ម្យ៉ាងទៀត ក្នុងផ្នត់គំនិតចាស់បុរាណកូនប្រុសប្រៀបបីដូចជាជើងមុខ កូនស្រីប្រៀបបីដូចជាជើងក្រោយ ជើងក្រោយត្រូវដើរតាមជើងមុខ កាលណាជើងមុខអត់មាំ អត់ខ្លាំង អត់មានសមត្ថភាពទេ ជើងក្រោយដើរទៅគឺដួលតាមជើងមុខហើយ នោះអត់សេចក្តីសុខទេគ្រួសារហ្នឹង។ ផ្នត់គំនិតខ្មែរពីដើមកូនប្រុសប្រៀបដូចជាមេគ្រួសារ ជាមនុស្សសំខាន់ក្នុងគ្រួសារ ឯកូនស្រីត្រឹមតែជាមេផ្ទះ។

| | | |
|---|---|---|
| *"ដងនោះឥសូរមិថិលា* | *រៀបរាជយោធា* | *នូវថ្នាត់នឹងថ្នានព្រះនគរ។* |
| *នៅរាជកញ្ញាសុបវរ* | *ស្មើបុត្រដ៏ឧទរ* | *ក៏លុះលើរាជពិភព ។* |
| *ស្តេចរក្សារាស្ត្រផងស្កល់ស្កប់* | *ស្តេចទើបឱ្យអ-* | *ភិសេកប្រកបនាមា។* |
| ...................................... | ........................ | .......................... |
| *ដងនោះព្រះបាទនរបតី* | *យល់រាជបុត្រី* | *ពិសេសពិសុទ្ធសុន្ទរ។* |
| *នោះព្រះមុនីរាជដ៏បវរ* | *ជបធនូសិល្បសរ* | *នូវស័ព្ទសច្ចាអធិស្ឋាន។* |
| *ថាទោះទេពតាឫទ្ធិមាន* | *ជ័យអាចលើកបាន* | *ធនូសិល្ប៍នូវតេជោជ័យ។* |
| *យើងនូវយករតន៍សីតាថ្លៃ* | *អភិសេកឱ្យឮ* | *នាទេពដ៏មានចេស្តា។"* |

(**វឌ្ឍនាយាវង្ស** ខ្សែទី១ ទំព័រ៦-៧)

ដើម្បីជ្រើសរើសគូឱ្យនាងសីតា មានបេក្ខភាពពីទិសទាំងដប់ចូលរួម អ្នកនិពន្ធលោកពណ៌នាថា៖

| | | |
|---|---|---|
| *"អស្ចារ្យទួទសទិសា* | *កក្រើកត្រៃត្រឹង្សា* | *ឧណ្ណាអស់ទេពដ៏និករ។* |
| *អស់ទេពតាផងសឹងដ៏អរ* | *បរគ្នាវីវរ* | *រត់ចុះពីត្រៃត្រឹង្ស។"* |

(**វឌ្ឍនាយាវង្ស** ខ្សែទី១ ទំព័រ៧)

- **ការគោរពពាក្យសត្យ**

តាមវប្បធម៌ខ្មែរ ខ្មែរបាននិយមឱ្យតម្លៃសម្តីជាឯក(សម្តីជាឯក លេខជាទោ អក្សរជាត្រី)។ សម្តីបើនិយាយទៅហើយគេចាត់ទុកជាបានការ ព្រោះមនុស្សគេយកសម្តី។តម្លៃនៃមនុស្សគេយកសម្តី (មនុស្សគេយកសម្តី ដំរីគេយកភ្លុក) សម្តីដែលនិយាយមកហើយមិនអាចលេបវិញបានទេ(រនាបបាក់យករនាបជួស តែបើសម្តីហួសមិនអាចជួសវិញបានទេ)។ មនុស្សដែលគោរពសម្តីគេចាត់ទុកជាមានតម្លៃ មនុស្សដែលគោរពសម្តីគេចាត់ទុកជាមនុស្សបានការ មនុស្សដែលមានភាពទទួលខុសត្រូវ។

**ព្រះបាទទសរថ** (គោរពពាក្យសត្យសន្យាប្រគល់រាជសម្បត្តិឱ្យព្រះភិរុត)

*"ព្រះទសរថរាជឆ្លើយស្តង ថាឱ្យនាងហោង គឺមោះអញសូមពីនាណា ។*
*នាព្រះនគរស្រីអយុធ្យា នេះអញបងជា ភាគពីររំលែកចេញហោង ។*
*ឱ្យព្រះរាជបុត្រច្បង នូវព្រះភិតគ្រង ឱ្យគង់ដូចសត្យប្តេជ្ញា ។"*

(វឌ្ឍឆាយាវង្ស ***រាមកេរ្តិ៍ខ្មែរទី១*** ទំព័រ៣៧ )

**ព្រះរាម** (គោរពពាក្យសត្យចាកចេញពីនគរទៅព្រៃ១៤ឆ្នាំ)

*ដងនោះនារាយណ៍រាមា ស្តេចទ្រង់ព្រះចិន្តា នឹងព្រះអនុជនូវទេពី ។*
*ថាយើងនៅមណ្ឌលទី ចិត្រកូដគីរី នេះទាបអយុធ្យាព្រះនគរ ។*
*ក្រែងព្រះភិរុតនាំបរ ញូរមកអង្វរ សំបូងសម្លេងអញបង ។*
*ខិតខំឱ្យអញទៅគ្រង រាស្ត្រពិភពស្នង សម្តេចព្រះវរបិតា ។*
*ច្នេះគួរយើងចរលីលា លះលែងបព្វតា ទៅរកទីស្ថានទូរគម ។*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី២ ទំព័រ៨៤-៨៥)

**ព្រះបាទជនក**(គោរពពាក្យសត្យ សន្យាបើជនណាលើកធ្នូរួចនឹងលើកសីតាឱ្យជាភរិយា)

*ព្រះបាទចក្រពត្តិរាជា ជនករាជដ៏មហា ក្សត្រត្រេកព្រះរាជហឫទ័យ ។*
*ស្តេចនូវយកសីតារតន៍ថ្លៃ ស្តុតីឱ្យជ័យ ប្រដាប់នៅមង្គលការ ។*
*ផ្សំនូវព្រះរាមឫទ្ធីមោះហិមា ប្រើខ្ញុំព្រះករុណា មកទូលសម្តេចភូបាល ។*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី១ ទំព័រ១២ )

**នាងសីតា** (គោរពពាក្យសត្យ នាងបានប្រកាសចំពោះមុខទេពតាថា នាងនឹងត្រឡប់ចូលព្រះនគរល្ពឹកណាព្រះរាមសោយទិវង្គត)។

*ម្លេះហើយកុំស្តេចសង្កា ម្តាយពុំប្រាថ្នាវិលថ្កាន*
*នឹងនៅតាមកម្មបុរាណ សូវស្លាប់ពុំទៅយល់ឡើយ ។*
*ថាបើព្រះអង្គសុគត មែនពិតប្រាកដជាក់ហើយ*
*សឹមម្តាយវិលទៅកូនអើយ បង្គំព្រះសពក្សត្រថ្លៃ ។*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី៨០ ទំព័រ៤)

- **ការរៀបមង្គលការនៅផ្ទះខាងស្រី**

ជាទំនៀមរបស់មនុស្សខ្មែរ ពិធីរៀបមង្គលការត្រូវធ្វើឡើងនៅផ្ទះខាងស្រី។ នេះជាការលើកកិត្តិយស ការឱ្យតម្លៃ ការបង្ហាញពីបវេណីរបស់ជាតិខ្មែរដែលយកស្ត្រីជាធំ។ រឿងរាមកេរ្តិ៍មានខ្លឹមសារបញ្ជាក់ត្រង់ព្រះបាទជនកបានប្រើខ្ញុំបម្រើឱ្យទៅយាងព្រះបាទព្រះបាទទស

រថ ដោយនាំមកនូវគ្រឿងរណ្ដាប់អាពាហ៍ពិពាហ៍មកជាមួយផង ដើម្បីមកអភិសេកបុត្រនៅនគរមិថិលាដែលជានគរខាងស្រី។

*ស្ដេចនូវយកសីតារតន៍ថ្លៃ ស្តុតីឱ្យជ័យ ប្រដាប់នៅមង្គលការ។*
*ផ្សំនូវព្រះរាមឫទ្ធីមោះហិមា ប្រើខ្ញុំព្រះករុណា មកទូលសម្តេចភូបាល។*
*ឱ្យអញ្ជើញព្រះភូវនាថ ស្ដេចទៅនូវគ្រអាវ រណ្ដាប់អាពាហ៍ពិពាហ៍។*

- **ការនិយមជឿលើមហិទ្ធិឫទ្ធិអាទិទេព**

ខ្មែរតែងចាត់ទុកបុគ្គលដែលមានឫទ្ធិខ្លាំងពូកែ បុគ្គលដ៏អស្ចារ្យ ថាជាតំណាងអាទិទេពចុះមកសង្គ្រោះលោក ឬចុះមកបង្ក្រាបសភាវអាក្រក់ណាមួយ។ ដូច្នឹងហ៎យបានជាក្នុងដំណើររឿងរាមកេរ្តិ៍ ព្រះរាមជាអវតាទី៧របស់ព្រះនរាយណ៍ ដែលចុះមកបង្ក្រាបពួករាពណ៍ដែលចូលចិត្តមករាតត្បាតលោក។

- **ការនិយមជឿថាសត្វចង្រៃ(កុក)**

តាមផ្នត់គំនិត ខ្មែរមានជំនឿលើសត្វកុកថាជាសត្វចង្រៃ ជាសត្វដែលនាំមកនូវឧបទ្រព។ ក្នុងដំណើររឿងរាមកេរ្តិ៍ នៅពេលដែលសត្វកុកនាំដំណឹងពីនាងសីតាទៅប្រាប់ព្រះរាម ព្រះលក្ស្មណ៍, ព្រះរាម ព្រះលក្ស្មណ៍មិនបានអស់គុណកុកទេ បែរជាជេរប្រមាថកុក។ ត្រង់ចំណុចនេះ បើអ្នកមិនបានដឹងពីផ្នត់គំនិតខ្មែរ គេនឹងគិតថាព្រះរាម ព្រះលក្ស្មណ៍រមិលគុណណាស់ ព្រោះកុកបាននាំដំណឹងមកប្រាប់ហើយ បែរជាជេរប្រមាថគេទៅវិញ។ តែបើអ្នកដឹងពីផ្នត់គំនិតខ្មែរទើបដឹងថា សម្ដីរបស់សត្វចង្រៃជាសម្ដីអពមង្គល។ ក្នុងផ្នត់គំនិតខ្មែរ ក្រៅពីសត្វកុកក៏នៅមានសត្វដទៃទៀតដែរដូចជា៖ សត្វមៀម ទីទុយ ខ្លែងស្រាក លលក ...។ល។ឱ្យតែមានសត្វព្រៃទាំងអស់នេះស្រែក យំ ឬចូលផ្ទះកាលណា ប្រាកដជាមានឧបទ្រពចង្រៃចូលផ្ទះហើយ។

*ថាហៃពិភេកព្រះស្តែង កាចអាចម្តេចថ្លែង ពុំនោលជំនៀលចិន្តា។*
*ថាអញដូចក្អែកសត្វសា- មាន្យបឹងឧបមា អញសោតដូចត្រីតិរិច្ឆាន ។*

*.................................. .......................... ..................................*

*អញទៅទរត្បូងមឹងនឹងក្រទា ដែកបែកសិរសា ដ៏ជាប្រាំពីរភាគផង។*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្សែទី៨ ទំព័រ៦)

- **ការនិយមតម្កល់សពក្នុងកោដ្ឋ**

ជាបវេណីរបស់មនុស្សខ្មែរ នៅពេលមានបុគ្គលណាចែកឋានទៅ គេតែងតែយកសពទៅតម្កល់ក្នុងកោដ្ឋ ឬចេតិយ ដែលកោដ្ឋខ្មែរមានពីរប្រភេទ មួយប្រភេទសម្រាប់ដាក់សពទាំងមូល(ព្រះរាជា ព្រះក្សត្រីយានី ឬអ្នកដែលមានឋានៈស្មើសម្តេច) មួយប្រភេទទៀតសម្រាប់ដាក់អដ្ឋិ(ឆ្អឹង)របស់សាមញ្ញជនដែលគេបានបូជាហើយ។ កោដ្ឋ និងចេតិយក្នុងវប្បធម៌ ផ្នត់គំនិត

ខ្មែរ ត្រូវបានគេចាត់ទុកជាទីមង្គលសម្រាប់អ្នកដែលចែកឋានទៅ ព្រោះកាលណាតែគ្មានកោដ្ឋ ឬចេតិយតម្កល់ទេនោះគេនិយមជឿថាវិញ្ញាណក្ខន្ធគ្មានជម្រក និងនៅមិនស្ងប់ឡើយ។ បេប នេះហើយទើបគេនិយមធ្វើចេតិយ ធ្វើកោដ្ឋសម្រាប់បុគ្គលដែលចែកឋានទៅ។

ក្នុងរឿងរាមកេរ្តិ៍ នៅពេលដែលនាងសីដាមុននឹងចេញពីនគរ នាងប្រកាសថា នាងត្រឡប់ចូលនគរវិញល្អឹកណាព្រះរាមសោយទិវង្គត។ លុះបានព័ត៌ឮថាព្រះរាមសោយទិវង្គតក៏ត្រឡប់ចូលនគរវិញឃើញកោដ្ឋ(ព្រះរាមចូលកោដ្ឋបញ្ឆោទនាងសីតា)។ នេះជាទិដ្ឋភាពវប្បធម៌អត្តសញ្ញាណជាតិខ្មែរមួយដែរ។

*“ថ្ងៃះចូរបាគិតរណ្ដាប់ — មេរុកោដ្ឋឱ្យឆាប់នេះម្ដង*
*កុំឱ្យអស់នរអ្នកផង — ឮលេចសាយសព្ទវាចា។*
*បងនឹងឧបាយកលគិត — ថាបងក្ស័យពិតហើយណា*
*លល្ងងឱ្យបានធីតា — ចូលមកពិភពបូរី។*

*.................................. — ..................................*

*រំពេចកើតជាមេរុមាស — រុងរឿងឱភាសពេកក្លាត់*
*កាដ្ឋកែវដាំត្បូងពិចិត្រ — កំពូលកំពស់មេឃា ។*
*ជើងមេរុសឹងត្រុឌផ្ទាល់ — ដោយរូតរៀងរាល់រចនា*
*ត្របកបុទមផ្ទៃថ្លា — លួសលេចក្អកពេជ្រឆ្វាក់ឆ្វាយ។*
*ហើយមានពិដានឆ្វេតឆត្រ — ដោយជាន់សង្កាត់រៀងរាយ*
*បាក់ស្ពានពិមានសួគ៌ាលាយ — ចរចុះមកនៅដែនដី។”*

(វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្មែរទី៨ ទំព័រ១៣-១៥)

## ខ-តម្លៃឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រសង្គ្រាម

យើងបានដឹងហើយថា រឿងរាមកេរ្តិ៍គឺជារឿងមួយដែលអ្នកនិពន្ធបានបង្ហាញពីការធ្វើចម្បាំងដ៏វែងឆ្ងាយមួយមិនព្រមចាញ់ឈ្នះ និង ដោយឥតឈប់ឈររវាងភាគីខាងព្រះរាម និងភាគីខាងរាពណ៍។ នៅក្នុងការធ្វើសង្គ្រាមនោះ គូភាគីទាំងសងខាងបានខិតខំរិះរកមធ្យោបាយល្បិចកិច្ចកលគ្រប់បែបយ៉ាងដើម្បីបម្រើឱ្យមហិច្ឆិតារបស់ខ្លួន មានទាំងយុទ្ធសាស្ត្រផ្លូវចិត្ត យុទ្ធសាស្ត្រផ្លូវកាយ យុទ្ធសាស្ត្រផ្ដាច់សៀ្បង យុទ្ធសាស្ត្របំបែកបំបាក់ យុទ្ធសាស្ត្រគំរាមកំហែង យុទ្ធសាស្ត្រផ្ដាច់ការ យុទ្ធសាស្ត្របំភាន់ស្មារតី និងយុទ្ធសាស្ត្រទិញទឹកចិត្តជាដើម ដើម្បីទទួលបានជ័យជម្នះរៀងៗខ្លួន ដែលការបង្ហាញនូវយុទ្ធសាស្ត្រទាំងនេះ វាជាផលប្រយោជន៍សម្រាប់អ្នកធ្វើសឹកសង្គ្រាម ដែលបានអានរឿងរាមកេរ្តិ៍យកមកត្រិះរិះពិចារណាថាតើគួរយកយុទ្ធសាស្ត្រណាមួយមកដោះស្រាយនៅក្នុងការធ្វើសង្គ្រាមរបស់ខ្លួន។

- **យុទ្ធសាស្ត្រផ្លូវចិត្ត** ៖

ជាយុទ្ធសាស្ត្រមួយយ៉ាងសំខាន់ក្នុងការធ្វើសឹកសង្គ្រាម ឬក៏ដោះស្រាយបញ្ហាអ្វីមួយ។ ជួនកាលជ័យជម្នះនៃសង្គ្រាម និងជ័យជម្នះនៃបញ្ហាណាមួយមិនអាចពឹងផ្អែកតែទៅលើកម្លាំងកាយ ឬកម្លាំងទ័ព និងគ្រឿងសព្វាវុធនោះទេ គឺពេលខ្លះក៏ត្រូវពឹងផ្អែកទៅលើការស្គាល់ពីចិត្តសាស្ត្រ ឬចំណុចខ្លាំង និងចំណុចខ្សោយរបស់គូសត្រូវផងដែរ ព្រោះថាចិត្តសាស្ត្រ គឺជាកត្តាសំខាន់សម្រាប់ឈានទៅរកភាពជោគជ័យ។ បើកាលណាបាត់បង់ចិត្តសាស្ត្រហើយ ទោះបីជាមេទ័ពនៃសង្គ្រាម ឬអ្នកជួបបញ្ហានោះខ្លាំងពូកែយ៉ាងណាក៏ដោយ ក៏ពិបាកនឹងយកជ័យជម្នះក្នុងសឹកសង្គ្រាម ឬបញ្ហានោះដែរ តែផ្ទុយទៅវិញបើសិនជាមេទ័ពសង្គ្រាម ឬអ្នកជួបបញ្ហានោះមិនសូវខ្លាំងពូកែទេ តែគេជាបុគ្គលដែលប៉ិនប្រសប់ក្នុងការស្វែងយល់ចិត្តសាស្ត្រ នោះគេអាចទទួលជ័យជម្នះបាន។ ដោយសារតែការមើលឃើញពីកត្តាចិត្តសាស្ត្រជាកត្តាសំខាន់ដូច្នេះហើយ ទើបបានជាក្រុងរាពណ៍បានជ្រើសរើសយកយុទ្ធសាស្ត្រផ្លូវចិត្តនេះ មកធ្វើសង្គ្រាមជាមួយព្រះរាម ដោយក្រុងរាពណ៍បានយកនាងសីតាមកបញ្ចិះលើរាជរថ ហោះទៅលើអាកាសចំពីមុខពន្លាព្រះរាម ក្នុងគោលបំណងបញ្ឈឺចិត្តព្រះរាមដើម្បីឱ្យឈឺចាប់ ធ្វើឱ្យព្រះរាមអស់កម្លាំងចិត្តបញ្ជាការប្រយុទ្ធលែងមានប្រសិទ្ធភាព ហើយខ្លួននឹងអាចយកជ័យជម្នះលើព្រះរាមបាន ដូចដំណើររឿងរបស់អ្នកអង្គម្ចាស់វឌ្ឍឆាយាវង្ស ខ្សែទី៨ ទំព័រ៣៤ បានបញ្ជាក់ថា៖

*“កាលនោះក្រុងរាពណាសូរ យក្សាដ៏ត្រកូល សម្តែងឫទ្ធីជាញជ័យ។*
*ទីមរថពាជីមកនៃ ស្អាងអង្គបីប្រពៃ ជំនិះហោះលើវហាស៍។*
*នាំព្រះទេពីសីតា ព្រះរាជជាយា ប្រសើរព្រះអគ្គកហេសី។*
*ហោះផ្សានមកដោយឫទ្ធី អំណាចអសូរី អសូរមកថ្កើនលើណា។”*

ម្យ៉ាងវិញទៀត កាលដែលព្រះរាមប្រើអង្គទដែលជាកូនរបស់ពាលីឱ្យធ្វើជាអ្នកកាទូតដើម្បីនាំសាររបស់ព្រះអង្គទៅប្រាប់រាពណ៍ អង្គទបានយកចិត្តសាស្ត្របំបាក់ស្មារតី សំឡុតរាពណ៍ព្រោះអង្គទទៅពេលនេះ មិនមែនទៅជារាជទូតធម្មតាទេ ក៏ប៉ុន្តែអង្គទជាអ្នកតំណាងឱ្យអ្នកកាទូតមហាអំណាចមួយ គឺទង្វើដ៏អង់អាចក្លាហាន ឃោរឃៅ និងមានលក្ខណៈមើលងាយគូចរចាររបស់ខ្លួន(ការបំភ័យទ័ពយក្ស ការបំបែកបំបាក់ទ្វារកំពែងរបស់យក្ស និងការសម្លាប់យក្សជាដើម) និង ម្យ៉ាងវិញទៀត អង្គទទៅបំបាក់មុខរាពណ៍នៅចំពោះមុខមហាជន ដោយអង្គទពុំព្រមអង្គុយស្មើឥន្ទ្រជិត និងកុម្ភការណ៍ ឬអង្គុយទាបជាងរាពណ៍នោះទេ គឺអង្គទឆ្វាយកន្ទុយឡើងខ្ពស់អង្គុយស្មើនឹងរាពណ៍តែម្តង ហើយថែមទាំងលើកយករឿងរ៉ាវចាស់កាលដែលក្រុងពាលីជាឪពុកបានចាប់រាពណ៍ឱ្យយោលអង្រឹងឱ្យខ្លួន ធ្វើឱ្យរាពណ៍អាម៉ាស់ចំពោះមុខមន្ត្រីសេនាហើយ នៅមិនគ្រប់គ្រាន់ទៀត គឺអង្គទថែមទាំងទះកំភ្លៀងរាពណ៍ឱ្យដួលនៅមុខមហាជនដែលទង្វើទាំងនេះ

ធ្វើឡើងដើម្បីបំបាក់ស្មារតី បង្អាប់កិត្តិយស និង ឫទ្ធានុភាពរបស់រាពណ៍ដែលជាស្ដេចយក្សតែម្ដង។

*"យល់ទសមទុខខ្ពស់លើសព្រះកាល ទែនកែវមំសា ពពាលនូវរតន៍រចនា*
*អង្គទតម្កើងព្រះអាជ្ញា ឆ្វាយនង្គុដ្ឋដ៏មហា ទីឃោគឃ្លាយវែងវាត់។*
*បំពែនជាភ្កែនពែនព័ទ្ធ ឆ្វាយជាន់ក្ដាត់ អង្គទអង្គុយថ្កើងក្រៃ។*
*ស្រៀកលើសនឹងទសមុខនៃ ទសមុខក្រោធក្រៃ ក្រឡេកក្រឡៅបីសម្លឹង*
*អង្គទបង់ជំទាញទ្រេតរឹង រាពណ៍រឹងខេងខឹង ក៏ទប់កំហឹងធ្វើក្សាន្ត។"*

(វឌ្ឍធាយាវង្ស *រាមកេរ្តិ៍ខ្សែទី៨* ទំព័រ៦០)

- **យុទ្ធសាស្ត្រផ្លូវកាយ** ៖

ក្នុងការធ្វើសឹកសង្គ្រាម ចាំបាច់បំផុតនូវកម្លាំងផ្លូវកាយ ព្រោះថាបើមិនមានកម្លាំងគ្រប់គ្រាន់ទេនោះ ការធ្វើសឹកសង្គ្រាមក៏មិនអាចទទួលបានជ័យជម្នះទាំងស្រុងដែរ។

នៅក្នុងរាមកេរ្តិ៍ក៏បានលើកឡើងបង្ហាញនូវយុទ្ធសាស្ត្រផ្លូវកាយក្នុងការធ្វើសឹកសង្គ្រាមផងដែរដូចជា៖ ការត្រៀមកម្លាំងទ័ពជាច្រើនរាប់សិបអក្ខោភិនី ទាំងខាងព្រះរាម និងទាំងខាងក្រុងរាពណ៍ ហើយមានការជ្រើសរើសយកអ្នកខ្លាំងពូកែនិងអ្នកមានសមត្ថភាពដើម្បីច្បាំងយកជាញជ័យ ដើម្បីទៅស៊ើបព័ត៌មាន និងដើម្បីទៅបញ្ចុះបញ្ចូលប្រមូលបក្សពួកមករួបរួមកម្លាំងគ្នាជាដើម តួយ៉ាងដូចជាខាងព្រះរាមបានប្រមូលកម្លាំងគ្នាពួតដៃកសាងផ្លូវជាយុទ្ធសាស្ត្រចម្បង និងជាពិសេសទាំងខាងព្រះរាម ក៏ដូចជាទាំងខាងរាពណ៍បានរៀបចំកម្លាំងទ័ពរៀងៗខ្លួន ដើម្បីធ្វើសឹកសង្គ្រាមជាមួយគ្នា។

*"ស្ដេចចរលុះដល់ឆ្នេរសាគរ ចតុទ័ពស្ដានពរ នៅភូមិមានជ័យជម្នះ*
*ភ្កើងអង្គកែវពុងថ្កើងព្រះ បារមីនូវតេជះ តបៈឫទ្ធិចេស្ដា។*
*រាយនាមមន្ត្រីសេនា ទាហានយោធា មហាក្របិន្ទពានរ។*
*សព្ទកងបីរំពងខ្ទារខ្ទរ ដោយទសទិសសាគរ អំពើកកក្រើកពសុធា។*
*ក្រុងរាពណ៍ឮព្រះរាមា ធិបតិន្ទរាជា ធិរាជក៏ឆ្លងជលធី។*
*លុះត្រើយលង្ការភូមិ ពីរព្រះចក្រី ក៏រេងរន្ទេះរឿណរង្គ។*
*សឹងត្រៀបសឹងរៀបពលផ្ទង់ ចួតចងគជគង់ គ្រប់អង្គទីទៃបីអធិក។*
*ប៉ុនប៉ងនូវប្រទះសាសឹក ហានប្ញាសឥតភ្លឹក ចម្បាំងរឿណរង្គសោះសារ។"*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ ខ្សែទី១ ទំព័រ៣)

- **យុទ្ធសាស្ត្រផ្ដាច់សៀង** ៖

ជាយុទ្ធសាស្ត្រចម្បងមួយដែរក្នុងការធ្វើសឹកសង្គ្រាម ដើម្បីយកប្រៀបលើគូសត្រូវរបស់ខ្លួន។ មិនថាជាសង្គ្រាមធំ ឬសង្គ្រាមតូចកម្រិតណាទេ ប្រសិនបើភាគីខាងណាអាចមានឱកាស ឬមានវិធីសាស្ត្រផ្តាច់ស្បៀងគូសត្រូវបាន គឺគេឆក់ឱកាសធ្វើភ្លាម ព្រោះថាស្បៀងជាកត្តាចម្បងសម្រាប់ទ្រទ្រង់សឹកសង្គ្រាម។ បើគ្មានស្បៀងក៏មិនអាចធ្វើសង្គ្រាមបានដែរ សូម្បីតែសុភាសិតខ្មែរដែលជាគតិបណ្ឌិតប្រជាប្រិយនោះ ក៏លើកឡើងពីសារសំខាន់នៃស្បៀងអាហារក្នុងការធ្វើសឹកសង្គ្រាមដែរគឺសុភាសិត **ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ**។ យ៉ាងណាមិញ តាមរយៈការធ្វើសឹកសង្គ្រាមក្នុងរឿងរាមកេរ្តិ៍ ក្រុងរាពណ៍ក៏បានយកយុទ្ធសាស្ត្រផ្តាច់ស្បៀង មកអនុវត្តនៅក្នុងសឹកសង្គ្រាមរបស់ខ្លួនផងដែរ ដូចជា៖ ក្រុងរាពណ៍បានឱ្យយក្សឈ្មោះរុក្ខសេននាំពលសេនាទៅយាមការពារព្រៃឱ្យបានហ្មត់ចត់ ដើម្បីកុំឱ្យទ័ពព្រះរាមគឺទ័ពស្វាបេះផ្លែឈើស៊ីបាន ព្រោះបើអត់ស្បៀង ពលព្រះរាមនឹងហេវហត់អស់កម្លាំងមិនអាចធ្វើចម្បាំងបានឡើយ ដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់ *វឌ្ឍនាយាវង្ស* ខ្សែទី៨ ទំព័រ១៨-១៩ បានបញ្ជាក់ថា៖

*"មឹងអាងអួតឯចេស្តា រាមលក្ស្មណ៍អនុជា អម្ចាស់នៃស្វាពានរ។*
*រស់ដោយដើមព្រឹក្សាករ បេះផល្លបវរ៍- ភោគ្គាដ៏ជាអាហារ។*
*ទាំងក្សត្រទាំងពលបរពារ សឹងបរិភោគគ្គា អាហារអាស្រ័យដើមឈើ។*

*...................... ........................... ...............................*

*អញនូវឱ្យយក្សកៀរគោះ គ្នាចាំព្រៃនោះ ដោយសព្វអន្លើក្លាត់ចាប់។*
*ទោះបីរស់សឹងដ៏ស្គមធោងធេង ព្រមព្រួយចិត្តឯង រំពៃរំពឹងរឹងរិល។"*

- **យុទ្ធសាស្ត្របំបែកបំបាក់**៖

ការបំបែកបំបាក់ក៏ជាកត្តាមួយសំខាន់ផងដែរនៅក្នុងការធ្វើសឹកសង្គ្រាម ដែលកត្តានេះគេត្រូវតែប្រុងប្រយ័ត្នបំផុត ព្រោះថា បើកាលណាភាគីណាមួយមានការបែកបាក់ផ្ទៃក្នុងហើយនោះ វាជាការផុយស្រួយបំផុតសម្រាប់ភាគីនោះ ហើយភាគីមួយទៀតងាយនឹងដណ្តើមយកជ័យជម្នះបានណាស់ ហើយនៅក្នុងរឿងរាមកេរ្តិ៍ យុទ្ធសាស្ត្របំបែកបំបាក់នេះក៏បានបង្ហាញតាមរយៈតួអង្គព្រះរាមដែលបានធ្វើការញុះញង់ បំបែកបំបាក់បងប្អូនគេ (ពាលី និងសុគ្រីព) ឱ្យមានទំនាស់នឹងគ្នាកាន់តែខ្លាំងឡើង ព្រោះព្រះរាមសុខចិត្តលបលួចសម្លាប់ពាលីប្លន់យកអំណាចរបស់ពាលីទៅឱ្យសុគ្រីព ដើម្បីប្រយោជន៍ផ្ទាល់ខ្លួនរបស់ទ្រង់ គឺចង់ឱ្យសុគ្រីពប្រមូលកម្លាំងទ័ពឱ្យខ្លួន។

*"ដងនោះពីរព្រះពីរពង្ស សម្តេចស្តេចត្រង់ បីលុះនៃខាស់ខិនហោង។*
*ព្រះប្រើសុគ្រីពទៅផ្គង ហៅពាលីបង ទទែរទទូចឱ្យខឹង។*
*លែងបានពាលីឫទ្ធិរឹង ចេញមកប្រយុទ្ធនឹង សុគ្រីពកណ្តាលវេហាស៍។*

*បានព្រះនូវថ្លែងសរថ្លា ផ្ដួលផ្ដាច់ក្រុងពា- លីលុះនូវសរព្រហ្មាស ។"*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ ខ្សែទី៥ ទំព័រ២៩)

- **យុទ្ធសាស្ត្រគំរាមកំហែង ៖**

នៅក្នុងការធ្វើសឹកសង្គ្រាម ការគំរាមកំហែងក៏មានសារសំខាន់ណាស់ដែរ ព្រោះជួនកាលគូសត្រូវអាចខ្លបខ្លាចដោយសារការគំរាមនេះ ជួនកាលដើម្បីសង្គ្រាមជោគជ័យអ្នកធ្វើសង្គ្រាមខ្លះក៏ទៅគំរាមកំហែងអ្នកដទៃ ដើម្បីឱ្យអ្នកដទៃខ្លបខ្លាចហើយជួយបម្រើផលប្រយោជន៍ឱ្យខ្លួន តួយ៉ាងដូចជាព្រះរាមគំរាមកំហែងអ្នកតូចតាចឱ្យបម្រើផលប្រយោជន៍ឱ្យខ្លួនដោយមិនត្រាប្រណី ដូចជាការគំរាមកំហែងនាងមេខល្លា នៅពេលដឹងថាហ្វូងត្រីបានជញ្ជូនថ្មភ្នំដែលទ័ពស្វាខំលើកយកមកសង់ស្ពាន ដែលជាគមនាគមន៍ចម្បងសម្រាប់ទ្រង់លើកទ័ពឆ្លងទៅធ្វើសង្គ្រាមនៅលង្កាដោយព្រះរាមគំរាមថា បើមិនព្រមសង់ស្ពានឱ្យទ្រង់វិញទេ នោះទ្រង់ផ្លែងសរឱ្យអន្តរាយហ្វូងត្រីទាំងអស់ ដែលធ្វើឱ្យនាងមេខល្លាខ្លបខ្លាច ហើយព្រមសង់ស្ពានថ្វាយព្រះរាមវិញ ។

*"ហេតុនោះអញផ្ទាញ់ជលសារ រឹងឬាតពិតដ៏ជា ឫទ្ធីនូវនាំពលព្រិន្ទ ។*
*ព្រះសមុទ្រក្រាបបាទនរពិន្ទ ទូលព្រះភូមិន្ទ វន្ទត់លើកករវន្ទា ។*
*បពិត្រសត្វផងពឹងពា សូមស្ដេចករុណា ជីវិតអស់សត្វសម្ងាយ ។*
*ខ្ញុំសូមចងថ្នល់ថ្វាត់ថ្វាយ សូមព្រះអង្គសាយ ពិរោធទ្រង់ព្រះកម្សាន្ត ។"*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្សែទី៧ ទំព័រ៥១)

និងនៅពេលដែលព្រះលក្សណ៍ត្រូវរបួសដោយសារស្នាដៃឥន្ទ្រជិត ដែលថ្លែងសរឱ្យនាគមករួតរឹត ព្រះរាមបានគំរាមកំហែងទេព្តានៅពិភពសួគ៌ាថានឹងថ្លែងសរឱ្យឆេះឋានសួគ៌ប្រសិនបើព្រះលក្សណ៍ស្លាប់ជាដើម។ ដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់ ***វឌ្ឍឆាយាវង្ស*** ខ្សែទី៩ ទំព័រ៤៥ បានបញ្ជាក់ថា៖

*"បើព្រះអនុជអញលុះដ៏កាល អស់ទេព្តាដ៏អម្បាល នៅនាពិភពសួគ៌ា ។*
*អញនូវថ្លែងសរដ៏មហា សិទ្ធិសក្តាមុតថ្លា ឱ្យសូន្យពិមាននាសបង់ ។*
*ឱ្យល្អិតជាពពុះឆេះផង ឱ្យគង់តែត្រង់ ឋានព្រះឥសូរស្ដេចស្ថិត ។*
*នាគាបីតណានារឹងឫទ្ធី អញនូវពិជិត ពិជ័យនៃអស់ទេព្តា ។"*

- **យុទ្ធសាស្ត្រផ្ដាច់ការ ៖**

នៅក្នុងការធ្វើសឹកសង្គ្រាមការផ្ដាច់ការក៏ជាការសំខាន់ ព្រោះថាបើអ្នកបញ្ជាទ័ពមិនប្រើយុទ្ធសាស្ត្រផ្ដាច់ការខ្លះទេ ក៏មិនអាចគ្រប់គ្រងការបញ្ជាទ័ពឱ្យចេញប្រយុទ្ធបានដែរ ដូច្នេះពេលខ្លះអ្នកបញ្ជាទ័ពក៏ត្រូវការយុទ្ធសាស្ត្រនេះដែរ តួយ៉ាងដូចជា រាពណ៍បានប្រើអំណាចផ្ដាច់ការទៅលើកងទ័ពដោយបង្ខំអ្នកនៅក្រោមបង្គាប់ឱ្យគោរពតាមការបញ្ជារបស់ខ្លួន ដោយរាពណ៍

បានបញ្ជាឱ្យកូន ប្អូន និងមេទ័ព ឱ្យលើកពលទៅច្បាំងជាមួយព្រះរាមជាដាច់ខាត។ ជាពិសេសគឺនៅពេលដែលរាពណ៍ប្រើកុម្ភការណ៍ឱ្យលើកទ័ពទៅប្រយុទ្ធជាមួយព្រះរាម កុម្ភការណ៍ជាក្សត្រប្រកបដោយទសពិតរាជធម៌ និយាយពន្យល់រាពណ៍ពីបុព្វហេតុដើមចមដែលនាំឱ្យមានសង្គ្រាម រាពណ៍មិនត្រឹមតែមិនព្រមធ្វើតាមទេ បែរជាចោទកុម្ភការណ៍ថាជាមេទ័ពដែលខ្លាចមនុស្សខ្លាចស្វានាំឱ្យខូចកេរ្តិ៍ឈ្មោះវង្សត្រកូលរបស់ខ្លួនទៅវិញ ដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់ ***វណ្ណឆាយាវង្ស*** ខ្សែទី៨ ទំព័រ៧០-៧១ បានបញ្ជាក់ថា៖

*"រាពណ៍ស្តាប់កុម្ភការណ៍រំលឹក ក្រោធក្រៃពន្លឹក ព្រះបាទទគ្រាំគ្រេង។*
*ត្រាស់ថាអានេះឥតក្រែង ហ៊ានទូលទាស់លេង ថាអញលុះលោភតណ្ហា។*
*ខ្លួនវាខ្លបខ្លាចសត្វស្វា ខ្លាចមនុស្សទ្វេហា ពុំហ៊ានអើតកចេញច្បាំង។*
*................................ ................................ ..................................។*
*រាពណ៍ឮដូច្នោះអរណាស់ ប្រែប្រាណថាអះ នេះចំជាប្អូនអញបង។*
*ចូរបាចូលយុទ្ធប្រលង យកជ័យនេះម្តង ទុកស្នាតេជដែដល់កប្ប។*
*ត្រាស់ឱ្យមហោទរតែងទ័ព ឱ្យស្រេចឆាប់ៗ នូវបានលើកទៅទាន់ការ។"*

- **យុទ្ធសាស្ត្រទិញទឹកចិត្ត**៖

ជាយុទ្ធសាស្ត្រមួយដែលគេត្រូវតែប្រុងប្រយ័ត្នផងដែរ ព្រោះថាការលោភលន់ និងការចង់បានកេរ្តិ៍ឈ្មោះតែងតែកើតមានចំពោះបុគ្គលគ្រប់រូប គ្រាន់តែថាតម្រូវការនោះតិច និងច្រើនតែប៉ុណ្ណោះ ហើយការទិញទឹកចិត្តនេះទាល់តែមានប្រយោជន៍ទើបគេទិញ ព្រោះវាជាថ្នូរនឹងលាភសក្ការៈណាមួយជាមិនខាន ដូច្នេះគេត្រូវតែប្រុងប្រយ័ត្នណាស់នៅពេលធ្វើសង្គ្រាម។ បើសិនជាភាគីណាមួយត្រូវបានគេទិញទឹកចិត្តបានហើយនោះ គឺភាគីនោះប្រឈមនឹងការបរាជ័យជាក់ជាមិនខាន។ យ៉ាងណាមិញតាមរយៈរឿងរាមកេរ្តិ៍ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ព្រះរាមបានឱ្យពិភេកទៅបញ្ចុះបញ្ចូលកុម្ភការណ៍ឱ្យចុះចូលនឹងខ្លួន (ទិញបងប្អូនឱ្យសម្លាប់គ្នា និងក្បត់គ្នា) ដោយទ្រង់សន្យាផ្តល់នូវយសសក្តិជាធំដល់កុម្ភការណ៍ នៅពេលដែលកុម្ភការណ៍ព្រមចុះចូលមកជាមួយខ្លួនដោយឱ្យយសសក្តិស្មើនឹងព្រះលក្សណ៍ ដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់ ***វណ្ណឆាយាវង្ស*** ខ្សែទី៩ ទំព័រ៨ បានបញ្ជាក់ថា៖

*"ហេតុនោះស្តេចប្រើខ្ញុំជា ទូតនាំព្រះអាជ្ញា មកថ្កានព្រះវៀមបពិត្រ។*
*ប្រើព្រះវៀមគិតតាំងចិត្ត ស្វាមីភក្តិស្នេហស្និទ ព្រះអង្គប្រសើរសម្ភារ។*
*ចូលទៅជារាជបរិពារ ព្រះបាទភូវនាថ សម្តេចនារាយណ៍រាមា។*
*ស្តេចទ្រង់ព្រះក្សាន្តករុណា ឱ្យយសសក្តា ធិកាព្រះវៀមថ្កើងក្រៃ។*
*ឱ្យបាំងស្វេតឆ្ឆត្រត្រួតថ្លៃ លើព្រះរោងនៃ ទន្ទឹមនូវព្រះអនុជា។"*

- **យុទ្ធសាស្ត្របោកប្រាស់** ៖

ការបោកប្រាស់ក៏ជាយុទ្ធសាស្ត្រមួយដែលនាំឱ្យសង្គ្រាមឈានទៅរកជ័យជម្នះ ឬបរាជ័យដែរ ពោលគឺបើភាគីណាអាចបោកប្រាស់គេបាន ភាគីនោះនឹងមានប្រៀបជាងភាគីដែលត្រូវបានគេបោកប្រាស់ តួយ៉ាងដូចជា ព្រះរាមបានខ្ចីអាវព្រះនារាយណ៍មកពាក់បន្លំមហាជម្ពូ ដើម្បីឱ្យមហាជម្ពូខ្លបខ្លាច ព្រមជួយជាកម្លាំងទ័ពដល់ព្រះរាមនៅក្នុងពេលទៅធ្វើសង្គ្រាមនៅលង្កា។

*"ក្សិណនោះព្រះបាទពង្សក្សត្រ　បើកបង្គួចរ័តន៍　កាឡាសម្តេចដ៏ឧត្តម។*
*ត្រែស័ង្គសម្ពាត់សោតសម　តន្ត្រីយ៍បីរង់　ត្រសាក់លេងល្បើយស្ងួតិសល់*
*ឯមហាជម្ពូរាជយង់យល់　ហាក់នារាយណ៍ទសពល ក៏ស្ដេចថ្កើងលើព្រះពន្លា។*

*......................................　.........................　....................................*

*ស្ដេចលែងកាឡានារាយណ៍　ប្រាកដជាអង្គ　ព្រះរាមទេពារឹងច្បាស់។*
*ហេតុសម្ភារបារមីក្រាស់　ស្ដែងស្ដេចត្រចត្រាស់ ដ៏ជាកំពូលភពត្រៃ។*
*មហាជម្ពូយល់ប្ញទីក្រៃ　ថាអ្នកនេះនៃ　គឺអង្គនារាយណ៍រាមា។"*

(វ័ឌ្ឍឆាយាវង្ស *រាកេរ្តិ៍ខ្មែរទី៧* ទំព័រ២៣-២៥)

ក្រៅពីយុទ្ធសាស្ត្រទាំងប៉ុន្មានខាងលើ យើងឃើញមាននូវយុទ្ធសាស្ត្រសង្គ្រាមជាច្រើនទៀតដែលនៅក្នុងរឿងរាមកេរ្តិ៍ជាស្នាដៃរបស់អ្នកនិពន្ធក្រៅពីអ្នកអង្គម្ចាស់ **វ័ឌ្ឍឆាយាវង្ស** ដូចជា៖

- **ការទប់ស្កាត់មិនឱ្យសត្រូវចូលមកក្នុងនគរ** ៖

ក្រុងរាពណ៍ឱ្យកុម្ភការណ៍ទៅស្រូបទឹកសមុទ្រឱ្យរីងអស់ តែពេលនោះអង្គទក៏ទៅកាឡាខ្លួនជាឆ្កែស្អុយធ្លាក់ចូលទៅក្នុងមាត់អសុរ ធ្វើឱ្យអសុរស្អុយដកដង្ហើមមិនរួចក៏ថ្លាយទឹកពេញវិញ។ កុម្ភណ្ឌបាននិម្មិតជាផ្លែផល្វាច្រើន ហើយចូលទៅពួនក្រោមស្ពាន ដើម្បីបំផ្លាញពលស្វា។

- **យុទ្ធសាស្ត្របំបាក់ទឹកចិត្ត** ៖

រាពណ៍ឱ្យបុញ្ញកាយជាក្មួយស្រី កាឡាខ្លួនជាសីតាស្លាប់អណ្ដែតទឹកទៅជិតព្រះពន្លាព្រះរាម ដើម្បីឱ្យព្រះរាមអស់ទឹកចិត្តនឹងប្រយុទ្ធតទៅទៀតព្រោះសីតាស្លាប់ហើយ ព្រះរាមនឹងដកទ័ពថយវិញ។ ម្យ៉ាងទៀត នាងសុកាចាបានកាឡាខ្លួនជាសីតាទៅធ្វើសង្គ្រាមជាមួយកុម្ភណ្ឌដោយឱ្យកុម្ភណ្ឌប្រាប់ស្រីលក្សណ៍ថា *"ពឹងមកប្រយុទ្ធធ្វើអ្វី បើសីតាត្រូវស្លាប់ថ្ងៃនេះហើយ។"* សម្ដីនេះធ្វើឱ្យស្រីលក្សណ៍លែងចង់ប្រយុទ្ធ ហើយរាពណ៍បញ្ជិះសីតាលើរាជរថមកមុខព្រះពន្លាដើម្បីបញ្ឈឺចិត្តព្រះរាម។

- **យុទ្ធសាស្ត្រយកស្រីធ្វើជានាង** ៖

ឥន្ទ្រជិតបានហោះទៅឋានព្រះឥន្ទ្រ ហើយក្លែងខ្លួនជា ព្រះឥន្ទ្រនាំស្រីទេពមករាំលេង ដើម្បីឱ្យព្រះលក្ស្មណ៍ទតភ្លេចខ្លួន ងាយស្រួលនឹងកម្ចាត់ព្រះលក្ស្មណ៍។

- **យុទ្ធសាស្ត្របំភាន់ស្មារតី** ៖

ឥន្ទ្រជិតបានឱ្យក្រុមយក្សក្លែងជាស្រីទេពកញ្ញាមករាំឱ្យព្រះលក្ស្មណ៍មើលក្នុងពេលចេញច្បាំង។ ព្រះលក្ស្មណ៍មើលភ្លេចខ្លួន ឥន្ទ្រជិតក៏ថ្លែងសរត្រូវព្រះលក្ស្មណ៍បាន។ ម្យ៉ាងវិញទៀត នៅពេលដែលអង្គទដឹងថា ពួកយក្សមានបំណងចង់សម្លាប់ខ្លួន អង្គទក៏ស្រែកសន្ធាប់ឡើងឱ្យឮយ៉ាងខ្លាំង ធ្វើឱ្យពួកយក្សភ័យភាន់ភាំងស្មារតីចាក់សម្លាប់គ្នាឯង ។

- **យុទ្ធសាស្ត្រចុះចូលជាមួយសត្រូវដើម្បីស៊ើបការណ៍ពីសត្រូវ** ៖

ហនុមាន និងអង្គទបានកាឡាខ្លួនជាស្វាតូចចូលទៅសុំសែងព្រះអាទិត្យនៅជាមួយ ហើយសែងព្រះអាទិត្យក៏ព្រមទទួលស្វាទាំងពីរឱ្យនៅជាមួយ ដែលទីបំផុតស្វាទាំងពីរក៏អាចសម្លាប់សែងព្រះអាទិត្យបាន។ ក្រោយមក ហនុមានបានកាឡាខ្លួនជាកូនស្វាសុំវាពណ៍នៅជាមួយ ដើម្បីស៊ើបឱ្យដឹងថា តើវាពណ៍លាក់ដួងកែវនៅទីណា?

ដូច្នេះតាមការបកស្រាយបង្ហាញអំពីយុទ្ធសាស្ត្រនានាក្នុងការធ្វើសឹកសង្គ្រាមនៅក្នុងរឿងរាមកេរ្តិ៍ខាងលើនេះ អាចជាប្រយោជន៍សម្រាប់អ្នកអាន អ្នកសិក្សា យកមកត្រិះរិះ ពិចារណា ឬក៏យកជាគំរូក្នុងការធ្វើសង្គ្រាមបង្ក្រាបសត្រូវ។

## គ - តម្លៃឆ្លុះបញ្ចាំងពីយុទ្ធវិធីគ្រប់គ្រងប្រទេស

ការដឹកនាំ ឬ ការគ្រប់គ្រងប្រទេស គឺជាកត្តាមួយដ៏សំខាន់ដែលបុគ្គលគ្រប់រូបត្រូវតែយកចិត្តទុកដាក់ ព្រោះបើសិនជាបុគ្គលអ្នកដឹកនាំមិនដឹង មិនស្គាល់ មិនយល់ឱ្យច្បាស់ពីតួនាទីរបស់ខ្លួន មិនប្រណិបត្តិខ្លួនឱ្យល្អ ជាពិសេសមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងទេនោះ នោះការដឹកនាំសហគមន៍ ស្ថាប័ន ឬ សង្គមជាតិ នឹងធ្លាក់ទៅក្នុងហិនភាពជាក់ជាមិនខាន។

យ៉ាងណាមិញតាមរយៈរឿងរាមកេរ្តិ៍ខ្មែរ អ្នកនិពន្ធក៏បានឆ្លុះបញ្ចាំងពីតម្លៃនៃភាពជាអ្នកដឹកនាំ ឬ អ្នកគ្រប់គ្រងឱ្យយើងបានឃើញផងដែរដូចជា៖

- **ព្រហ្មវិហារធម៌ទាំង៤** (**មេត្តា ករុណា មុទិតា ឧបេក្ខា**)៖

អ្នកដឹកនាំត្រូវចេះការប្រកាន់ខ្ជាប់នូវព្រហ្មវិហារធម៌ទាំង៤ ដោយចាត់ទុកអ្នកនៅក្នុងសហគមន៍ ក្នុងស្ថាប័នឬក្នុងប្រទេស គឺជាកូនជាចៅរបស់យើង ដោយផ្តល់នូវសេចក្តីអាណិតស្រឡាញ់ ទទួលខុសត្រូវ និង ឈរលើគោលការណ៍គតិយុត្ត។ លក្ខណៈនៃអ្នកដឹកនាំប្រភេទនេះក៏បានឆ្លុះបញ្ចាំងបង្ហាញឱ្យយើងឃើញនៅក្នុងរឿងរាមកេរ្តិ៍ខ្មែរផងដែរ។ តាមរយៈតួអង្គ*ព្រះបាទទសរថ* ទ្រង់ជាបុគ្គលអ្នកដឹកនាំមួយរូបដែលប្រកាន់ខ្ជាប់នូវព្រហ្មវិហារធម៌ទាំង៤ ហើយ

ដែលអាណាប្រជានុរាស្ត្រគោរពស្រឡាញ់ និងគាំទ្ររាល់ទង្វើ និងសកម្មភាពរបស់ព្រះអង្គ ជាពិសេស គឺនៅពេលដែលព្រះអង្គដោះស្រាយវិបត្តិទំនាស់ដែលកើតមានក្នុងរាជវង្សានុវង្សរបស់ទ្រង់ ដោយសារការសន្យារបស់ទ្រង់ជាមួយមហេសីកៃកេសី គឺទ្រង់ចង់បែងចែកនគរ និងរាជសម្បត្តិជាពីរចំណែក ដើម្បីឱ្យទៅព្រះរាមគ្រប់គ្រងមួយចំណែក និងឱ្យទៅព្រះភិរុតគ្រប់គ្រងមួយចំណែក។ មានន័យ ថាព្រះបាទទសរថ ទ្រង់ចង់ដោះស្រាយបញ្ហាវិបត្តិនោះដោយឧបេក្ខាការមិនលម្អៀង ដើម្បីកុំឱ្យខូចពាក្យសត្យរបស់ទ្រង់ផង និងកុំឱ្យខូចរាជប្រវេណីផង។ តែបំណងនេះត្រូវមហេសីកៃកេសីជំទាស់យ៉ាងដាច់អហង្ការ។ ចំណុចនេះ ប្រសិនបើព្រះបាទទសរថទ្រង់មិនមែនជាក្សត្រប្រកាន់ខ្ជាប់នូវព្រហ្មវិហារធម៌ និងមិនមែនជាក្សត្រប្រកបដោយទសពិតរាជធម៌ទេនោះ ប្រហែលជាទ្រង់ប្រើអំណាចរបស់ទ្រង់មកដោះស្រាយបញ្ហាដោយឆន្ទានុសិទ្ធិរបស់ទ្រង់ ហើយនឹងដាក់សម្ពាធ ឬទណ្ឌកម្មផ្សេងៗលើនាងកៃកេសីបាត់ទៅហើយ តែនេះទ្រង់ជាក្សត្រប្រកបដោយសច្ចៈ មានយុត្តិធម៌ និងមានគតិបណ្ឌិត ព្រោះបើទ្រង់ប្រើអំណាច ទ្រង់នឹងខូចតម្លៃដោយបំពានលើសម្ដីខ្លួនឯង ជាពិសេសគឺបាត់បង់នូវកិត្តិយសរបស់ទ្រង់។

*"ព្រះទសរថរាជឆ្លើយស្ដង    ថាឱ្យនាងហោង    គឺមោះអញសូមពីនាណា។*
*នាព្រះនគរស្រីឦយុធ្យា    នេះអញបងជា    ភាគពីររំលែកចេញហោង។*
*ឱ្យព្រះរាជបុត្រច្បង    នូវព្រះភិតគ្រង    ឱ្យគង់ដូចសត្យប្ដេជ្ញា។"*

(វឌ្ឍនាយាវង្ស ***រាមកេរ្តិ៍ខ្មែរទី១*** ទំព័រ៣៧)

ម្យ៉ាងវិញទៀត តាមរយៈតួអង្គព្រះរាមដែលទ្រង់រាប់អានកូខ័នជាព្រានប្រមាញ់ ដោយទុកដូចជាសាច់ញាតិស្មើឯកឧទរនោះ បានបង្ហាញឱ្យឃើញពីទឹកព្រះទ័យពោរពេញទៅដោយមនុស្សធម៌ មិនប្រកាន់វណ្ណៈឬឋានៈ ដែលអាកប្បកិរិយារបស់អ្នកគ្រប់គ្រងបែបនេះ រមែងជាទីពេញចិត្តរបស់មហាជនទូទៅ តែក៏ជាការមិនពេញចិត្តចំពោះអ្នកប្រកាន់វណ្ណៈដែរ គឺគេអាចបន្ទោសព្រះរាមថា មិនគួររាប់អានមនុស្សព្រៃ មានត្រកូលទាបដូចជាបងប្អូនឡើយ គួរណាស់តែទុកកូខ័នត្រឹមតែជាខ្ញុំបម្រើ ឬជាសេនាបានហើយ ហើយដែលទង្វើនៃក្រុមមនុស្សប្រភេទនេះជាទង្វើអមនុស្សធម៌ អយុត្តិធម៌ អសីលធម៌ ដែលសង្គមស្អប់ខ្ពើម និងមិនគួរយកមកអនុវត្តក្នុងសង្គមមនុស្សឡើយ ព្រោះទោះជាយ៉ាងណាក្ដី ទាំងព្រះរាម ទាំងកូខ័នមនុស្សព្រៃ គឺសុទ្ធសឹងតែជាមនុស្សដូចគ្នា កើតចេញពីមាតាបិតាមនុស្សដូចគ្នា ចង់មាន ចង់បាន ចង់សុខចម្រើន មានតម្រូវការ និងមានសេចក្ដីស្រេកឃ្លានដូចគ្នា។ ដូច្នេះកាលដែលព្រះរាម រាប់អានកូខ័នជាមនុស្សជាតិដូចគ្នា វាមិននាំឱ្យព្រះរាមថោកទាប ឬក៏ខូចខាតផលប្រយោជន៍អ្វីទេ តាមពិត មានតែនាំឱ្យព្រះរាមរឹតតែមានព្រះកិត្តិយស និងសក្តិសមជាបុគ្គលដឹកនាំដ៏ឆ្នើមថែមទៀត។

*"ស្ដេចស្ដាប់កូខ័នទូលស្មោះ    ពាក្យពិតពីរោះ    នូវគុណសប្បុរសមោះហិមា។*

*ទើបស្តេចបន្ទូលត្រាស់ថា ហៃកូខ័នបា មហាមានគុណឥតប្រមាណ ។*
*សមបាជាញាតិពីបូរាណ អញអធិស្ឋាន បាងង់ស្មើឯកឧទរ ។*
*នាយើងចេញចាកព្រះនគរ ត្រចព្រៃពនេចរ មកជួបនឹងនានេះឥឡូវ ។*
*សប្បុរសគុណបាឥតគូ ឥតអ្នកឯណានូវ មកផ្ទឹមគុណបាដ៏កន្លង ។*
*អង្គអញឯងជាច្បង អណ្តាប់បាហោង ព្រះលក្សណ៍ជាប្អូនពៅបា ។"*

(វឌ្ឍឆាយាវង្ស ***រាមកេរ្តិ៍ខ្មែរទី១*** ទំព័រ៦០-៦១)

មិនត្រឹមតែការរាប់អានកូខ័នតែប៉ុណ្ណោះទេ ព្រះរាមនៅមានភាពសន្តោស ភាពមេត្តា និង ករុណារបស់ទ្រង់ជាច្រើនទៀត សម្រាប់ជាសក្ខីភាពបង្ហាញនូវទង្វើល្អរបស់បុគ្គលអ្នកដឹកនាំ គ្រប់គ្រងផងដែរ ដូចជាព្រះរាមចេះអត់ឱនឱ្យសត្រូវ មិនប្រកាន់ទោសអូសដំណើរក្នុងអំពើ ឈ្លានពានពីសំណាក់រាមបរមសូរ ដែលនេះជាលក្ខណៈមួយដ៏ល្អប្រសើររបស់ព្រះរាមក្នុងការ អត់ឱនទោសប្រទានជីវិតដល់សត្រូវនៅក្នុងកាលៈទេសៈ ឬ ហេតុការណ៍ដែលគួរអត់ឱន ។

រីឯតាមរយៈលក្ខណៈ និងសកម្មភាពរបស់***ព្រះបាទជនក*** ក៏បានបង្ហាញថាទ្រង់ជាក្សត្រ ប្រកបដោយទសពិតរាជធម៌ ប្រព្រឹត្តតាមបុរាណរាជប្រពៃណី យាងធ្វើពិធីច្រត់ព្រះនង្គ័លដើម្បី បន់ស្រន់សុំទឹកភ្លៀងឱ្យកសិករប្រកបរបរកសិកម្ម ដែលបង្ហាញពីការយកចិត្តទុកដាក់ប្រកប ដោយក្តីមេត្តា ករុណា ចំពោះប្រជាពលរដ្ឋរបស់ទ្រង់ ហើយតាមរយៈសកម្មភាពដែលទ្រង់ទត ឃើញសុវណ្ណពោងពាយដែលមានទារិកាតូចនៅក្នុងនោះ ទ្រង់បានរើសយកទៅចិញ្ចឹមដោយ មិនគិតដល់ពូជពង្សវង្សត្រកូល មិនគិតពីបុព្វហេតុដែលនាំឱ្យគេបោះបង់ទារិកានោះ គឺរឹតតែ បានបង្ហាញពីលក្ខណៈមនុស្សធម៌ដ៏ពិតប្រាកដរបស់ទ្រង់ថែមទៀត ពោលគឺទ្រង់មានព្រះទ័យ ករុណាចំពោះមនុស្សជាតិដូចគ្នាដែលលក្ខណៈនៃការផ្តល់តម្លៃ នេះគួរតែអ្នកដឹកនាំគ្រប់គ្រង គ្រប់រូបប្រកាន់ឱ្យបានខ្ជាប់ និងទុកជាគំរូ ។

*"ដងនោះព្រះបាទមិថិលា ស្តេចធ្វើចរិយា បីដោយនូវក្រឹត្យដ៏ពិធី ។*
*លុះពិសាខសុភតិត្ថិ ផ្ទុំមុខមន្ត្រី ប្រយោជន៍នូវប្រែពសុធា ។*
*ដើម្បីនូវធ្វើឱ្យក្សេមប្រជា រាស្ត្ររដ្ឋដោយនា ក្រិតាធិការដ៏បុរាណ ។*
*ស្តេចទ្រង់នង្គ័លបាសមាន ព្រះឧសភរាជប៊ិរូបហាន ដំណើរសីហានាទលេលា ។*

*.................................... ........................... ............................*

*ដងនោះឥសូរមិថិលា រៀបរាជយោធា នូវថ្វាត់នឹងថ្កានព្រះនគរ ។*
*នៅរាជកញ្ញាសុបវរ ស្មើបុត្រដ៏ឧទរ ក៏លុះលើរាជពិភព ។"*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី១ ទំព័រ៥-៦)

យ៉ាងណាមិញ តាមរយៈសកម្មភាពរបស់***ព្រះភិរុត*** ទ្រង់ជាក្សត្រមួយអង្គមិនមានភាពលោភលន់រាជសម្បត្តិ ហើយថែមទាំងប្រកាន់នូវសច្ចធម៌ទៀតផង គឺទ្រង់បានទៅតាមសុំយាងព្រះរាមឱ្យមកគ្រងរាជ្យវិញដោយមិនគាំទ្រនូវទង្វើរបស់នាងកៃកេសីជាមាតាឡើយ ដែលនេះជាការប្រកាន់ខ្ជាប់ខ្ជួននូវព្រហ្មវិហាធម៌ ក៏ដូចជាប្រវេណីរបស់ប្រទេស និងរាជវង្សានុវង្សរបស់ទ្រង់ផងដែរ ដែលទឹកព្រះទ័យរបស់ព្រះភិរុតនេះជាទឹកព្រះទ័យល្អកម្រកបាននៅក្នុងសង្គមមនុស្សបច្ចុប្បន្ន ព្រោះបច្ចុប្បន្នដើម្បីទ្រព្យសម្បត្តិ ដើម្បីអំណាច ដើម្បីបំពេញនូវចំណង់របស់ខ្លួនបុគ្គលមួយចំនួនបានខិតខំប្រឹងប្រែងស្រវាស្រទេញដោយ ឥតអៀនខ្មាស ធ្វើយ៉ាងណាឱ្យតែខ្លួនមានអំណាច ធ្វើយ៉ាងណាឱ្យតែខ្លួនមានទ្រព្យ រហូតដល់ពេលខ្លះបងប្អូនសម្លាប់គ្នា កូនសម្លាប់ឪពុកម្តាយក៏មាន។ រីឯព្រះភិរុតមិនដូច្នោះទេ គឺទ្រង់សុខចិត្តធ្វើដំណើរទៅតាមព្រះរាមដល់ក្នុងព្រៃ សូម្បីតែកូខ័ន និងព្រះលក្សណ៍ក៏មិនជឿនូវទឹកព្រះទ័យរបស់ទ្រង់ដែរ គឺទាំងកូខ័ន ទាំងព្រះលក្សណ៍ គ្រាន់តែឃើញក្បួនដង្ហែរបស់ទ្រង់គឺសុទ្ធតែយល់ថាទ្រង់លើកទ័ពមកតាមសម្លាប់ព្រះរាម ដោយនឹកខ្លាចព្រះរាមត្រឡប់ទៅដណ្តើមរាជ្យវិញ។ តែតាមការពិតវាផ្ទុយស្រឡះដែលទង្វើនេះ ធ្វើឱ្យកូខ័នសរសើរពីទឹកចិត្តរបស់ទ្រង់ពេកកន្លង។

*“ដងនោះកូខ័នអក្កាត់ ត្រួញក្រាបប្រតិបត្តិ បង្គំក្រាបក្រោមបាទា។*
*សរសើរព្រះភិរុតថា ប្រាសលែងលោភា ឆន្ទៈមោហោះភ័យផង។*
*ពាក្យពិតទេទៀងឥតឆ្គង ដើរដោយនូវគន្លង ព្រះធម៌អារ្យសត្យសព្វ។*
*នាស្តេចមកយកគោរព ប្រតិបត្តិអង្គអ- ភិវាទអញ្ជើញព្រះបង។”*

(វឌ្ឍឆាយាវង្ស ***រាមកេរ្តិ៍ខ្សែទី២*** ទំព័រ៦៧)

ដូច្នេះ ការប្រកាន់ខ្ជាប់នូវព្រហ្មវិហារធម៌ គឺជាកត្តាសំខាន់ណាស់សម្រាប់អ្នកដឹកនាំ ឬអ្នកគ្រប់គ្រង ព្រោះបើអ្នកដឹកនាំ ឬអ្នកគ្រប់គ្រងបាត់បង់នូវព្រហ្មវិហារធម៌ហើយនោះ បុគ្គលនោះនឹងក្លាយទៅជាបុគ្គលដែលសាហាវឃោរឃៅខ្វះក្តីមេត្តា ករុណា មុទិតា និង ឧបេក្ខានៅក្នុងខ្លួន តួយ៉ាងដូចជានៅជិតចុងបញ្ចប់នៃរឿង ព្រះរាមបានក្លាយទៅជាអ្នកគ្រប់គ្រងដែលប្រាស់ចាកនូវព្រហ្មវិហារធម៌ដោយទ្រង់បញ្ជាឱ្យគេយករាមលក្សណ៍ដែលជាក្មេងតូច ទៅធ្វើទោសដាក់ទណ្ឌកម្ម បណ្តើរអាក្រោសជុំវិញនគរ ហើយយកទៅសម្លាប់ជាដើម។ ដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់***វឌ្ឍឆាយាវង្ស*** ខ្សែទី៧៧ ទំព័រ២៧-២៨ បានបញ្ជាក់ថា៖

*“...កាលអើយកាលនោះ ព្រះនារាយណ៍រឹងឫទ្ធិថ្កើងថ្កល់*
*ស្តាប់ព្រះអនុជនិមល ក្រេវក្រោធទុំទាំងភក្ត្រា។*
*ហើយទើបព្រះបាទបពិត្រ មានព្រះកំហិតត្រាស់ថា*
*រ័យអស់មន្ត្រីសេនា អាមាត្យទាហានទីទៃ។*

*អានេះចិត្តចោរហាវហាន ទុកវាពុំបានឡើយនែ*
*ចូរយកចេញទៅវៃៗ ធ្វើទុក្ខឱ្យរងវេទនា។*
*ដាក់ក្តីទាំងប្រាំប្រការ ហើយឱ្យភ្នាក់ងារនៅវា*
*ក្រវែលជុំព្រះនគរា អាក្រោសប្រាប់អស់អ្នកផង។*
*ហើយដាក់ទ្រុងទុកបីថ្ងៃ កុំអាលឱ្យក្ស័យឡើយហោង*
*ស្រេចឱ្យពេជ្រឃាត់ផង់ យកទៅផ្តិលផ្តាច់ជីវី។...”*

- **ពង្រីកចំណេះដឹង ពង្រឹងសមត្ថភាព ៖**

អ្នកដឹកនាំគ្រប់គ្រង ត្រូវចេះពង្រីកចំណេះដឹង និងពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែមនៅពេលដែលដឹងថាខ្លួន និងសហការីមានចំណុចខ្វះខាត។ ការដែលព្រះបាទទសរថឱ្យបុត្រទៅរៀនសិល្ប៍សាស្ត្រជាមួយឥសី បានបង្ហាញពីភាពទទួលខុសត្រូវមួយក្នុងភាពជាអ្នកដឹកនាំ។ មានន័យថា ក្នុងនាមជាអ្នកដឹកនាំ គឺត្រូវតែមានចំណេះដឹង និងមានសមត្ថភាពពិតប្រាកដដូច្នេះទោះបីជាទ្រង់ជ្រាបថា ការឱ្យបុត្រទៅរៀនវិជ្ជាសិល្ប៍សាស្ត្រនៅនឹងឥសីក្នុងព្រៃត្រូវមានជីវិតតស៊ូលំបាកក៏ដោយ ក៏ទ្រង់នៅតែឱ្យបុត្រទៅរៀន ព្រោះថាបុគ្គលម្នាក់ៗបើគ្មានវិជ្ជាសិល្ប៍សាស្ត្រ បុគ្គលនោះមិនអាចនាំនាវាជីវិតជួបប្រទះនូវសុភមង្គលបានឡើយ។ ម្យ៉ាងវិញទៀតជីវិតរបស់មនុស្សម្នាក់ៗតែងតែប្រែប្រួលមិនទៀងជួនសុខ ជួនទុក្ខ វាជារឿងធម្មតារបស់មនុស្សលោកមិនមានបុគ្គលណាម្នាក់ដែលមានតែភាពស្រណុកសុខស្រួល សម្បូរសប្បាយមិនដែលស្គាល់ទុក្ខលំបាកនោះឡើយ។ ដូច្នេះការដែលព្រះបាទទសរថឱ្យបុត្រទៅរៀនសិល្ប៍សាស្ត្រ គឺទ្រង់មានបំណងចង់ឱ្យបុត្រមានចំណេះដឹង និង ចង់ឱ្យបុត្រជួបប្រទះនូវការលំបាកខ្លះៗ ដើម្បីឱ្យរាងកាយរបស់បុត្រស្គាល់រសជាតិជីវិតពិតប្រាកដរបស់មនុស្ស ពោលគឺការកើតមកជាមនុស្សត្រូវចេះស្វែងរកភាពរុងរឿងថ្កើងថ្កានសម្រាប់ជីវិត ព្រោះចំណេះវិជ្ជាគឺជាទ្រព្យដ៏ប្រសើរ តួយ៉ាងដូចជា លទ្ធផលនៃការសិក្សាដែលព្រះរាមទទួលបានក្រោយពីបានទៅហាត់រៀនសិល្ប៍សាស្ត្រជាមួយឥសីពិស្វាមិត្រនោះ គឺព្រះរាមអាចទទួលជ័យជម្នះលើកាកនាសូរ និងរាមបរមសូរបានដោយងាយ ជាពិសេសព្រះរាមបានទទួលជ័យជម្នះដ៏ធំធេង គឺអាចលើកធ្នូសរប្រកួតយកសីតាមកអភិសេកបាន។ ម្យ៉ាងវិញទៀត តាមរយៈតួអង្គរាមលក្ស្មណ៍ ជប្បលក្ស្មណ៍ ដោយសារតែការខិតខំសិក្សារៀនសូត្រនូវរាល់សិល្ប៍សាស្ត្រ ធ្វើឱ្យកុមារទាំងពីរអាចយកឈ្នះលើហនុមានដែលជាបុគ្គលមួយដ៏ខ្លាំងក្លានៅក្នុងសឹកសង្គ្រាមនាក្រុងលង្កា។

- **មានចិត្តធ្ងន់ និង ចេះអត់ធ្មត់ ៖**

ភាពអត់ធ្មត់ និងការធ្វើចិត្តឱ្យធ្ងន់នេះ ជាកត្តាចាំបាច់ណាស់សម្រាប់អ្នកដឹកនាំគ្រប់គ្រង ព្រោះបើសិនជាអ្នកដឹកនាំគ្រប់គ្រងមិនចេះអត់ធ្មត់ និងមិនចេះធ្វើចិត្តឱ្យធ្ងន់ទេនោះ

នោះការដឹកនាំសហគមន៍ ការដឹកនាំក្រុម ការដឹកនាំស្ថាប័ន ក៏ដូចជាការដឹកនាំប្រទេស មុខតែនឹងនាំសហគមន៍ ក្រុម ស្ថាប័ន និងប្រទេសជាតិឆ្ពោះទៅរកការអាប់ឱនជាក់ជាមិនខាន។ យ៉ាងណាមិញ តាមរយៈរឿងរាមកេរ្តិ៍ ក៏បានលើកឡើងបង្ហាញពីបញ្ហានេះផងដែរដូចជា នៅក្នុងភាពជាអ្នកដឹកនាំ ព្រះរាមមានព្រះហឫទ័យធូន់ណាស់ គឺទ្រង់ចេះអត់ធ្មត់ដែលកម្រមានបុគ្គលណាម្នាក់អាចធ្វើតាមទ្រង់បានណាស់ គឺកាលដែលព្រះបាទទសរថចង់បង្វេររាជសម្បត្តិឱ្យព្រះអង្គ ហើយត្រូវបាននាងកៃកេសីទូលជំទាស់នោះ ដោយឱ្យព្រះបាទទសរថប្រគល់រាជសម្បត្តិទៅឱ្យព្រះភិរុតដែលជាបុត្ររបស់នាងវិញ និងការដែលនាងទូលឱ្យបំបរបង់ព្រះរាមឱ្យទៅនៅព្រៃចំនួន ១៤ឆ្នាំនោះ ក៏ព្រះរាមស្ម័គ្រចិត្តធ្វើដោយមិនមានការខឹងសម្បាអ្វីទាំងអស់ ដែលនេះបញ្ជាក់ឱ្យឃើញថា ព្រះរាមមានទឹកព្រះទ័យធូន់ ចេះអត់ធ្មត់ មិនចង់ឱ្យមានការឈ្លោះទាស់ទែងគ្នាដោយបញ្ហារាជ្យបល្ល័ង្ក ដែលហេតុការណ៍នេះ សូម្បីតែព្រះលក្សណ៍ ក៏ទ្រង់ចង់ដកព្រះខ័នទៅប្រហារនាងកៃកេសីដែរ ដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់ វឌ្ឍនាយាវង្ស ខ្សែទី២ ទំព័រ៣៩ បានបញ្ជាក់ថា៖

| | | |
|---|---|---|
| *“ក្សិណព្ទុដល់ព្រះរាមា* | *នូវព្រះលក្សា* | *ធិរាជដ៏ពីរចក្រី។* |
| *ព្រះលក្ខណ៍ស្តេចក្រោធឡើងខ្មី* | *ដាលដូចអគ្គី* | *ក៏ទ្រង់ព្រះខ័នពេជ្រថ្លា។* |
| *ប៉ងនូវពិឃាតជន្មា* | *ព្រះវរមាតា* | *គឺនាមនាងកៃកេសី។* |
| *ទើបព្រះរាមទេពធិបតី* | *ព្រះឱស្ឋប្រិមប្រិយ៍* | *ឃាត់ព្រះអនុជលក្សា។* |
| *ថាហៃវរលក្ខណ៍កុំបីបា* | *គិតចងទាសា* | *នឹងអ្នកដ៏មានគុណថ្លៃ។* |
| *អំពើនោះបាបធ្ងន់ក្រៃ* | *កុំធ្វើឆ្ពោះនៃ* | *ចូរបារំសាយក្រោធា។”* |

- **ស្គាល់ចិត្តសាស្ត្រអ្នកនៅក្រោមឱវាទ** ៖

ការស្គាល់ពីទឹកចិត្ត(ស្គាល់សុខ ស្គាល់ទុក្ខ ស្គាល់ការលំបាកនឿយហត់) របស់សហការីក្រោមឱវាទក៏ជាការសំខាន់ និងចាំបាច់សម្រាប់អ្នកដឹកនាំគ្រប់គ្រងដែរ ព្រោះការស្គាល់ចិត្តគ្នានេះវាជាកាតាលីករជួយជំរុញការងារឱ្យបានល្អ និងឈានទៅរកភាពជោគជ័យសម្រាប់ការងារ ពោលគឺមិនធ្វើឱ្យខូច ឬធ្លោយការងារ។ កាលណាអ្នកដឹកនាំគ្រប់គ្រងមិនស្គាល់ចិត្តអ្នកក្រោមបង្គាប់ទេនោះ ជួនកាលការងារនោះវាខុសទិសដៅដែលអ្នកដឹកនាំចង់បាន ឬក៏ខុសកាលខុសវេលាជាដើម។ តួយ៉ាងដូចជាព្រះរាម ពេលដឹងថាកងទ័ពមានការនឿយហត់ដោយសារការជញ្ជូនថ្មភ្នំមកធ្វើជាស្ពានសម្រាប់ឆ្លងទៅលង្កា ទ្រង់ក៏ឱ្យកងទ័ពឈប់សម្រាកខ្លះ ដោយទ្រង់មិនបង្ខំទាំងទទឹងទិសតាមទំហំនៃការចង់បានរបស់ទ្រង់ឡើយ ពោលគឺទ្រង់មិនអាងលើអំណាចរបស់ទ្រង់គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួនទោះបីជានរណាស្លាប់ក៏ស្លាប់ចុះនោះឡើយ ដែលលក្ខណៈបែបនេះជាទីពេញចិត្តបណ្ឌិត ក៏ដូចជាជនទូទៅ និងអ្នកនៅក្រោមឱវាទរបស់ខ្លួន ដែល

ទង្វើនេះវាផ្ទុយស្រឡះពីក្រុងរាពណ៍ដែលជាអ្នកដឹកនាំម្នាក់ដែលមិនស្គាល់ពីចិត្តសាស្ត្ររបស់អ្នកនៅក្រោមឱវាទ ដោយខឹងភ្លែតវាយប្រហារភ្លាម មិនគិតមុខ មិនគិតក្រោយ ធ្វើអ្វីតាមតែទង្វើចិត្តរបស់ខ្លួន អាងតែខ្លួនមានអំណាច អាងខ្លួនជាអ្នកដឹកនាំក៏ស្ដីបន្ទោសតែម្ដង។ ជាក់ស្ដែងដូចជារាពណ៍បានស្ដីឱ្យ និងវាយក្បាលពិភេកនឹងស្បែកជើងនៅមុខចំណោមសេនា មន្ត្រី ដែលទង្វើនេះឱ្យពិភេកនឹកខ្មាស់គេផង ខឹងនឹងបងផង ក៏នឹកតូចចិត្តហើយរត់ទៅសុំចុះចូលខាងសត្រូវដែលនាំឱ្យខូចប្រយោជន៍ជាតិយ៉ាងច្រើន ព្រោះពិភេកជាបុគ្គលមួយរូបដែលមានសមត្ថភាព ដឹងអស់កិច្ចការផ្ទៃក្នុងរបស់ជាតិ។ ដូច្នេះអ្នកដឹកនាំគួរចងចាំថា អ្នកតូចទាបកម្រិតណាក៏គេមានកិត្តិយសរបស់គេដែរ ហើយអ្នកដឹកនាំគ្រប់គ្រងគួរតែស្វែងយល់ពីទឹកចិត្តរបស់អ្នកនៅក្រោមឱវាទឱ្យបានច្រើនទើបការដឹកនាំនោះទទួលជោគជ័យ។

- **ចេះវិធីសាស្ត្រទំនាក់ទំនងមនុស្ស និងចងមិត្ត ៖**

ស្គាល់កាលៈទេសៈក្នុងការទំនាក់ទំនងក៏ដូចជា ការប្រើសហការីឱ្យបំពេញភារកិច្ចអ្វីមួយ។ តួយ៉ាងដូចជា នៅពេលដែលបានជួបជាមួយនឹងហនុមាន និងសុគ្រីព ព្រះរាមបានចងសម្ព័ន្ធមិត្តនឹងសុគ្រីព ដើម្បីជួយបំពេញបំណងគ្នាទៅវិញទៅមក គឺព្រះរាមសុខចិត្តបំពេញចិត្តសុគ្រីព ដោយអភិសេកសុគ្រីពឱ្យគ្រប់គ្រងខាស់ខិនបុរី និងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់នគរសុគ្រីពទេ ដែលនេះសឱ្យឃើញថា ព្រះអង្គមិនត្រូវការខាស់ខិនបុរីជាអាណានិគមរបស់ទ្រង់នោះឡើយ គឺទ្រង់ចង់ឱ្យសុគ្រីពជួយព្រះអង្គវិញក្នុងឋានៈជាមិត្តជួយគ្នាទៅវិញទៅមកតែប៉ុណ្ណោះ។

ព្រះរាម តំណាងឱ្យអ្នកគ្រប់គ្រងម្នាក់ដែលស្គាល់កាលៈទេសៈក្នុងការប្រើសហការីឱ្យទៅទំនាក់ទំនងសុំជំនួយទ័ពពីមហាជម្ពូ ដោយព្រះរាមមិនឱ្យហនុមានទៅតែម្នាក់ឯងទេ គឺទ្រង់ឱ្យអង្គត់ទៅជាមួយ ព្រោះហនុមានជាបុគ្គលម្នាក់ដែលមានចិត្តឆេវឆាវ ធ្វើកិច្ចការអ្វីៗមិនសូវចេះអត់ធ្មត់ ខ្លាចខូចការ។

ការចងមិត្ត ការបង្កើនកម្លាំងទ័ពក្នុងការធ្វើចម្បាំង គឺជាការចងសម្ព័ន្ធភាពនៃកម្លាំងច្រើនរួមគ្នា វាអាចធ្វើឱ្យយើងទទួលបាននូវជ័យជម្នះអ្វីមួយដែលយើងប៉ងធ្វើ។ យ៉ាងណាមិញ ព្រះរាមដែលជាតួអង្គខ្លាំងតំណាងឱ្យអវតារព្រះវិស្ណុនោះ ទ្រង់ក៏បានឱ្យតម្លៃទៅលើការចងមិត្តព្រោះទ្រង់បានគិតថាមានតែការចងមិត្តជិតឆ្ងាយឱ្យជួយជាកម្លាំងទេ ទើបអាចភ្លៀងរម្លាយលង្កាបាន។

- **មិនគំរាមកំហែង និងមិនបៀតបៀនអ្នកដទៃ ៖**

ក្នុងភាពជាអ្នកដឹកនាំ បុគ្គលគ្រប់រូបគួរតែចៀសឱ្យបានពីការគំរាមកំហែង បៀតបៀន ឈ្លានពានលើអ្នកជិតខាងក៏ដូចជាអ្នកដទៃ ហើយបើចង់ធ្វើកិច្ចការអ្វីដែលមានការប៉ះពាល់ជាមួយអ្នកជិតខាង ឬអ្នកដទៃនោះ គួរណាស់តែអ្នកដឹកនាំផ្ដល់ដំណឹង និងសុំការអនុញ្ញាតពី

គ្នាទៅវិញទៅមកទើបជាការគាប់ប្រសើរ។ យ៉ាងណាមិញ តាមរយៈសកម្មភាពក្នុងការកសាងផ្លូវគមនាគមន៍របស់ព្រះរាមដែលជួបនឹងឧបសគ្គដោយសារហ្វូងត្រីនាំគ្នាជញ្ជូនថ្មភ្នំចេញនោះ គឺជាកំហុសរបស់ព្រះរាម ព្រោះទ្រង់ជាអ្នកដឹកនាំ ទ្រង់ជាអ្នកមានអំណាច តែទ្រង់ទៅជ្រៀតជ្រែកលើព្រំដែនទឹករបស់ត្រីដោយមិនមានការផ្តល់ជាព័ត៌មានដល់នាងទេពធីតាមេខល្លា ដែលជាអ្នកត្រួតត្រាថែរក្សាសមុទ្រជាមុន តែនេះទ្រង់បែរជាប្រើពួកពលស្វាឱ្យជញ្ជូនថ្មភ្នំទៅទម្លាក់ក្នុងក្តាំង ឃាំងផ្លូវទៅមករបស់ត្រី និងបង្កឱ្យមានការភិតភ័យដល់ហ្វូងត្រីថែមទៀត។ ទង្វើទាំងនេះគួរណាស់តែព្រះរាមធ្វើទៅតាមច្បាប់ទម្លាប់ឱ្យបានត្រឹមត្រូវ មិនគួរណាព្រះរាមទៅឈ្លានពានដែនទឹករបស់ត្រីយ៉ាងដូច្នេះទេ ព្រោះហ្វូងត្រីមិនបានធ្វើអ្វីឱ្យប៉ះពាល់ដល់ព្រះរាមឡើយ។ ម្យ៉ាងវិញទៀត នៅពេលដែលដឹងថាហ្វូងត្រីនាំគ្នាជញ្ជូនថ្មភ្នំចេញ គួរណាស់តែព្រះរាមរកវិធីដោះស្រាយឱ្យសក្តិសម តែនេះព្រះរាមបែរយកវិធីគំរាមកំហែងមកដោះស្រាយទៅវិញ ពោលគឺព្រះរាមមិនស្គាល់ពីកំហុសរបស់ខ្លួនទេ ហើយបែរជាព្រះអង្គខ្ចាល់ក៏ចង់ថ្លែងសរអគ្គិវាសប្រាថ្នាឱ្យគោកសមុទ្រ ធ្វើឱ្យហ្វូងត្រីមានការតក់ស្លុតភ័យរន្ធត់មកអង្វរលន់តួសូមទោសទ្រង់ និងធានាជញ្ជូនថ្មសង់ស្ពានថ្វាយទ្រង់វិញ។

- **មិនត្រូវមានគំនិតអាត្មានិយម ៖**

អ្នកដឹកនាំគ្រប់គ្រងមិនត្រូវមានគំនិតអាត្មានិយម គិតតែពីប្រយោជន៍ផ្ទាល់ខ្លួន យកអញនិយមនោះទេ។ បើកាលណាអ្នកដឹកនាំគ្រប់គ្រងគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន មិនគិតពីអ្នកដទៃ នោះបុគ្គលនោះនឹងប្រាសចាកពីព្រហ្មវិហារធម៌ នឹងប្រាសចាកចេញពីលក្ខណៈមនុស្សដែលមិនមានមនោសញ្ចេតនាគិតដល់សេចក្តីសុខ និងទុក្ខរបស់អ្នកដទៃ។ ចូរអ្នកដឹកនាំគ្រប់គ្រងគិតចំពោះអ្នកដទៃឱ្យដូចដែលអ្នកចង់ឱ្យអ្នកដទៃគិតចំពោះខ្លួន។ យ៉ាងណាមិញ តាមរយៈតួអង្គរាពណ៍ រាពណ៍តំណាងឱ្យតួអង្គអ្នកគ្រប់គ្រងពោរពេញទៅដោយកាមតណ្ហា មិនចេះឆ្អែតឆ្អន់នឹងកាមគុណ ប្រើអំណាចផ្តាច់ការ សាហាវ ប្រព្រឹត្តអំពើមិនគប្បីទៅលួចយកទេព្តា និងទេពកញ្ញាទាំងឡាយរាប់ម៉ឺននាក់មកធ្វើជាស្នំបម្រើខ្លួនដោយកាមគុណ ហើយក៏នៅតែមិនគ្រប់គ្រាន់ព្រោះគ្រាន់តែឮនាងសូបនខាទូលពីរូបកាយលោមពណ៌របស់នាងសីតាភ្លាម រាពណ៍ចង់បានភ្លែតដោយមិនគិតពីអាយុជីវិត ឬសុវត្ថិភាពរបស់អ្នកនៅជុំវិញខ្លួនឡើយ ដោយរាពណ៍ប្រើមហារីកឱ្យប្រែកាយជាម្រឹគមាស ដើម្បីជាផ្ទាក់ឱ្យព្រះរាមតាមបាញ់ ទោះជានរណាត្រូវស្លាប់ក៏ស្លាប់ចុះ ឱ្យតែបានប្រយោជន៍ខ្លួន ដែលនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីគំនិតអត្តទត្ថបុគ្គលដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់វឌ្ឍនាយាវង្ស ខ្សែទី៣ ទំព័រ៣៣ បញ្ជាក់ថា៖

*ស្តេចប្រើអាមាត្យមួយនិពទ្ធ ទ្រង់មានប្រសិទ្ធិ៍ ហៅមហារីករតន៍ពណ៌រាយ។*
*ប្រើប្រែរូបអង្គនោមឆាយ ជាម្រឹគពណ៌រាយ ប្រសើរក្រៃលែងម្រឹគ។*

*ថាហៃមហារីកព្រះស្តែងដំណែងរូបា ជាម្រឹគន៏មហា ប្រសើរក្រៃលែងម្រឹគផង ។*
*លល្បួងរាមដ៏សមណ៍ឱ្យបរបាញ់ល្បួង ករកាន់ធនូសរផ្គាប់ផ្គង ចេញលេងអាស្រមឃ្លាតឃ្លា ។*

- **ប្រគល់កិច្ចការឱ្យសហការីធ្វើ ស្តាប់យោបល់គ្នាទៅវិញទៅមក ដោយមិនក្តោបការងារតែម្នាក់ឯង និងមានការទទួលខុសត្រូវ ៖**

គឺជាការកំណត់គោលដៅតម្រង់មនុស្សទៅរកគោលដៅ ផ្តល់សិទ្ធិអំណាច ដល់អ្នកដទៃ ដោះស្រាយ និងគ្រប់គ្រងជម្លោះ ដោយក្តាប់ឱ្យបានពីទំហំការងារ ទាំងភាពងាយស្រួល និងការលំបាក ហើយចេះបែងចែកការងារឱ្យត្រូវទៅតាមជំនាញរបស់សហការី ពោលគឺត្រូវចេះស្តាប់យោបល់គ្នាកុំអាងតែខ្លួនជាអ្នកគ្រប់គ្រង ព្រោះពេលខ្លះយោបល់របស់សហការីជាយោបល់ល្អ ជាយោបល់ត្រូវ អាចនាំខ្លួន និងប្រទេសជាតិឆ្ពោះទៅរកសេចក្តីសុខសុភមង្គលបាន តួយ៉ាងដូចជាព្រះរាម តែងតែស្តាប់តាមការឱ្យយោបល់របស់ពិភេក ថាតើគួរធ្វើអ្វីជាបន្ត? តើត្រូវឱ្យអ្នកណាចេញច្បាំងនាពេលនេះជាដើម ពោលគឺព្រះរាមប្រគល់ភារកិច្ចឱ្យសហការី ហើយទ្រង់មិនមែនចេះតែធ្វើតាមការនឹកឃើញ ឬតាមតែទ្រង់មានអំណាចនោះទេ ដូចជាពេលឃើញយក្សត្រីសិរ ចេញមកសំញែងខែងរែងលើទីប្រយុទ្ធ ព្រះរាមចាប់កៅទ័ណ្ឌចង់ចេញទៅតយុទ្ធ តែត្រូវពិភេកឃាត់ ទ្រង់ក៏ស្តាប់តាមពិភេក ដែលបង្ហាញថា ព្រះរាមជាអ្នកដឹកនាំគ្រប់គ្រងដែលចេះប្រគល់ភារកិច្ច និងផ្តល់តម្លៃដល់សហការីនៅក្នុងការងារអ្វីមួយឱ្យមានភាពទទួលខុសត្រូវ និងចេះស្តាប់គ្នាទៅវិញទៅមក ដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់ **វឌ្ឍឆាយាវង្ស** ខ្សែទី១០ ទំព័រ ២១-២២ បានបញ្ជាក់ថា៖

*ដងនោះព្រះរាមស្តេចស្តែង យល់អសុរដ៏សំញែង សំបើមសម្បារយក្សយង់*
*ព្រះចង់ចេញពះរឿងរង្គ ចាប់ក្រៅទ័ណ្ឌទ្រង់ ពិភេកបង្គំទូលឃាត់ ។*
*បពិត្រពុំគួរមហាក្សត្រ ចេញច្បាំងនឹងគាត់ ជាបុត្រនៃក្រុងរាពណា ។*
*ក្រែងនូវអាប់ព្រះយសចេស្តា ភ្លីព្រះរាម ប្រយុទ្ធនឹងអសុរបុត្រ ។*
*គាត់ដូចភ្លើងភ្លឺប្រាកដ ឆេះឆាបនូវរលត់ រលាយឥឡូវពុំលង់ ។*
*ម្តេចអ្វីព្រួយដល់ព្រះអង្គ សូមស្តេចប្រើពង្ស ពានរដទៃទៅបាន ។*
*ដងនោះព្រះត្រាស់ទៅថ្កាន ថាហៃហនុមាន ឧសភសេនាពង្សពីរ ។*
*ចេញតយុទ្ធយកត្រីស័រ ឃ្នងឈ្នួសមកមី នូវពលអសុរហាវហាន ។*

ដូច្នេះ លក្ខណៈនៃថ្នាក់ដឹកនាំដែលចេះប្រគល់កិច្ចការឱ្យសហការីធ្វើ ស្តាប់យោបល់គ្នាទៅវិញទៅមកដោយមិនក្តោបការងារតែម្នាក់ឯង និងមានការទទួលខុសត្រូវរបៀបព្រះរាមនឹងនាំមកនូវជ័យជម្នះក្នុងការងារយ៉ាងពិតប្រាកដ ដែលផ្ទុយគ្នាស្រឡះពីការការដឹកនាំគ្រប់គ្រងរបស់ក្រុងរាពណ៍ ។ បើសិនជាក្រុងរាពណ៍ចេះស្តាប់យោបល់របស់ពិភេក និងកុម្ភការណ៍ ក៏ដូច

ជានាងមណ្ឌោគិរី ម្លេះសមក្រុងរាពណ៍ ក៏ដូចជាពលយក្សទាំងអស់អាចរស់នៅបានប្រកបដោយភាពសុខដុមរម្យនាជាក់ជាមិនខាន តែនេះផ្ទុយស្រឡះគឺរាពណ៍មិនស្ដាប់រាពណ៍មិនផ្ដល់តម្លៃចំពោះយោបល់របស់សហការីឡើយ ពោលគឺរាពណ៍ ផ្ដាច់ការក្នុងការគ្រប់គ្រងដែលសកម្មភាពទាំងនេះបានផ្ដល់មកវិញនូវផលអាក្រក់ គឺរាពណ៍ត្រូវបាត់បង់ ពិភេក និង កុម្ភការណ៍ ក៏ដូចជាប្រទេសជាតិដោយសារតែទង្វើឥតពិចារណារបស់ខ្លួន ពោលគឺក្រុងរាពណ៍មិនព្រមស្ដាប់យោបល់របស់សហការីឡើយ ដូចជាការខឹងនឹងការផ្ដល់យោបល់របស់ពិភេក ខឹងនឹងការផ្ដល់យោបល់របស់នាងមណ្ឌោគិរីជាដើម។

*ក្រុងរាពណ៍ស្ដាប់ទេពីថ្លែង ទូលទាស់បីសំដែង ពំនោលពំនិតរ៉ង់ឆ្លង។ រាពណ៍*
*ដឹងក្រេវក្រោធរឹងស្ដូង បើដោយពាក្យហាង ក៏មូលនឹងពិភេក្សា។*
*បឹងយកពិភេកនោះជា ប្ដីមឹងស្នេហា ចំណោចំណង់ចិត្តិហោង*
*ចូរមឹងរត់ទៅនៅផង ឱ្យពិភេកគ្រង ខ្ញុំព្រះរាមលក្សា។*
*អញនូវចេញផ្ចាញរាមា ផ្ចាញលក្ខណ៍អនុជា ក៏ផ្ចាញទាំងពានរពល។*
*ផ្ចាញទាំងពិភេកកំហល់ ទាំងមឹងឯងដល់ ជីវិតលុះមរណ៍ផងគ្នា។*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្សែទី៨ ទំព័រ១៧-១៨)

- **ផ្ដល់ការលើកទឹកចិត្ត ការសរសើរ ការឱ្យតម្លៃ៖**

ដោយឱ្យតម្លៃទៅលើបុគ្គលដែលមានចំណេះដឹង មានជំនាញវិជ្ជាជីវៈ និងវាយតម្លៃជារឿយៗ ទៅលើដំណើរការនៃការងារ។ គួរចងចាំថា រឿងកោតសរសើរ និងរឿងផ្ដល់រង្វាន់ជាកិត្តិយស ដើម្បីលើកទឹកចិត្តត្រូវធ្វើឱ្យកាន់តែឆាប់កាន់តែល្អ ព្រោះវាជាកត្តា ចត្តសាស្ត្ររបស់មនុស្ស។ មនុស្សតែងតែត្រូវការណាស់ចំពោះការលើកទឹកចិត្ត ហើយបើយើងបង្អង់ពេលយូរ នាំឱ្យបុគ្គលដែលមានស្នាដៃទាំងនោះមានការអស់ទឹកចិត្ត ឬបាក់ទឹកចិត្ត។ តួយ៉ាងដូចជាព្រះរាមបានផ្ដល់កិត្តិយសដល់ពិភេកដែលបានចុះចូលនឹងខ្លួន និងរង្វាន់ជាទីគាប់ចិត្តដល់ហនុមាននៅពេលហនុមានបំពេញការងារបានសម្រេចលទ្ធផល ដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់ វឌ្ឍឆាយាវង្ស ខ្សែទី៦ ទំព័រ៦៣ បានបញ្ជាក់ថា៖

*ទៀងទូលអស់អាថិអភិប្រាយ ព្រះបាទនារាយណ៍ ស្ដេចស្ដាប់ទំនួលហនុមាន។*
*ត្រាស់ត្រាច់ទ្រើសទ្រង់ព្រះក្សាន្ត ថាហៃហនុមាន គំនិតគំនាប់អញអរ។*
*អញឱ្យមកុដកែវកងករ ផ្ទីមពស្ត្រាពរណ៍ រង្វាន់នៃរាជក្របី។*
*ហនុមានខិនអង្គសិរសី បង្គំនរបតី ទទួលរង្វាន់រាជា។*

ផ្ទុយទៅវិញ បើសិនជាអ្នកដឹកនាំចង់ស្ដីបន្ទោស គឺត្រូវរង់ចាំឱ្យយូរពេលបន្តិចដើម្បីឱ្យបុគ្គលនោះ រសាយចិត្ត និងមានគំនិតឆ្លើយតបមកវិញបាននូវអ្វីដែលគេបានប្រព្រឹត្តិ ហើយបើស្ដី

បន្ទោសភ្លាមៗ ហាក់បីដូចជាយើងយកកំហឹងទល់នឹងកំហល់ យកសាំងទៅជះលើភ្លើងដែលកំពុងតែឆេះយ៉ាងដូច្នោះដែរ មិនខុសពីក្រុងរាពណ៍ដែលស្ដីបន្ទោសពិភេកនៅមុខចំណោមមន្ត្រីនោះទេ។

*ថាហៃពិភេកព្រះស្ដែង កាចអាចម្ដេចថ្លែង ពុំនោលដំនៀលចិន្តា។*

*ថាអញដូចក្អែកសត្វសា- មានឲ្យបឹងឧបមា អញសោតដូចត្រីតិរិច្ឆាន ។*

*................................ ......................... ..................................*

*អញទៅទរត្បូងមឹងនឹងក្រទា ដែកបែកសិរសា ដ៏ជាប្រាំពីរភាគផង។*

(វគ្គរឆាយាវង្ស រាមកេរ្តិ៍ខ្សែទី៨ ទំព័រ៦)

តាមរយៈតួអង្គកុកដែលបានដៀលត្មះតបតចំពោះព្រះរាម ក៏ជាមេរៀនបង្ហាញឱ្យឃើញថា គ្រប់ជីវមនុស្សសត្វ គឺសុទ្ធតែស្រឡាញ់កិត្តិយស ស្រឡាញ់សេចក្ដីសរសើរ និង ចង់បានការដឹងគុណអំពីជនដែលខ្លួនមានឧបការៈទៅលើ មិនចង់ឱ្យអ្នកណាមើលងាយខ្លួនឡើយ បើទុកណាខ្លួនជាជននោះតូចទាបទន់ខ្សោយក៏ដោយ ហើយវាក៏ជាមេរៀនសម្រាប់ជនទូទៅឱ្យនឹកឃើញជានិច្ចថាសិទ្ធិ និងសេរីភាពគឺជាទីប្រាថ្នារបស់មនុស្សសត្វគ្រប់ជាន់ថ្នាក់ និងម្យ៉ាងទៀតការបានរបស់កុកក៏ជាទង្វើមួយក្នុងការបង្ហាញជាសាកលថា *ជនគ្រប់រូបគួរកុំសម្លឹងមើលឃើញតែទោសកំហុសរបស់អ្នកដទៃត្រូវមើលឱ្យឃើញពីទោសកំហុសរបស់ខ្លួនផង* ព្រោះថាបុគ្គលគ្រប់រូបទោះបីជាមានគុណសម្បត្តិយ៉ាងណាក្ដី ក៏គង់មានគុណវិបត្តិត្រង់ណាមួយជាមិនខាន។

- **ត្រូវមានតម្លាភាព និងជឿទុកចិត្តគ្នាទៅវិញទៅមកនៅក្នុងការងារ ៖**

អ្នកដឹកនាំមិនត្រូវបង្ហាញឱ្យឃើញពីបញ្ហាបក្សពួកនិយម គ្រួសារនិយមនោះទេ ព្រោះថាជាការពិតណាស់ យើងតែងតែចង់បានអ្នកដែលជិតស្និទ្ធមកនៅក្បែរខ្លួន តែយើងក៏មិនត្រូវបិតឈឹងជាមួយអ្នកដទៃដែរ។ គួរចងចាំថា អ្នកដែលនៅក្បែរខ្លួនយើង ងាយផ្ដល់យើងជាទីបំផុតនៅពេលមានបញ្ហា ព្រោះអ្នកនៅក្បែរខ្លួនយើង គេស្គាល់យើងច្បាស់ជាងអ្នកដទៃ និងត្រូវបានប្រគល់ភារកិច្ចដល់អ្នកដទៃទៀត នៅពេលយើងអវត្តមាន ដោយមិនក្ដោបការងារតែម្នាក់ឯង និងទទួលស្គាល់ពីសមត្ថភាពរបស់អ្នកដទៃ ជាពិសេសត្រូវមានប្រកួតប្រជែង រកអ្នកមានសមត្ថភាពពិតប្រាកដមកមកធ្វើការងារអ្វីមួយ មិនមែនចេះតែរើសដាក់ៗនោះទេ។

***ឧទាហរណ៍***៖ ការប្រឡងធ្នូដែលើកធ្នូសររបស់ព្រះបាទជនក បានបង្ហាញពីការផ្ដល់តម្លៃនៃតម្លាភាពរបស់ព្រះបាទជនកចំពោះក្សត្រទាំងអស់ ដែលមានបំណងចង់បាននាងសីតាធ្វើជាមហេសី ដែលសកម្មភាពនេះបានបង្ហាញពីការយកចិត្តទុកដាក់ក្នុងការស្រឡាញ់យុត្តិធម៌របស់ព្រះអង្គចំពោះសមត្ថភាពបុគ្គល ពោលគឺទាល់តែបុគ្គលមានសមត្ថភាពទើបអាចប្រគល់ភារកិច្ច

ឱ្យទទួលខុសត្រូវលើការងារអ្វីមួយបាន ដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់ **វឌ្ឍនាយាវង្ស** ខ្សែទី១ ទំព័រ៦-៧ បានបញ្ជាក់ថា៖

*ដងនោះព្រះបាទនរបតី យល់រាជបុត្រី ពិសេសពិសុទ្ធសុន្ទរ។*
*នោះព្រះមុនីរាជដ៏បវរ ជបធនូសិល្បសរ នូវស័ព្ទសច្ចាអធិស្ឋាន។*
*ថាទោះទេពតាឫទ្ធិមាន ជ័យអាចលើកបាន ធនូសិល្ប៍នូវតែជោជ័យ។*
*យើងនូវយករតន៍សីតាថ្លៃ អភិសេកឱ្យពួ នាទេពដ៏មានចេស្តា។*

- **មានគំនិតសាមគ្គីភាព ៖**

អ្នកដឹកនាំគ្រប់គ្រងត្រូវចេះស្តាប់គំនិត និងចេះចំណាយពេលវេលាសម្រាប់អ្នករួមការងារ សូម្បីតែរឿងរ៉ាវតូចក៏ដោយ ព្រោះបញ្ហាតូចមែន តែផ្សារភ្ជាប់នឹងមនោសញ្ចេតនា ជាពិសេសត្រូវចូលរួមចំណែកចែករំលែកទុក្ខលំបាក ឬចេះជួយការងារគ្នាពេលមានធុរៈផ្សេងៗ ពោលគឺការសាមគ្គីភាពជាធ្លុងមួយ។ សាមគ្គីគឺជាកកត្តាស្នូល បើកាលណាបែកបាក់សាមគ្គីហើយ នោះជាហេតុនាំឱ្យសត្រូវងាយស្រួលនឹងផ្តួលរំលំបានហើយប្រទេសជាតិនឹងទទួលនូវភាពវិនាសអន្តរាយ និរាសព្រាត់ប្រាស តួយ៉ាងដូចជា ក្រុងលង្កាត្រូវអន្តរាយដោយសារតែខ្វះនូវសាមគ្គីផ្ទៃក្នុង ព្រោះរាពណ៍មិនចេះស្តាប់អ្នកក្រោមបង្គាប់ មិនមានគំនិតសាមគ្គីភាព មិនចំណាយពេលវេលាពិភាក្សាការងារ ធ្វើអ្វីតាមតែទង្វើរបស់ខ្លួន ដែលកត្តាទាំងនេះហើយធ្វើឱ្យពិភេកខឹងរត់ចូលខាងព្រះរាម និងជាបុព្វហេតុបង្កភាពងាយស្រួលដល់ព្រះរាមក្នុងការស៊ើបឱ្យដឹងគ្រប់ហេតុការណ៍ទាំងអស់។ ចំណែកខាងព្រះរាមពុំមានការបែក បាក់សាមគ្គីដូចក្រុងរាពណ៍ទេ ដូច្នេះហើយបានជាខាងព្រះរាមតែងតែបានទទួលជ័យជម្នះជានិច្ច គឺព្រះរាមអាចយកជ័យជម្នះលើក្រុងរាពណ៍បាន។

- **មិនត្រូវប្រមាថកម្លាំងសត្រូវ និងត្រូវស្តាប់ឱ្យជាក់ មុននឹងសម្រេចចិត្តធ្វើអ្វីមួយ ៖**

ដោយសារអញ្ញនិយមធ្វើឱ្យរាពណ៍គិតថា គ្មាននរណាម្នាក់ខ្លាំងពូកែដល់ខ្លួនទេ ដោយរាពណ៍បានដៀលត្មះពលស្វាថា ជាពួកមិនចុះយុទ្ធសាស្ត្រ ស៊ីតែផ្លែឈើធ្វើម្តេចនឹងអាចយកជ័យជម្នះលើខ្លួនបាននោះ។ ដូច្នេះអ្នកដឹកនាំ ត្រូវតែប្រកាន់ឱ្យខ្ជាប់នូវពាក្យបុរាណថា ចេះឯងឱ្យក្រែងចេះគេ។ ម្យ៉ាងវិញទៀត ដោយសារតែការស្តាប់ព័ត៌មាន ឬសភាពការណ៍មិនច្បាស់លាស់ និងមិនបានអង្កេតឱ្យបានត្រឹមត្រូវ ក៏ជាគ្រោះថ្នាក់មួយដ៏ធ្ងន់ធ្ងរសម្រាប់អ្នកដឹកនាំដែរ តួយ៉ាងដូចជា គ្រាន់តែឮពាក្យភាន់ច្រឡំរបស់អតិកាយថា ហនុមានដែលជាសេនាឯករបស់ព្រះរាមស្លាប់ និង ឮថាព្រះរាមដកទ័ពថយ រាពណ៍ក៏ត្រេកអរ អួតប្រាប់គេឯង ហើយលើកឆត្រជ័យ

សម្តែងឫទ្ធិអំណាចរបស់ខ្លួនភ្លាមតែម្តង ដោយមិនពនិត្យអង្កេតឱ្យបានហ្មត់ចត់ជាមុនឡើយ លុះដឹងថាជារឿងមិនពិតក៏ខូចចិត្តតែម្តង ។

**- ចេះសន្តោស មិនឆ្មើងឆ្មៃ ចេះគួរសម និង ដឹងគុណ ៖**

មិនប្រកាន់ពណ៌សម្បុរ មិនបែងចែកវណ្ណៈ និង ត្រូវចាត់ទុកខ្លួនជាអ្នកបម្រើនៅពេលដែលគេត្រូវការ ។

**ព្រះរាមចេះសន្តោសអត់ឱន** ទុកជីវិតដល់រាមបរមសូរដែលស្គាល់នូវទោសកំហុសរបស់ខ្លួន ។

**ព្រះរាមមិនចេះតម្កើងខ្លួន** និងចេះរាប់អានមនុស្សជាតិទូទៅ តួយ៉ាងដូចជាកូខ័នជាមនុស្សព្រៃមានក្លិនស្អុះស្អាប គឺព្រះរាមមិនបានទុកកូខ័នជាខ្ញុំកំដរទេ ដោយទ្រង់ទុកកូខ័នដូចជាប្អូនថែមទៀត ។

**ព្រះរាមចេះដឹងគុណ** និងជួយខ្នះខ្នែងសង្គ្រោះជតាយុបក្សីដែលបានជួយការពារនាងសីតា ហើយត្រូវក្រុងរាពណ៍ដកព្រះទម្រង់តប់បាក់ស្លាបដេកស្រប៉ាបលើដី តែជតាយុមិនទទួលយកការជួយសង្គ្រោះជីវិតពីព្រះរាមទេ ហើយនៅទីបំផុតព្រះរាមបានឱ្យពរជតាយុបក្សីទៅកើតក្នុងឋានសួគ៌ និងលើកបីសពជតាយុ ដែលជាជនគំរូនៃលក្ខណៈមនុស្សធម៌ ប្រកបដោយភាពដឹងគុណចំពោះអ្នកដែលបានធ្វើគុណចំពោះខ្លួន ។

**ព្រះរាមសន្តោសភរិយា** ព្រះរាមជាបុរសម្នាក់មានចិត្តសន្តោសយ៉ាងប្រពៃចំពោះភរិយា មានក្តីស្រឡាញ់តែមួយគត់សម្រាប់ភរិយាដែលខុសពីបុរសខ្លះចូលចិត្តយកស្រីជាចំណីរាគា អាងប្រាក់ អាងអំណាច មិនខ្វល់ពីសេចក្តីសុខទុករបស់អ្នកដទៃ ឱ្យតែខ្លួនបានបំពេញនូវចំណង់តណ្ហារបស់ខ្លួន ។ ដូច្នេះ ក្នុងនាមជាអ្នកគ្រប់គ្រង ឬ ជាអ្នកដឹកនាំ គួរតែយកទង្វើសន្តោសភរិយាតាមព្រះរាម ។ បើទោះបីជានាងសូរបនខា ដែលប្អូនស្រីរបស់រាពណ៍កាឡាខ្លួនជានារីយ៉ាងស្រស់ស្អាតដូចស្រីទេពអប្សរយ៉ាងណាក្តី ក៏ទ្រង់មិនព្រមទទួលជាដាច់ខាត ។ ទង្វើទាំងនេះក៏គួរតែបុរសគ្រប់រូបទទួលធ្វើជាគំរូ ព្រោះថា ការមិនសន្តោសចំពោះភរិយារបស់ខ្លួនជាទង្វើក្បត់គ្រួសារដែលជាបុព្វហេតុនាំមកនូវមហន្តរាយជាច្រើនប្រការ គឺបំផ្លាញទាំងទ្រព្យសម្បត្តិ បំផ្លាញទាំងសុខភាព រហូតដល់ពេលខ្លះហ៊ានក្បត់ជាតិ ក្បត់សាសនា ក្បត់ព្រះមហាក្សត្រ និងវិនាសទាំងអាយុជីវិតទៀតផង ។ បុគ្គលគ្រប់រូបគួរចងចាំថា កាលបើសីលធម៌ធ្លាក់ចុះហើយនោះសង្គមមនុស្សនឹងកាន់តែវឹកវរ ។ ដូច្នេះបុគ្គលគ្រប់រូប គួរតែប្រកាន់ខ្ជាប់នូវសីលធម៌ជាគោល ទើបសង្គមមនុស្សឈានទៅរកភាពសុខុដរម្យនាបាន ។ ចូរបុគ្គលគ្រប់រូបប្រព្រឹត្តទង្វើរបស់ខ្លួនចំពោះ អ្នកដទៃ ឱ្យដូចដែលចិត្តរបស់អ្នកចង់ឱ្យអ្នកដទៃប្រព្រឹត្តចំពោះខ្លួនយើងអ៊ីចឹងដែរ ។

**- ចេះផ្តល់អំណាច និង ឱកាសដល់អ្នកក្រោមបង្គាប់ ៖**

មានផលប្រយោជន៍ដល់ការអនុវត្តការងារ ដូចជាជួយពន្លឿនការងារ (នៅពេលបុគ្គលិកក្រោមឱវាទមានអំណាចខ្លះៗ គេអាចធ្វើការងារជំនួសយើងបាន មិនគាំងដំណើរការងារ ហើយថ្នាក់ដឹកនាំល្អពេលខ្លួនអវត្តមាន អ្នកក្រោមឱវាទចេះធ្វើបាន ព្រោះយើងបានប្រគល់ការងារ ហើយអំណាចឱ្យគេធ្វើ និងមិនខ្លាចថ្នាក់ក្រោមទទួលផលប្រយោជន៍។ ប៉ុន្តែយើងត្រូវចេះធ្វើការតាមដានត្រួតពិនិត្យ ព្រោះបុគ្គលខ្លះ ពេលមានអំណាចដែលយើងផ្តល់ឱ្យគេបែរជាយកអំណាចនោះទៅគាបសង្កត់អ្នកដទៃ នាំឱ្យមានអនាធិបតីក្នុងការងារ ។ តួយ៉ាងដូចជាព្រះរាមដែលបាន ប្រគល់អំណាចដល់ព្រះលក្ស្មណ៍ក្នុងការប្រមូលទ័ព និងគ្រប់គ្រងទ័ពជាដើម។ ក្រៅពីការចេះប្រគល់អំណាច អ្នកដឹកនាំ ឬអ្នកគ្រប់គ្រងក៏ត្រូវចេះផ្តល់ឱវាទទូន្មានប្រៀនប្រដៅឱ្យបុគ្គលនៅក្រោមឱវាទចេះខន្តី ចេះអត់ធ្មត់ វៀរចាកនូវអំពើអាក្រក់ មិនយកកំហឹងទល់កំហល់ ចៀសវាងទំនាស់ដែលកើតឡើង ដោយសារតែបញ្ហារាជបល្ល័ង្ក ទ្រព្យសម្បត្តិ ពោលគឺហ៊ានលះបង់នូវផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីប្រយោជន៍សង្គមមនុស្សទូទៅ តួយ៉ាងដូចជាព្រះរាមឃាត់ព្រះលក្ស្មណ៍កុំឱ្យខឹងនឹងមាតា (កៃកេសី) គឺមានន័យថាព្រះរាមជាបុត្រដែលមានភាពកត្តញ្ញូចំពោះមាតាព្រះរាមជាបងដ៏ឧត្តមរបស់ប្អូនៗ និងជាក្សត្រដែលគិតគូរយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់រាស្ត្រជាធំ។

**-ហ៊ានលះបង់និងមានវីរភាពដើម្បីជាតិ** ៖

អ្នកដឹកនាំគួរតែជាបុគ្គលដែលមានការលះបង់ខ្ពស់ ដើម្បីជាផលប្រយោជន៍រួម។ តួយ៉ាងដូចជាព្រះរាមដែលសុខចិត្តលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីសេចក្តីសុខក្នុងរាជវង្ស និងប្រជារាស្ត្រ ពោលគឺទ្រង់មិនចង់ឱ្យមានការបែកបាក់ ឬការថ្នាំងថ្នាក់ល្អក់កករចិត្តនៅក្នុងព្រះញាតិវង្សរបស់ទ្រង់ ក៏ដូចជាការមិនចង់ឱ្យមានកិត្តិសព្ទថាពួកក្សត្រឈ្លោះគ្នា ឬ ប្រណាំងប្រជែងគ្នាអំពីរឿងរាជសម្បត្តិ ឬ បែកបាក់គ្នាព្រោះតែរាជបល្ល័ង្ក ដែលជាបុព្វហេតុចម្បងនាំឱ្យអំណាចក្សត្រធ្លាក់ចុះ។ ម្យ៉ាងវិញទៀត ក្នុងភាពជាអ្នកដឹកនាំ និងជាអ្នកគ្រប់គ្រងគេ គឺត្រូវធ្វើយ៉ាងណាឱ្យបុគ្គលខ្លួនឯងក្លាយជាវីរជនក្នុងបុព្វហេតុជាតិមាតុភូមិផងដែរ។ តាមរយៈតួអង្គកុម្ភការណ៍ គេបានបង្ហាញពីគំរូវីរភាពស្នេហាជាតិរបស់កុម្ភការណ៍ ដែលតំណាងឱ្យអ្នកគិតប្រយោជន៍ជាតិជាធំជាងប្រយោជន៍ផ្ទាល់ខ្លួន គឺមិនតបតនឹងរាពណ៍ ទោះបីជាដឹងថារាពណ៍ធ្វើខុស ក៏កុម្ភកាណ៍នៅតែសុខចិត្តចេញទៅច្បាំងនឹងព្រះរាម មិនខ្លាចស្លាប់ ដើម្បីការពារកិត្តិយសត្រកូល ចៀសវាងនូវដំណៀលថាបងប្អូនឈ្លោះគ្នា ក្លាយទៅជាសត្រូវនឹងគ្នា ពោលគឺកុម្ភការណ៍មិនលក់ឧត្តមគតិជាតិឡើយ កុម្ភការណ៍នៅតែរក្សាភក្តីភាពចំពោះបងក៏ដូចជាចំពោះប្រទេសជាតិដែរ។ កុម្ភការណ៍ដឹងច្បាស់ណាស់ថា ទៅច្បាំងមុខជាស្លាប់តែកុម្ភការណ៍នៅតែទៅ គឺទៅក្នុងនាមជាពលរដ្ឋល្អរបស់ជាតិ ហ៊ានពលីជីវិតដើម្បីជាតិ។ ម្យ៉ាងវិញទៀត ទោះបីជាបក្សពួកព្រះរាមបញ្ចុះបញ្ចូល

ដោយសន្យាឱ្យបុណ្យសក្តិធំក៏ដោយ ក៏កុម្ភការណ៍ មិនព្រមចុះចូល មិនព្រមធ្វើជាខ្ញុំកញ្ជះ សត្រូវ ហើយស៊ូទ្រាំប្រយុទ្ធលុះត្រាដង្ហើមចុងក្រោយ ដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់ ***វឌ្ឍនាយាវង្ស*** ខ្សែទី៩ ទំព័រ១១ បានបញ្ជាក់ថា៖

*ហៃពិភេហេតុនោះអញយល់ ខ្លាចដំនៀលនូវដល់ ទាំងអញឥឡូវផងណា។*
*សូវស្លាប់អញពុំទៅជា ខ្ញុំព្រះរាមា ធិរាជនោះឡើយនេះឥឡូវ។*
*ចូរបាទៅទូលដោយនូវ បណ្តាំកូវ ធរេន្ទ្រធិរាជពីរអង្គ។*
*សូមស្តេចរណ្តាប់ពលផង ចេញកណ្តាលរឿងរង្គ ប្រយុទ្ធដណ្តើមចេស្តា។*
*វីត្រង់អញនឹងទៅជា ខ្ញុំព្រះរាម នោះអញពុំគិតមូតហោង។*

- **ប្រកាន់សត្យ សច្ចៈភាព ស្មោះត្រង់ យុត្តិធម៌ មិនលោភលន់ និងហ៊ានទទួលស្គាល់ការពិត ៖**

អ្នកដឹកនាំត្រូវចេះអប់រំទូន្មានចិត្តឱ្យប្រកាន់នូវភាពសច្ចៈទៀងត្រង់ ប្រកបដោយភាពយុត្តិធម៌ និងហ៊ានទទួលយកការពិត។ ព្រះរាមសុខចិត្តនិរទេសខ្លួនទៅនៅព្រៃអស់រយៈ១៤ឆ្នាំ គឺក្នុងគោលបំណងឱ្យបិតាកាន់នូវពាក្យសត្យ ដែលនេះជាគំរូដ៏ល្អសម្រាប់មនុស្សទូទៅក៏ដូចជាអ្នកដឹកនាំ គឺហ៊ានថា ហ៊ានធ្វើ។ម្យ៉ាងវិញទៀត ព្រះរាមទ្រង់មិនចង់ឱ្យមានការបែកបាក់ ឬថ្នាំងថ្នាក់ក្នុងរាជវង្សានុវង្សក៏ដូចរាជបល្ល័ង្ក ដែលជាបុព្វហេតុនាំឱ្យខ្សោយអំណាចក្សត្រ។ ម្យ៉ាងវិញទៀត ព្រះរាមមិនព្រមត្រឡប់មកគ្រងរាជ្យតាមការស្នើសុំដ៏ទទូចរបស់ព្រះភិរុតនេះ ជាទម្ងន់មួយនៃការកាន់ពាក្យសត្យយ៉ាងម៉ឺងម៉ាត់ដាច់ខាតរបស់ទ្រង់បន្ថែមទៀត គឺទ្រង់មិនត្រឹមតែមិនព្រមត្រលប់មកគ្រងរាជ្យទេ ថែមទាំងនាំព្រះជាយានិងព្រះអនុជចេញពីចិត្រកូដបព៌ត ទៅកាន់ព្រៃទណ្ឌកៈ ដើម្បីលាក់ខ្លួនពួនអាត្មា ខ្លាចក្រែងព្រះញាតិវង្សមកទទូចសុំឱ្យទៅគ្រងរាជ្យសារជាថ្មីទៀត។

*ដងនោះនារាយណ៍រាមា ស្តេចទ្រង់ព្រះចិន្តា នឹងព្រះអនុជនូវទេពី។*
*ថាយើងនៅមណ្ឌលទី ចិត្រកូដគិរី នេះទាបអយុធ្យាព្រះនគរ។*
*ក្រែងព្រះភិរុតនាំបរ ញូរមកអង្វរ សំបូងសម្លេងអញបង។*
*ខិតខំឱ្យអញទៅគ្រង រាស្ត្រពិភពស្នង សម្តេចព្រះវរបិតា។*
*ច្នេះគួរយើងចរលីលា លះលែងបព្វតា ទៅរកទីស្ថានទូរគម។*

(វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្សែទី២ ទំព័រ៨៤-៨៥)

តាមរយៈតួអង្គព្រះភិរុត ដែលជាបុត្ររបស់ព្រះបាទទសរថជាមួយនាងកៃកេសី និងត្រូវជាប្អូនរបស់ព្រះរាមដែរនោះ គឺទ្រង់ជាក្សត្រមួយអង្គដែលតំណាងឱ្យជនស្មោះត្រង់ មានស្មារតីភក្តីចំពោះព្រះរាជវង្សានុវង្ស ជាពិសេសចំពោះព្រះរាម ពោលគឺទ្រង់មិនលោភលន់ មិន

ប្រណាំងប្រជែងនឹងវាសនា មានគំនិតជ្រៅ ដៅបានឆ្ងាយ ដោយទ្រង់មិនព្រមសោយរាជ្យជាដាច់ខាត ព្រោះបើសិនជាទ្រង់សោយរាជ្យ ក៏ទ្រង់មិនមានកិត្តិយសគ្រប់គ្រាន់ដែរ ហើយសត្រូវជិតឆ្ងាយនឹងមើលងាយ ព្រោះរាជ្យសម្បត្តិដែលទ្រង់ បានជារាជ្យសម្បត្តិខុសបុរាណរាជប្រវេណី ជារាជសម្បត្តិដែលបានមកពីការដណ្តើមគ្នា ដូច្នេះបុគ្គលល្អដូចជាទ្រង់មិនអាចទទួលយកបានទេ ហើយមិនត្រឹមតែមិនព្រមទទួលនោះទេ គឺទ្រង់ថែមទាំងទៅតាមបងឱ្យមកសោយរាជ្យវិញថែមទៀត ពោលគឺទ្រង់លាងខ្លួនទ្រង់យ៉ាងស្អាតបរិសុទ្ធមិនឱ្យប្រឡាក់ប្រឡូសនឹងភាពលោភលន់ឡើយ ដូចក្នុងដំណើររឿងរបស់អ្នកអង្គម្ចាស់***វឌ្ឍនាយាវង្ស*** ខ្សែទី២ ទំព័រ៥៥-៥៦ បញ្ជាក់ថា៖

*ទោះបីឱ្យអញសោយរាជ្យនៅពូ ព្រះនគរនេះនៃ អញខ្ពើមពុំចង់ប្រាថ្នា។*
*អញនូវយកព្រះខ័នពេជ្រថ្លា ទំលាយអង្គឱរា អញឯងឱ្យលុះអន្តរាយ។*
*មួយសោតអញនូវតាមទៅថ្វាយ បង្គំបាទព្រះនារាយណ៍ ហើយសូមអញ្ជើញស្តេចមក។*
*ទោះបីប្រវៀមដ៏ពន្លក ពុំវិលវឹងមក ប្រយោជន៍ប្រវេណីក្សត្រ។*
*អញនៅបម្រើប្រតិបត្តិព្រះ បាទវៀមរត់ន៍ បីដូចព្រះលក្ខណ៍នោះហោង។*

ម្យ៉ាងវិញទៀត បុគ្គលអ្នកដឹកនាំគួរតែចេះទទួលស្គាល់ការពិត ហើយចេះកែខ្លួននៅពេលដឹងថាមានកំហុសនោះទើបជាអ្នកដឹកនាំដែលមានទំនួលខុសត្រូវចំពោះភារកិច្ច តែរាពណ៍ជាអ្នកដឹកនាំម្នាក់ដែលផ្ទុយពីនេះ គឺនៅពេលត្រូវសរទិព្វមន្តរបស់ព្រះរាមដល់សន្លប់បាត់ស្មារតី លុះដឹងខ្លួនឡើងវិញ ក៏នឹកឃើញពីកំហុសរបស់ខ្លួន ដឹងថាខ្លួនធ្វើខុសនឹងមានសេចក្តីវិនាសអន្តរាយទៅថ្ងៃអនាគត តែខ្លួនរាពណ៍ផ្ទាល់មិនព្រមលះបង់គំនិតរបស់គេឡើយ គឺនៅតែរឹងរូស នៅតែឃោរឃៅ ដឹងថាភ្លើងក្តៅហើយនៅតែចូលក្នុងភ្លើងដោយឥតញញើត ហើយនៅទីបំផុត ទាំងខ្លួន ទាំងក្រុមគ្រួសារ ទាំងញាតិមិត្ត ត្រូវវិនាសទាំងអស់ ពោលគឺវិនាសទាំងជាតិតែម្តង។

បុគ្គលដែលស្គាល់កំហុស ហើយចេះកែកំហុស គឺជាបណ្ឌិត តួយ៉ាងដូចជាព្រះរាមដែលមានការភ្ញាក់រឭក ទទួលស្គាល់នូវកំហុសរបស់ខ្លួននៅពេលដែលនាងសីតាបានលើកឡើងពីទង្វើខុះការពិចារណា អមនុស្សធម៌ ឥតមេត្តារបស់ទ្រង់ ដោយទ្រង់ទទួលនូវវិប្បដិសារី នឹកឃើញរាល់កំហុស ដោយប្រតិបត្តិខ្លួនជាបុគ្គលម្នាក់មានកាយវិការស្លូតបូត ចេះនិយាយពាក្យស្រទន់ គួរសមសូមខមាទោស លោះលាងកំហុសចំពោះមុខមហេសីថា៖

*ខ្លួនបងនេះយល់ខុសហើយ កុំយកទោសឡើយប្អូនភ្ងា*
*គិតកាលកម្សត់នឹងគ្នា ចេញមកបើកទ្វារឆាប់ខ្ញុំ*
*សូមប្អូនមិត្រមាសសង្សារ ព្រាត់ប្រាស់និរាសបុរី។*
*បងនឹងចូលទៅស្រដី និយាយប្រាប់ទោសអាត្មា។*

*(វណ្ណនាយាវង្ស រាមកេរ្តិ៍ខ្មែរទ័ព៧៨ ទំព័រ៤២-៤៣)*

តាមរយៈតួអង្គពិភេកដែលជាប្អូនរបស់ក្រុងរាពណ៍ គឺជាបុគ្គលម្នាក់ដែលមានភាពស្មោះត្រង់ ហ៊ាននិយាយការពិត ស្រឡាញ់យុត្តិធម៌ដោយហ៊ានទូលថ្វាយរាពណ៍តាមត្រង់ថា ក្រុងលង្កានឹងវិនាសហិនហោច បើកាលណារាពណ៍មិនព្រមប្រគល់សីតាឱ្យទៅព្រះរាមវិញទេនោះ ដែលនេះជាគំនិតសច្ចៈ យុត្តិធម៌ ចង់បានសន្តិភាពពិតៗដែលអ្នកយុត្តិធម៌ អ្នកមានគតិបណ្ឌិតទូទៅក៏ត្រូវតែយល់ស្របតាមការទូលរបស់ពិភេកដែរ តែពាក្យពិត និងគំនិតយុត្តិធម៌ទាំងនេះវាមិនស្របនឹងគំនិតអយុត្តិធម៌និងថោកទាបរបស់ក្រុងរាពណ៍ទេ ព្រោះអ្វីដែលពិភេកត្រូវទទួលក្រោយពីទូលការពិតនោះ គឺក្រុងរាពណ៍បានជេរប្រមាថផ្តាសា និងវាយក្បាលពិភេកនឹងស្បែកជើងកណ្តាលជំនុំចំណោមគួរឱ្យអាម៉ាស់ថែមទៀត។ គួរចងចាំថា តម្លៃយុត្តិធម៌មានតែនៅក្នុងសង្គមយុត្តិធម៌ទេ គឺវាមិនអាចមានក្នុងសង្គមអយុត្តិធម៌បានឡើយ ហើយដោយសារសង្គមអយុត្តិធម៌ដូច្នេះហើយទើបពាក្យពិតរបស់ពិភេកក្លាយទៅជាការមើលងាយរបស់រាពណ៍ទៅវិញ ពោលគឺពាក្យពិតវែងស្លែង។ ដោយសារទង្វើអយុត្តិធម៌របស់ក្រុងរាពណ៍ ធ្វើឱ្យយុត្តិធម៌របស់ពិភេកមិនអាចនៅជាមួយគ្នាបាន គឺពិភេកសុខចិត្តលះបង់ភរិយា លះបង់កូន លះបង់ទ្រព្យសម្បត្តិ រត់មកចុះចូលខាងព្រះរាម ដែលទង្វើនេះសម្រាប់អ្នកលទ្ធិជាតិនិយម គេចោទថាពិភេកក្បត់ជាតិពេញទី ព្រោះពិភេកខឹងនឹងបងរបស់ខ្លួនរត់ទៅចូលខាងសត្រូវ។ តែបើនិយាយទៅតាមយុត្តិធម្មនិយម ឬធម្មាធិបតេយ្យវិញ ពិភេកជាអ្នកយុត្តិធម៌ដូច្នេះពិភេកត្រូវតែរស់នៅក្នុងសង្គមយុត្តិធម៌ដើម្បីលើកតម្កើងយុត្តិធម៌ ពោលគឺចង់លុបបំបាត់អយុត្តិធម៌ឱ្យអស់ពីសង្គម ដើម្បីនាំមកនូវសុខសន្តិភាព និងភាពសុខដុមរម្យនា ជូនជាតិមាតុភូមិ ក៏ដូចជាពិភពលោក។

អ្នកដឹកនាំ ឬអ្នកគ្រប់គ្រងគួចងចាំថាការល្មោភនឹងអំណាចដោយឥតពិចារណា និងការមិនចង់ឱ្យអ្នកដទៃខ្លាំងពូកែដូចខ្លួន ធ្វើឱ្យមនុស្សហ៊ានប្រព្រឹត្តនូវអំពើមិនគប្បីគ្រប់បែបយ៉ាងដើម្បីតែប្រយោជន៍សួនតួរបស់ខ្លួន តួយ៉ាងដូចជា មហិង្សរាជដែលហ៊ានសម្លាប់កូនឈ្មោលចោលទាំងអស់ក្នុងគោលបំណងមិនចង់ឱ្យអ្នកណាម្នាក់មកជ្រៀតជ្រែក ឬ ដណ្តើមយកសេចក្តីសុខរបស់ខ្លួន។ ម្យ៉ាងវិញទៀតដើម្បីបានទ័ពទៅប្រយុទ្ធជាមួយក្រុងរាពណ៍នៅលង្កាបុរី ព្រះរាមសុខចិត្តជួយសុគ្រីព ដោយទៅលួចបាញ់ពាលីពីក្រោយខ្នង ដែលនេះជាទង្វើដ៏កំសាកដែលបុគ្គលជាអ្នកដឹកនាំ ឬអ្នកគ្រប់គ្រងគួរតែចៀសវាងឱ្យបាន ជាពិសេសគឺត្រូវចៀសឱ្យបាននូវរាល់ទង្វើអគតិមួយចំនួនដូចជា ព្រះរាមបញ្ជាឱ្យព្រះលក្ស្មណ៍យកនាងសីតាទៅសម្លាប់ទាំងមានផ្ទៃពោះដោយសារតែការមិនព្រមស្តាប់ហេតុផលអ្នកដទៃឡើយ។ ព្រះរាមមិនមែនមិនដឹងថាសីតាមានផ្ទៃពោះឯណា តែព្រះរាមនៅតែបញ្ជាឱ្យព្រះលក្ស្មណ៍យកនាងទៅសម្លាប់ដោយគ្មានធម៌មេត្តា និងទង្វើដែលព្រះរាមបានចាប់ក្មេងដែលគ្មានកំហុស យកទៅធ្វើបាបយ៉ាងទុក្ខទារុណយ៉ាងសែន

វេទនា ដោយយកទៅបណ្ដើរអាក្រាសជុំវិញព្រះរាជវាំង ហើយយកទៅដាក់ក្នុងទ្រុងដែកទៀត ដែលបង្ហាញពីអំពើដ៏អមនុស្សធម៌ មិនចេះសន្ដោសរបស់ព្រះរាម សូម្បីតែកូនក្មេងក៏ព្រះរាមបានធ្វើទារុណកម្មដែរ។

**-ស្អប់ខ្ពើមសង្គ្រាមនិងស្រឡាញ់សន្តិភាព ៖**

ក្នុងនាមជាអ្នកដឹកនាំត្រូវចេះស្អប់ខ្ពើមសង្គ្រាម និង ស្រឡាញ់សន្តិភាព។ អ្នកដឹកនាំមិនត្រូវមានគំនិតគុំគួន ព្យាបាទសងសឹកនោះទេ គឺត្រូវចេះដោះស្រាយបញ្ហាដោយសន្តិវិធី។ តាមការសង្កេត ព្រះរាមជាអ្នកដឹកនាំមួយរូបដែលមិនចង់ធ្វើសង្គ្រាម ឬបង្កហេតុមុនឡើយ គឺទ្រង់ជាបុគ្គលដែលត្រូវការសន្តិភាព ជាក់ស្តែងដូចជាទ្រង់ធ្លាប់អត់ឱនទោសឱ្យរាមបរមសួរ និង អត់ឱនចំពោះហេតុការណ៍ក្នុងជីវិតដូចជាមិនបង្កជម្លោះជាមួយនាងកៃកេសី ដោយទ្រង់សុខចិត្តទៅរស់នៅក្នុងព្រៃតាមការស្នើសុំរបស់នាង ក៏ដូចជាទ្រង់បានបញ្ជូនរាជទូត គឺអង្គទឱ្យទៅចរចានឹងរាពណ៍ថា ទ្រង់ជាអវតាររបស់ព្រះវិស្ណុដ៏មានរិទ្ធិ ដោយសុំឱ្យរាពណ៍ប្រគល់នាងសីតាមកឱ្យទ្រង់វិញ តែរាពណ៍ពុំព្រម បំពេញតាមបំណងរបស់ទ្រង់ ដែលជាបុព្វហេតុនាំឱ្យកើតមានសង្គ្រាមនិងហាយនភាពដល់ពួកយក្ស។ ម្យ៉ាងវិញទៀត ខណៈដែលក្រុងរាពណ៍បញ្ឆិះនាងសីតាលើរាជរថហោះមកបញ្ឈឺចិត្តព្រះរាមនោះ ទ្រង់មិនថ្លែងសរសម្លាប់រាពណ៍ភ្លាមទេ គឺទ្រង់គ្រាន់តែថ្លែងអារិទ្ធិចន្ទ្រដែលត្រឹមតែធ្វើឱ្យរាពណ៍សន្លប់ប៉ុណ្ណោះ ហើយសង្ឃឹមថាពេលរាពណ៍ដឹងខ្លួន រាពណ៍សុខចិត្តខ្លាចអំណាចទ្រង់ និងព្រមយកនាងសីតាមកប្រគល់ឱ្យទ្រង់វិញ តែផ្ទុយស្រឡះគឺរាពណ៍ពុំព្រមចុះចាញ់ទ្រង់ឡើយ ហើយដោយសារការគុំគួន ការព្យាបាទសងសឹករបស់បុគ្គលម្នាក់ឬបក្សម្ខាង ចំពោះបុគ្គលម្នាក់ទៀតឬបក្សម្ខាងទៀតនេះហើយ ដែលនាំឱ្យមានកើរ្តិ៍របស់ព្រះរាមជាមួយក្រុងរាពណ៍ គឺកើតចេញពីការធ្វើបាបចំពោះនាងសុបនខាដែលជាសាច់ញាតិខ្លួន ក្រុងខក៏បានរើសអ្នកខ្លាំងពូកែឱ្យទៅសងសឹកនឹងព្រះរាម ព្រះលក្ស្មណ៍ ហើយក្រោយមក អាតុល័យក៏តាមសងសឹកព្រះរាម ធ្វើឱ្យព្រះរាមនិងនាងសីតាព្រាត់ប្រាស់គ្នា ព្រោះតែព្រះរាមបានសម្លាប់ ក្រុងរាពណ៍ដែលជាសាច់ញាតិរបស់ខ្លួន។

**- ស្គាល់កាលៈទេសៈ ៖**

ក្នុងនាមជាអ្នកគ្រប់គ្រង និងដឹកនាំប្រទេសមួយក៏មិនត្រូវមានចិត្តអហិង្សាពេកនោះដែរ មានពេលខ្លះបុគ្គលអ្នកដឹកនាំត្រូវពិនិត្យពិចៃឱ្យបានសព្វជ្រុងជ្រោយផងដែរ ព្រោះការប្រព្រឹត្តរបស់មនុស្សមិនមែនសុទ្ធតែត្រូវ សុទ្ធតែល្អ និងសុទ្ធតែដោះស្រាយបញ្ហាដោយសន្តិវិធីគ្រប់ករណី និងគ្រប់ពេលវេលានោះទេ។ តួយ៉ាងដូចជាព្រះរាម ពេលដែលទ្រង់សុខចិត្តលះបង់រាជសម្បត្តិ តាំងចិត្តព្យាយាមប្រព្រឹត្តក្រឹត្យក្រមជាបុគ្គលល្អដោយចាកចេញពីចិត្រកូដបពិតទៅកាន់ព្រៃទណ្ឌកៈ ដើម្បីលាក់ខ្លួនពួនអាត្មា ខ្លាចក្រែងព្រះញាតិវង្សទៅទទូចអង្វរឱ្យទ្រង់ត្រឡប់

ទៅសោយរាជ្យយ៉ាងណាក្តី ក៏ទ្រង់មិនទ្រាំបាននូវទង្វើរបស់យក្សពិរាធ ដែលមកគំរាមកំហែង បៀតបៀនឈ្លានពានទ្រង់ចង់ឆក់យកសីតាពីទ្រង់ ក៏ព្រះអង្គមិនអាចទប់ចិត្តទប់កាយបានដែរ ព្រោះព្រះរាមជាមនុស្ស ដូច្នេះព្រះរាមនៅមានកាមកិលេសគឺ រាគៈ ទោសៈ មោហៈ ដូចគេឯង ផងដែរ។ ដូច្នេះព្រះរាមមិនអាចប្រើខន្តីធម៌ ឬដោះស្រាយបញ្ហាជាមួយយក្សពិរាធដោយសន្តិវិធី បានទេ ព្រោះយក្សពិរាធជាតំណាងឱ្យមនុស្សពាលឃោរឃៅ ក្អេងក្អាង មិនយល់ថាអ្វីជាការគួរ និងអ្វីការមិនគួរ។ ថ្វីត្បិតតែការអត់ឱនឬការលើកលែងទោសឱ្យសត្រូវ គឺជាទង្វើ ល្អនៃអ្នកប្រាជ្ញ និងបណ្ឌិតក៏ពិតមែន តែបើការអត់ឱននោះត្រឡប់ជាឱ្យទោសដល់យើងវិញនោះ តើយើងសុខ ចិត្តអន់ឱនដែរឬទេ? តើអ្នកណាដែលមានចិត្តអត់ឱនឱ្យជនឧក្រិដ្ឋ? តួយ៉ាងដូចជាទង្វើរបស់យក្ស ពិរាធនេះ បើសិនជាព្រះរាមអត់ឱនឱ្យវាច្បាស់ជាយល់ថា ព្រះរាមជាជនកំសាកទើបមិនហ៊ាន តបត។

ប្រសិនបើអ្នកគ្រប់គ្រងមិនយល់ មិនស្គាល់នូវកាលៈទេសៈណាគួរធ្វើ និងកាលៈទេសៈ ណាមិនគួរធ្វើ វានឹងបុាចផលអាក្រក់ដល់អ្នកគ្រប់គ្រងជាមិនខាន តួយ៉ាងដូចជានាងកៃកេសីជា ដើម ដោយសារតែការមិនចេះមើលកាលៈទេសៈ និងដោយសារតែភាពលោភលន់ហួសរបស់ នាង សុភមង្គលដែលនាងចង់បង្កើតឱ្យកូន បានក្លាយទៅជាអពមង្គលទៅវិញ គឺនាងជាអ្នកធ្វើឱ្យ ព្រះស្វាមីកើតទុក្ខក្រៀមក្រំរហូតសោយទិវង្គត នាងមានឈ្មោះជានារីសម្លាប់ស្វាមី នាងជាអ្នក ធ្វើឱ្យព្រះរាម ព្រះលក្សណ៍ និងនាងសីតារងទុក្ខវេទនា នាងជាអ្នកធ្វើឱ្យរាស្ត្រ និងមន្ត្រីកើតទុក្ខ ក្តៅក្រហាយក្រៀមក្រំទូទាំងនគរ។ នាងជាអ្នកធ្វើឱ្យព្រះរាជបុត្ររបស់នាងទទួលនូវភាពតាន តឹងទុក្ខសោក ដែលទង្វើនិងសកម្មភាពទាំងនេះគួរតែអ្នកគ្រប់គ្រង និងអ្នកដឹកនាំត្រូវចៀស ឱ្យបាន ព្រោះការមិនស្គាល់កាលៈទេសៈ និងភាពលោភលន់ វានឹងនាំមកនូវផលអាក្រក់ចំពោះ បុគ្គលយើង ចំពោះសង្គមជាតិយើងនៅថ្ងៃណាមួយជាក់ជាមិនខាន។ ជាពិសេសអ្នកដឹកនាំត្រូវ ចេះគិតគូរពិចារណាឱ្យបានវែងឆ្ងាយ ពោលគឺអ្នកដឹកនាំត្រូវអង្គុយឱ្យខ្ពស់ ភ្នែកសម្លឹងឱ្យឆ្ងាយ ដើមទ្រូងឱ្យត្រជាក់ ។

តាមរយៈតួអង្គកុកដែលឆាប់ដឹងខ្លួនថាមិនអាចប្រឆាំងនឹងព្រះរាមបាន បើប្រឆាំងតទៅ ទៀតគ្រោះភ័យអន្តរាយនឹងមកគ្របសង្កត់លើខ្លួន កុកក៏លន់តួសុំទោសថ្វាយជីវិតបម្រើព្រះរាម នៅពេលណាព្រះរាមត្រូវការខ្លួន។ មិនខុសណាពីចៅសនសុខចិត្តទទួលខ្លួនថាឆ្កួត ដើម្បីឱ្យរួច ទណ្ឌកម្មរបស់គណៈពាលនៃតាចេនដូច្នោះដែរ ដែលនេះគឺជាមធ្យោបាយមួយដែលត្រូវអនុវត្ត ក្នុងកាលៈទេសៈណាមួយតាមការគួរ ដើម្បីដោះខ្លួនឱ្យរួចពីគ្រោះថ្នាក់ ឬ ដើម្បីសេចក្តីសុខរបស់ សង្គមជាតិខ្លួន។

*ក្រៅអំពីចំណុចសំខាន់ៗខាងលើ រឿងរាមកេរ្តិ៍ក៏បានបង្ហាញនូវតម្លៃចំពោះមនុស្សដែលជាអ្នកគ្រប់គ្រងគេ ឬ មនុស្សដែលត្រូវគេគ្រប់គ្រងនូវបញ្ហាផ្សេងៗជាច្រើនទៀត ដែលតែងតែកើតមាននៅក្នុងសង្គមទូទៅ តួយ៉ាងដូចជា៖*

- ***បង្ហាញពីតម្លៃចំណេះវិជ្ជាជាសម្បត្តិមហាសាល*** ៖ ក្នុងរឿងរាមកេរ្តិ៍ តួអង្គព្រះរាម និង ព្រះលក្សណ៍រៀនចេះចប់គម្ពីរនៃព្រហ្មញ្ញសាសនាពីឥសីពិស្វាមិត្រដែលជាគ្រូបាអាចារ្យ រួចហើយអាចលើកធ្នូសរ ហើយបានព្រះនាងសីតាជាមហេសី។ នេះបញ្ជាក់យ៉ាងច្បាស់ពីតម្លៃនៃចំណេះវិជ្ជាដែលអ្នកនិពន្ធចង់បង្ហាញ។
- ***បង្ហាញកុំឱ្យមានអំនួត*** ៖ ទូភីសម្លាប់ស្តេចក្របីមហិង្សរាជ ហើយមានអំនួត តែងតែដើររករឿងរាតត្បាតគេឯង ដូចជារករឿងឥសីបញ្ចលិង្គ នាងទេពធីតារក្សាសមុទ្រព្រៃហេមពាន្ត និងទៅរករឿងពាលី ដែលជាស្តេចស្វាសោយរាជ្យនៅខាស់ខិនបុរី ហើយទីបំផុតពាលីក៏ប្រហារទូភីនឹងព្រះខ័នស្លាប់ទៅ។
- ***បញ្ហាដែលកើតឡើងដោយសារពាក្យសម្តី*** ៖ (អណ្តាតជាអាទិ៍កន្លង បានសុខទុក្ខផងដោយសារអណ្តាត) ដែលគេបានលើកឡើងបង្ហាញតាមរយៈតួអង្គជតាយុ ដែលត្រូវស្លាប់ដោយសារតែសម្តីខ្លួន។ បើសិនជាជតាយុមិននិយាយប្រាប់រាពណ៍ថា ខ្លួនខ្លាចតែចិញ្ចៀនសីតាទេនោះ ក្រុងរាពណ៍ក៏មិនអាចយកជ័យជម្នះលើជតាយុបានដែរ។ ត្រង់ចំណុចនេះហើយដែលពាក្យបុរាណទូន្មានថា "មុននឹងនិយាយអ្វី ត្រូវគន្លាស់អណ្តាតឱ្យបានមួយរយជុំសិន" ឬ "អណ្តាតជាអាទិ៍កន្លង បានសុខទុក្ខផង ដោយសារអណ្តាត"។
- ***ទោះបីជាមនុស្សក្លាយទៅជាអ្វីក៏ដោយ ក៏មនុស្សមិនអាចគេចផុតពីបញ្ហានានាដែលកើតមាននៅក្នុងសង្គមបានដែរ*** ៖ តួយ៉ាងដូចជាព្រះរាមដែលជាអាទិទេពនោះក៏អាចចាញ់កលយក្ស និងចេះលេងសើចជាមួយសូរបនខាឱ្យកើតមានរឿងដែរ។ ព្រះរាមចេះយំនៅពេលព្រាត់ពីសីតា ព្រះរាមចេះប្រចណ្ឌមិនសមហេតុផល ព្រះរាមចេះគំរាមកំហែងសត្វកុក ព្រះរាមចេះបោកប្រាស់អ្នកដទៃ។
- ***បញ្ហាភក្តីភាព*** ៖ សីតាសុខចិត្តរស់នៅយ៉ាងសែនវេទនានៅក្នុងអសោកសួន ដើម្បីសម្តែងពីភាពស្មោះត្រង់ និងមានភក្តីភាពចំពោះព្រះរាម។ ទោះបីជារាពណ៍ខំប្រឹងលួងលោមយ៉ាងណាក៏ដោយ ក៏នាងសីតាមិនព្រម គឺនាងសុខចិត្តស្លាប់ប្រសើរជាងរស់នៅជាមួយរាពណ៍។ ក្រោយមក សីតាសុខចិត្តលុយភ្លើងដើម្បីសម្តែងពីភាពស្មោះត្រង់របស់នាង ហើយនៅទីបំផុតទោះបីជាសីតាខឹងព្រះរាមយ៉ាងណាក៏ដោយ ក៏នាងនៅតែមានទឹកចិត្តជាប់ជំពាក់ស្មោះត្រង់ និងគោរពស្រឡាញ់ព្រះរាមជាជានិច្ច។

- *ភាពទន់ខ្សោយធ្វើឱ្យមនុស្សចេះភូតកុហក* ៖ ព្រះរាមដោះស្រាយបញ្ហាដោយភូតកុហក ព្រោះព្រះរាមអស់មធ្យោបាយក្នុងការដោះស្រាយជម្លោះជាមួយមហេសី ដោយព្រះរាមសុខចិត្តចូលកោដ្ឋបញ្ឆោតនាងសីតា ដែលនៅទីបំផុតអំពើភូតកុហកមុសាទាំងនោះ ធ្វើឱ្យព្រះរាមត្រូវទទួលនូវបរាជ័យយ៉ាងធ្ងន់ធ្ងរនៅក្នុងជីវិត។

ដូច្នេះ តាមការបកស្រាយនូវអត្ថន័យនៃរឿងរាមកេរ្តិ៍រួចមកយើងឃើញថា រឿងរាមកេរ្តិ៍គឺជារឿងមួយដែលបានបញ្ចូលនូវគ្រប់សកម្មភាព គ្រប់ទង្វើរបស់មនុស្សដែលបានធ្វើដោយបង្ហាញពីផលនៃទង្វើឱ្យយើងឃើញ ដើម្បីធ្វើជាគំរូចំពោះអ្នកមានអ្នកសិក្សាគ្រប់រូប និងជាស្នាដៃមួយដែលពោរពេញទៅដោយអត្ថន័យយ៉ាងជ្រាលជ្រៅ គួរឱ្យយើងយកមកធ្វើជាគំរូ និងត្រិះរិះពិចារណាផងដែរ ព្រោះរឿងនេះ បង្ហាញពីលក្ខណៈវីរភាពពីទំនាស់វិបត្តិ(ទំនាស់រាជបល្ល័ង្កទំនាស់សភាវៈល្អជាមួយសភាវៈអាក្រក់) បញ្ហាស្មុគស្មាញនៅក្នុងជីវភាពរស់នៅ ការស្មោះត្រង់ការចោទប្រកាន់ និងបញ្ហាដទៃទៀតជាច្រើនដែលពាក់ព័ន្ធនឹងទង្វើរបស់មនុស្សនៅក្នុងជីវភាពរស់នៅជាក់ស្តែង(អ្នកណាសាងអំពើអ្វី ផលនៃអំពើនោះនឹងតាមមកដូចស្រមោលអន្ទោលតាមប្រាណ)។

## ២- តម្លៃលើផ្នែកអត្ថរូប

### ក- តម្លៃតំណែងនិពន្ធ

រឿងរាមកេរ្តិ៍របស់អ្នកអង្គម្ចាស់ *វណ្ណរាយាវង្ស* គឺជាស្នាដៃមួយដែលសរសេរជាពាក្យកាព្យ មានលក្ខណៈជាបទពោល។ បទខ្លះទៀតមានលក្ខណៈដូចជា បទពំនោល ព្រហ្មគីតិ បន្ទោលភាគ និង បទខ្លះទៀតយើងមិនអាចចាត់ទុកចូលក្នុងប្រភេទបទកំណាព្យណាមួយឱ្យបានច្បាស់លាស់ទេ ហើយបទទាំងនោះមានដូចជា ៖ បទសំរេប សំណាស្តេចលេលា សំណាខរសម្តេចភាណ ច្រះដុក ជើតសម្តេចលីលា សំណាខម ជើតហើយច្រះ សំណាខ្មែរ សម្តេច សំណាសៀមសុទ្ធ សម្តេចលា បម្រើ ឱតជើត សំណារ ដំណាក សំណារលា សំណារមន ពិលាប ជើតច្រះបណក្ខ ឱតសៀម ច្រមតែង ច្រះបម្រើហើយសំរៀង ជើតឃឹង ថានប្រាក្រាប ច្រះហើយច្រំតែងថាពែនហើយពាតដែក ពាក់ដែក ព្រះលក្សណ៍វានមាលា ច្រះតែង ប្រគំ កែវណក ជន្មា ជើតសំណាសៀម បិនណកឱត បម្រើសំណាដំណាក សម្តេចឱត ច្រះរាម សំណាខ្មែរ ជើតហើយច្រះដុកបទឆា ក្លម់មបទរាយ បទទ្រង់គ្រឿង ជើតបទខឹនម៉ា ផ្គានបទជុំព្រៃ និយាយបទរាយ បទរាយ ជើតបទរាយ ត្រះបទរាយ ភ្លេងបទរាយ ភ្លេងបទគយ និយាយរាយ ស្មើបទរាយ បទពិលាប ឱតបទរាយ រាយ ឱតនិយាយរាយ ឱតរាយ ឱតបទពិលាប បទសោកបទស្ទឹងថង បទនិយាយ ភ្លេងពញ្ញាបទរាយ ណានសី ភ្លេងថយ៉យតរាយ និយាយជើតបទរាយ ភ្លេងពញ្ញាដើរបទរាយ ជើតរាយ ក្រៅ

ណាក ដើតបទធោន ភ្លេងបទតួងព្រះធាតុ និយាយបទឯក ភ្លេងខោម បទរាយ បទយានី ត្រះភ្លេង បទសម័យ ឆន្ទបទរាយ បទឱតលោម ភ្លេងបទរាយឆា ក្អមបទពិលាប ក្រៅណាកបទរាយ។

ចំពោះបទទាំងនេះមានអ្នកសិក្សាខ្លះ (មីសែលត្រាណេ *ការសិក្សារឿងរាមកេរ្តិ៍* ទំព័រ១) យល់ថា *ពាក្យកាព្យរឿងរាមកេរ្តិ៍ មានទំនងបែបជាបទពោល ឬពំនោល សម្រាប់យកទៅសម្តែង ល្ខោន ឬ យី* ។

នៅក្នុងតម្លៃតំណែងនិពន្ធរឿងរាមកេរ្តិ៍ គឺមានតម្លៃផ្សេងៗទៀតជាច្រើន ដែលអ្នកនិពន្ធបានលើកឡើង ដែលក្នុងនោះមានដូចជា៖

- **តម្លៃខចនរូប**

គឺជាតម្លៃដែលគេឱ្យទៅលើការប្រើប្រាស់ពាក្យពេចន៍ដូចជាពាក្យបាលី ពាក្យសំស្ក្រឹត ពាក្យបាលីសំស្ក្រឹត ពាក្យខ្មែរបុរាណ និង មានលាយពាក្យសៀមមួយចំនួនជាដើម។ យ៉ាងណាមិញ នៅក្នុងរឿងរាមកេរ្តិ៍ខ្មែរ ក៏មានពាក្យពេចន៍មួយចំនួនទាក់ទងទៅនឹងភាសាសំស្ក្រឹត ដែលបង្ហាញឱ្យយើងឃើញនូវប្រភពដើមនៃរឿងរាមកេរ្តិ៍ខ្មែរផងដែរ ដែលក្នុងនោះមានដូចជា៖

- **ពាក្យបាលី** ៖ ភូធរ នរបតី ទេពី ពេជ្ឈឃាត ពនាផ្កា សីលភិនេស្រ្ត ...។ល។
- **ពាក្យសំស្ក្រឹត**៖ ជ្វាលា បុស្បុក អសោក ឧទ្យាន ទូរគម រម្យ ភូវនាថ...។ល។
- **ពាក្យបាលីសំស្ក្រឹត** ៖ អធិដ្ឋាន និម្មិត បរិហារ និរន្តរ កលហ.
- **ពាក្យខ្មែរបុរាណ**៖ រូបហាន កុមភ្លើង ខុននាង ទ្រៀវ កំពែង កោន ពឹង ...។ល។
- **ពាក្យសៀម** ៖ ក្លាងមឿង កេងី ខាវ ដៅ(ស្ថាន) ហ្មក ពិន ...។ល។
- **ពាក្យសាមញ្ញ** ៖ អាពុក អញមឹង លោ លោត ដួល ដេក ...។

ក្រៅពីការប្រើប្រាស់ពាក្យខាងលើនេះ ការប្រើប្រាស់ឃ្លាប្រយោគមានលក្ខណៈខ្លី ឆាប់រហ័ស អស់សេចក្តី ត្រឹមត្រូវ គោរពតាមក្បួនកាព្យ និង ក្បួនវេយ្យាករណ៍។

- **តម្លៃសម្ព័ន្ធរូប**

បទកាព្យដែលគេយកមកប្រើក្នុងរឿងរាមកេរ្តិ៍មានច្រើន ហើយមានឈ្មោះផ្សេងៗពីគ្នា ដូចបានរៀបរាប់ខាងលើដែលស្របទៅនឹងបទភ្លេង និងបរិយាកាស។ ក្នុងចំណោមពាក្យកាព្យនោះបើយើងធ្វើការសង្កេតឱ្យហ្មត់ចត់ ឃើញថាជើងកាព្យមានលក្ខណៈដូចគ្នាទៅនឹងបទកាព្យមួយចំនួន គឺ៖

**ក- បែបបទពំនោល** ៖ យើងដឹងហើយថាកាលពីសម័យនោះ យើងពុំទាន់មានឈ្មោះបទពំនោលទេ គឺគេប្រើជាបទសំណាវ បទពិលាប បទដើត ដោយគ្រាន់តែគោរពចំនួនព្យាង្គ ចំនួនឃ្លានិងចំណាប់ចួន ជាបទពំនោលតែប៉ុណ្ណោះ។ ឧទាហរណ៍៖

- **បទសំណារ**៖ ប្រើសម្រាប់រៀបរាប់ឆាក និងព្រឹត្តិការណ៍ផ្សេងៗ មានការបង្ហាញពីឫទ្ធានុភាពកំហឹងក្រេវក្រោធ សង្គ្រាម ចលនារឹករវរ ការភ័យខ្លាច ការអង្វរ ជាដើម។

*“ក្សិណរាមបរមសូរយក្សា    រឹងក្រេវក្រោធា    មហាពន្លឹកមួយសា ។*
*ខេខឹងដ៏ត្រនួនដេះដាល    ហិចហោះបីត្រអាល    ឆ្ពោះទៅថ្កានទ័ពព្រះរាមា។*
*រាមបរមសូរស្រេចដល់ដ៏ចំហុត    ចូលដល់ទ្វារផ្តត់    ក៏ទ្រង់ធនូជឹងសរថ្លា ។*
*ស្រែកស័ព្ទបីសន្ធាប់ឃោសា    ជើងជាន់ពសុធា    តន្ត្រំកក្រើកធរណី ។”*

(វឌ្ឍនាយាវង្ស ***រាមកេរ្តិ៍ខ្មែរ១*** ទំព័រ២៣)

- **បទពិលាប** ៖ប្រើនៅពេលតួអង្គថ្ងូញសោកក្នុងពេលព្រាត់ប្រាស់ ឬ មានទុក្ខព្រួយ ។

*“ម្ដាយសោកសង្រេងឥតស្បើយ    ប្រាសព្រះត្រាណត្រើយ    ពន្លឺពន្លកថ្លើមថ្លៃ។*
*ព្រះភិរុតព្ទព្រះជនកក្សយ័    ញ័រអស់ហឫទ័យ    រន្ធត់ចំប្រប់ប្រះប្រាណ។*
*ដួលដេកសន្លប់លើស្ថាន    ប្រាសាទភិមាន    នាងកៃកេសីមាតា។*
*ទាំងព្រះសុត្រុតអនុជា    សន្លប់ផ្ទាស់មរណា    ព្រមព្រះរៀមរងទុក្ខទល់។”*

(វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្មែរទី២ ទំព័រ៣៧-៣៨)

**ខ- បែបបទព្រហ្មគីតិ** ៖ បទនេះពុំទាន់មានឈ្មោះនៅឡើយទេនៅសម័យនោះ តែចំណាប់ចួន ចំនួនព្យាង្គ និងឃ្លាមានលក្ខណៈដូចបទព្រហ្មគីតិ។

“ទូលថ្ងូញទំនួញថ្លែង    សម្ដែងសោតសល់សោកា
អង្គព្រះរាម    ទៀងទិព្វទេពនៃសន្ធត។
ព្រះជនកអ្នកនរនាថ    ទ្រង់នាមព្រះបាទសំរិទសរថ
ព្រះជននីអ្នកទង់ព្រត    ព្រះនាមនាងកោសកន្យាណ ។

(វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្មែរទី១ ទំព័រ៤៧)

**គ- បែបបទបន្ទោលកាក**៖ នៅសម័យអង្គរពុំទាន់មានបទបន្ទោលកាកនេះទេ តែកាល ខ្លះមានចំណាប់ចុងចួន និង ចំនួនព្យាង្គដូចបទបន្ទោលកាកដែរ។

“ទ្រើសទ្រង់ព្រះចេស្ដា    ស្ដេចស្ដែងឮប្រាកដសាយសព្វ
ទូទ័រទាំងពិភព    ពិមានសួគ៌សោតសឹងខ្លាច ។
ព្រះបាទប្រាជ្ញទេពប្រាជ្ញប្រុះ    ម្ដេចឡើងមកលុះនូវអំណាច
នៃមហាមហឹង្សារាជ    ទូភីកាភ័យកាលា។”

(វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្មែរទី៤ ទំព័រ៦២)

- **តម្លៃបការរូប**

ជាតម្លៃដែលអ្នកនិពន្ធលើកឡើងនៅក្នុងវិធីផ្ដើមរឿង តួរឿង និងបញ្ចប់រឿង ។

**ក- វិធីផ្ដើមរឿង**៖ អ្នកនិពន្ធបានផ្ដើមរឿងតាមបែបព្រហ្មញ្ញសាសនា គឺការហោមពិធី តួយ៉ាងដូចជាអ្នកនិពន្ធបានបង្ហាញថា៖

*"ដងនោះមានអសុរសា- មាន់មួយនាម ហៅកាកនាសូរស្ដែង ។*
*ឮស័ព្ទសង្ខផិជច្រើងថ្កែងង ព្រតព្រះគម្ដែង ឥសូរដ៏រាមឬទ្ធា ។*
*អសុរនោះនិមិត្ររបា ជាកាកមួយសា ហោះហើរនូវតេជបីពន្លឹក ។*
*មកចឹកហោមសាស្ដ្រធម្មិក ឮសព្ទគគឹក ស្លឹកស្មើភ្ញីញ័ររុះរោយ ។ "*

(វឌ្ឍឆាយាវង្ស ***រាមកេរ្ដិ៍ខ្មែរទី១*** ទំព័រ២)

និងការយកវិបត្តិតឹងតែងមកធ្វើជាបុព្វហេតុចាប់ផ្ដើមរឿង ពោលគឺការប្រយុទ្ធរវាងសភាវៈល្អ និងសភាវៈអាក្រក់មកចោទជាបញ្ហាមុននឹងបង្ហាញតួអង្គផ្សេងៗទៀត(វិបត្តិរបស់កាកនាសូរ និងឥសីពិស្វាមិត្រ និងការធ្វើអន្តរាគមរបស់ព្រះរាម) ។

**ខ- វិធីបង្ហាញតួរឿង(តួអង្គ)**៖

- **អ្នកនិពន្ធបានបង្ហាញតួអង្គតាមរយៈតួអង្គបង្ហាញខ្លួនឯង**៖ ដូចជា ព្រះរាមបានប្រាប់រក្សរាមបរមសូរថា៖

*"រីអង្គអញឯងនេះណា កាលបឋមត្រៃកា យុគឡើងនៅជាព្រះនារាយណ៍ ។*

(វឌ្ឍឆាយាវង្ស រាមកេរ្ដិ៍ខ្មែរទី១ ៥.ឯ.ម ទំព័រ២៧)

- តួអង្គបង្ហាញតួអង្គផ្សេងទៀត ៖ ដូចជា នាងសូរបនខាប្រាប់ព្រះរាមថា៖

*"ខ្ញុំជាប្អូនក្រុងរាពណ៍ណា សូរសាយលង្កា យសាធិរាជដ៏ពិពណ៌ ។*
*បងមួយឈ្មោះក្រុងកុម្ភការណ៍ បងមួយចេះធម៌ ហៅឈ្មោពិភេកហោរា ។"*

(វឌ្ឍឆាយាវង្ស ***រាមកេរ្ដិ៍ទី៣*** ទំព័រ៥-៦)

- **ការបង្ហាញតួអង្គដោយអ្នកនិពន្ធខ្លួនឯង** ៖ ដូចជាអ្នកនិពន្ធបង្ហាញពីតួអង្គឥសីពិស្វាមិត្ត៖

*"ដងនោះព្រះមកុដដ៏ភិរម្យ ប្រសើរឧត្ដម ប្រពៃរូពិនមហាក្សត្រ ។*
*បិទបាំងនូវជញ្ជាំងជុំជិត ស្ដម្ភទ្វារដ៏ពិចិត្ត ក្រលាតបៈដុងដោម ។"*

(វឌ្ឍឆាយាវង្ស ***រាមកេរ្ដិ៍ខ្មែរទី១*** ទំព័រ១)

- ការបង្ហាញតួអង្គតាមរយៈដំណើររឿង គឺអ្នកនិពន្ធបានបង្ហាញតួអង្គមហិង្សរាជតាមរយៈដំណើររឿងថា៖

*"មុនមានមហិង្សរាជឃ្មង បរទារពលផង សារឆ្លើយអនេកសំខ្យា ។*
*ដងនោះមហិស្សាសូររាជ ជាតិជាញនូវអំណាច ពីរេន្ទនូវពលមហិមា ។"*

(វឌ្ឍនាយាវង្ស *រាមកេរ្តិ៍ខ្សែទី៤* ទំព័រ៣៧)

**គ. វិធីបញ្ចប់រឿង៖** អ្នកនិពន្ធបានបញ្ចប់រឿងតាមបែបព្រហ្មញ្ញសាសនា គឺសភាវៈល្អឈ្នះសភាវៈអាក្រក់ (ព្រះរាមមានជ័យជំនះលើក្រុងរាពណ៏) និងបែបព្រះពុទ្ធសាសនា គឺអ្នកសាងទង្វើល្អ ទទួលកុសលល្អ អ្នកសាងទង្វើអាក្រក់ទទួលអកុសល(ព្រះរាមត្រូវទទួលរងការព្រាត់ប្រាស់ពីនាងសីតាដោយសារទង្វើខ្វះការពិចារណារបស់ទ្រង់)។

- **តម្លៃឧបកថាវិធី**

ជាតម្លៃនៃវិធីតែងនិពន្ធមួយបែប ដែលកវីនិពន្ធប្រើដោយនិយាយរៀបរាប់ពីព្រិត្តិការណ៍អ្វីមួយមិនទាន់ចប់សេចក្តីផង ក៏ផ្អាកមួយខណៈហើយក៏ចាប់និយាយរៀបរាប់ព្រិត្តិការណ៍ថ្មីមួយទៀតបន្ត ពោលគឺការបែងចែកដំណើរឿងជាដំណាក់ៗ ជាខ្សែ ជាវគ្គ ដោយផ្សាយដំណើររឿងមួយហើយលើកយកដំណើររឿងមួយផ្សេងទៀតមកនិយាយបន្តវិញ។

ឧទាហរណ៏៖

-អ្នកនិពន្ធបានចែករឿងរាមកេរ្តិ៍ជាខ្សែ ដែលមានទាំងអស់ចំនួន៨០ខ្សែ។

-នៅក្នុងរឿងរាមកេរ្តិ៍ខ្សែទី៤ ដើមដំបូងអ្នកនិពន្ធនិយាយពីដំណើរព្រះរាមតាមរកនាងសីតាបន្ទាប់ពីក្រុងរាពណ៏ឆក់យកទៅ ហើយដំណើររឿងនេះមិនទាន់ដឹងសេចក្តីអស់ផងស្រាប់តែអ្នកនិពន្ធស្លេះពីការតាមរកនាងសីតា បែទៅជានិយាយរឿងស្តេចក្របីមហិង្សារាជដែលជាស្តេចទ្រើសឃ្នងដោយសម្លាប់កូនឈ្មោលទាំងអស់ ដែលនៅទីបំផុតក្របីនោះត្រូវបានកូនរបស់ខ្លួនឈ្មោះទូភី សម្លាប់បាន ហើយទូភីនោះ ក៏ទៅច្បាំងជាមួយនឹងពាលីជាស្តេចស្វាទៀត។

- **តម្លៃបដិវិធី**

ជាវិធីតែងនិពន្ធមួយបែបដែលអ្នកនិពន្ធធ្វើអោយមានភាពផ្ទុយគ្នាពីមួយទៅមួយ

ឧទាហរណ៏៖

-កូខ័នមានរូបអាក្រក់ ក្លិនស្អុយឆ្អេះឆ្អាប តែមានសណ្តានចិត្តល្អ។

-ខាងរាពណ៏ជ្រុលច្រល់ ខាងព្រះរាមស្ងាត់ស្ងៀម។

-ខាងរាពណ៏ឱ្យព័ត៌មានខុស ឆាប់សប្បាយ

-ខាងព្រះរាមឱ្យព័ត៌មានត្រឹមត្រូវគឺឈ្នះ។

-កុមារពីរនាក់ច្បាំងជាមួយទ័ពមួយនគរ ជាដើម។

- **តម្លៃឧបមាណវិធី**

ជាវិធីតែងនិពន្ធមួយបែបដែលអ្នកនិពន្ធធ្វើការប្រៀបធៀបអ្វីមួយ ទៅនឹងអ្វីមួយទៀត។ ដូចជា ៖

ព្រះរាមបានប្រៀបធៀបថា៖

*“អង្គអញឯងដូចផ្កាច្បារ　　ជាស្គ័រធានា　　អាចអត់នូវកម្ដៅអគ្គី ។*
*ននោងនោះគឺនាងសីតាទេពី　　ចម្បាដ៏ពិសី　　គឺព្រះលក្ស្មណ៍អនុជា ។*
*នាយើងទាំងបីអង្គារ　　ឯកចិត្តចិន្តា　　ដូចស្គ័រនូវមាសនោះហោង ។*
*រីកន្លង់នោះគឺផ្សុងផង　　ជាមន្ទិលផង　　ដូចពាក្យនាងកែកេសី ។”*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី២ ទំព័រ៣-៤)

មួយនោះដូចថៅភិរុត មួយទៀតប្រាកដ ដូចថៅសុគ្រីតប្អូនអញ?

- **តម្លៃពណ៌នាវិធី**

ជាវិធីតែងនិពន្ធមួយបែបដែលអ្នកនិពន្ធរៀបរាប់ ពីអ្វីមួយដូចជាមនុស្ស ធម្មជាតិជាដើម ។

ឧទាហរណ៍៖ នៅពេលព្រះរាមចេញពីកូខ័ន អ្នកនិពន្ធបានរៀបរាប់ពីព្រៃ ព្រឹក្សាថា

*“ស្លឹកខ្លះខ្លោច ខ្លះបីក្រហម　　ស្បូវស្មៅក្រែងទ្រោម វិនាសនូវភ្លើងព្រៃដាល ។*
*តេជៈព្រះបាទភាវនា　　ពង្សពោធិសម្ភារ　　ក៏នាំទេពីលេលា ។*
*មើលមានព្រៃព្រឹក្សសាខា　　សងខាងមាគ៌ា　　សឹងប្រែត្រជាក់ដ៏សប្បាយ ។*
*លូតលាស់មាលាលេចលាយ　　ដុះដាសរៀងរាយ　　រូបហានរបៀបអភិរម្យ ។”*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី២ ទំព័រទី១)

- **តម្លៃឯកវាទវិធី**

ជាវិធីតែងនិពន្ធមួយបែបដែលអ្នកនិពន្ធប្រើ ដោយធ្វើឱ្យតួអង្គនិយាយថ្លែងពីទុក្ខព្រួយឬរៀបរាប់ពីអនុស្សាវរីយ៍តែម្នាក់ឯង នឹកគិតតែម្នាក់ឯង ដោយគ្មាននរណាចូលលាយឡូកឡំឡើយ ។

ឧទាហរណ៍៖ ព្រះរាមនឹកដល់សីតាតែម្នាក់ឯងថា

*“ឱថ្មើរណេះណាផ្ដំលក់　　ឬប្អូនទល់ទុក្ខសៅហ្មង*
*ឬមួយប្អូនក្រោធនឹងបង　　ឬមួយរសាយក្រោធា ។*
*ឱបងនេះគិតឆ្ងាយឆ្ងល់　　ហេតុតែអកុសលផងគ្នា*
*ឱ្យប្រាសប្អូនមាសឃ្លាតឃ្លា　　និរាសចាកចោលបងទៅ ។”*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី៧៩ ទំព័រ៣៥)

និង ជប្បលក្ស្មណ៍នឹកដល់រាមលក្ស្មណ៍ជាបងតែម្នាក់ឯងថា៖

*“ទូញថាឱព្រះបាទបង　　ម្ដេះសមស្ដេចរងភិតភ័យ*
*ជារស់ឬមួយក្សិណក្ស័យ　　ប្អូនពុំបានយល់ភក្ត្រា*
*.................................　　...............................*

*ឱម្លេះប្អូនវិលទៅដល់　　　ព្រះមាតាយល់ហើយណា*
*សួររកព្រះរៀមចេស្ឋា　　　ជ្រាបហើយសោយសោកស្មើរក្ស័យ។"*

(វឌ្ឍឆាយវង្ស រាមកេរ្តិ៍ខ្សែទី៧៧ ទំព័រ៣៤-៣៥)

ក៏ដូចជាការទូញសោករបស់នាងសីតាដែលបង្ហាញពីព្រហ្មវិហារធម៌របស់នាង ការនឹកអាឡោះអាល័យបុត្រនៅពេលដែលបុត្រឃ្លាតទៅជាដើម។

- **តម្លៃសំភាសនវិធី**

ជាវិធីតែងនិពន្ធមួយបែបដែលអ្នកនិពន្ធប្រើ ដោយតម្រូវឱ្យតួអង្គនិយាយ ជជែកសន្ទនា ឆ្លើយឆ្លងគ្នាទៅវិញទៅមក។

ឧទាហរណ៍៖

- ព្រះរាមសួរព្រះលក្ស្មណ៍ដែលមកតាមខ្លួន តើសីតានៅជាមួយអ្នកណា?
- ការជជែកគ្នារវាងពិភេកនិងកុម្ភការណ៍ ដើម្បីបង្ហាញថាតើអ្នកណាខុស អ្នកណាត្រូវ?
- ការដែលពិភេកទូលព្រះរាមពីឫទ្ធានុភាពរបស់កុម្ភការណ៍ សីតានិយាយប្រាប់កូនពីចិត្តឃោរឃៅរបស់ព្រះរាមជាបិតា។

ការសន្ទនារវាងហនុមាននិងសីតា និង ការសន្ទនារវាងស្តេចនាគនិងហនុមានជាដើម។

*"កាលនោះឯព្រះមាតា　　　ស្តាប់បុត្រពុំងារស្នេហ៍ស្នង*
*ទូលថាព្រះរាមច្បាស់ច្បង　　　ឱ្យមកទទួលច្នេះណា។*
*នាងខ្វាល់ពិតពុំមានក្សាន្ត　　　បន្ទូលទៅថ្កានវិញថា*
*កូនអើយម្តាយអរនឹងបា　　　បានមកដល់ម្តាយនេះនៃ។"*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ទី៨០ ទំព័រ៣)

- **តម្លៃសន្ទេហវិធី**

ជាវិធីតែងនិពន្ធមួយបែបដែលអ្នកនិពន្ធធ្វើឱ្យ អ្នកអាន អ្នកស្តាប់ មានការងឿងចង់តាមដានតទៅទៀតដូចជា៖

- តើរាពណ៍ឆក់យកនាងសីតាបានឬមិនបាន?
- ពេលដែលរាពណ៍ចាប់នាងសីតាទៅ តើព្រះរាមតាមរកនាងឃើញឬទេ?
- ពេលជតាយុប្រយុទ្ធជាមួយរាពណ៍ តើព្រះរាមមកទាន់ឬមិនទាន់?
- សុគ្រីពបិទរូងភ្នំ តើពាលីចេញរួចឬពុំរួច?
- ពេលដែលពិភេករត់ចេញពីនគរទៅសុំចុះចូលនឹងព្រះរាម តើព្រះរាមព្រមទទួលឬទេ?
- តើហនុមានទៅសុំកាឡាព្រះនារាយណ៍បានឬទេ?

- ពេលដែលព្រះរាមឱ្យពិភេកទៅបញ្ចុះបញ្ចូលកុម្ភការណ៍ តើកុម្ភការណ៍ព្រមចុះចូលឬទេ?
- ពេលព្រះលក្ស្មណ៍ប្រយុទ្ធនឹងឥន្ទ្រជិត ហើយត្រូវរបួសសន្លប់បាត់ស្មារតី តើព្រះលក្ស្មណ៍ស្លាប់ឬរស់?
- ពេលពិភេកឱ្យហនុមានទៅរកថ្នាំព្យាបាលព្រះលក្ស្មណ៍ តើហនុមានរកថ្នាំនោះបានឬទេ?
- តើរាពណ៍ស្លថ្នាំពិសេសបានឬមិនបាន? តើរាពណ៍តាំងសិល្ប៍បានសម្រេចឬមិនបានសម្រេច?
- តើរាពណ៍ធ្វើដូចម្ដេចទៀត ដើម្បីបន្តសម្បាំងបើកូនក៏ដូចជាមេទ័ពនិងទ័ពស្លាប់អស់ហើយ?
- តើព្រះរាមចាប់ព្រះរាចកុមារបានឬទេ?
- តើព្រះរាមច្បាំងប្រហាររាជកុមារបានជោគជ័យឬទេ?
- តើនាងសីតាព្រមជានានឹងព្រះរាមដែរឬទេ?
- តើនាងសីតាសុខចិត្តវិលចូលនគរដែរឬទេ?
- តើព្រះរាមប្រើឧបាយយ៉ាងណា បើនាងសីតាមិនព្រមជានានឹងព្រះរាមវិញ?... ជាដើម។

- **តម្លៃវឌ្ឍមានវិធី**

ជាវិធីតែងនិពន្ធមួយបែបដែលអ្នកនិពន្ធធ្វើឱ្យដំណើររឿងមានការណ៍រីកចម្រើនពីធូរស្រាលទៅតានតឹង (កាន់តែតឹងតែងឡើងៗ) និងពីតានតឹងទៅធូរស្រាល។ តួយ៉ាងដូចជាអ្នកនិពន្ធបានបង្ហាញពីសេចក្ដីភ័យព្រួយរបស់រាពណ៍ ដែលមានសភាពកាន់តែតឹងឡើងៗ ដូចជាពីដំបូងអង្គទសំឡុតយក្សទូទៅ តមកសំឡុតឃ្លាំងមឿង សំឡុតអ្នកចាំទីក្រុង សំឡុតរាពណ៍បន្តិចម្ដងៗ(ដំបូងអង្គុយស្មើកុម្ភការណ៍ រួចអង្គុយស្មើឥន្ទ្រជិត ហើយអង្គុយស្មើរាពណ៍តែម្ដង ទើបនិយាយបង្គាប់រាពណ៍ និងទះកំផ្លៀងរាពណ៍ឱ្យដួលតែម្ដង)។

កូនរាពណ៍ទាំងដប់ត្រូវស្លាប់អស់ សូម្បីតែមេទ័ពក៏ស្លាប់គ្មានសល់។

*“បង់បុត្រទាំងទសសូន្យក្សយ័ បង់កុម្ភការណ៍ក្រៃ ប្រល័យទាំហមុខមន្ត្រី។*
*សេនាយោធាធិបតី ពលសុពណ៌ពី កាយានៃយានយក្សា។*
*សឹងសូនសោះទាល់អាត្មា ផេងទាំងលង្កា មហានាសមាផល។*
*ទសមុខខំទាំងទល់ ទុក្ខផ្ទេះដ៏ក្រវល់ ក៏ភ្ជុំអសុរសេនា។”*

(វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្មែរទី១០ ទំព័រ៤៧-៤៨)

- **តម្លៃផ្ទួនពាក្យវិធី**

ជាវិធីតែងនិពន្ធមួយបែបដែលអ្នកនិពន្ធបានលើកយកពាក្យដដែលៗមកសរសេរដើម្បីបញ្ជាក់ន័យឱ្យកាន់តែច្បាស់។

*"ស្តេចដ៏ស្តេចជាន់ស្តេចធាក់ ស្តេចច្រានស្តេចចាក់ ស្តេចហែករុះរោយបោះបង់។"*

(វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្មែរទី៤ ទំព័រ៣២)

- **តម្លៃរណ្តំព្យញ្ជនៈវិធី**

នេះក៏ជាវិធីសំខាន់មួយដែរព្រោះវាជាវិធីតែងនិពន្ធមួយបែបដែលកវីនិពន្ធមិនអាចរំលងបាន។ វិធីនេះជាវិធីមួយធ្វើឱ្យកំណាព្យមានសូរសៀងណែងណង ស៊ីចង្វាក់គ្នា និងកាន់តែពីរោះថែមមួយកម្រិតទៀតដូចជា៖

"ខុនខែងខឹងខូនខឹងខាំ" (វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្មែរទី៤ ទំព័រ៣២)។

- **តម្លៃបុនរុត្តវិធី**

ជាវិធីតែងនិពន្ធមួយបែបដែលអ្នកនិពន្ធរៀបរាប់ដំណើររឿងដដែលៗ ឡើងវិញដូចជា៖ កាលបើដឹងថាមេទ័ពមួយស្លាប់ហើយ រាពណ៍តែងតែមានទុក្ខសោក និងចាត់ឱ្យមេទ័ពម្នាក់ទៀតចេញទៅច្បាំងជាបន្តៗ រហូតស្លាប់អស់មេទ័ព និងទ័ព។

## ខ.តម្លៃសិល្ប៍រូបារម្មណ៍វិធី

ជាវិធីសាស្ត្រក្នុងការឆ្លុះបញ្ចាំងតថភាពវត្ថុវិស័យរបស់អ្នកនិពន្ធ ពោលគឺអ្នកនិពន្ធបង្កើតនូវសិល្បវិធីដ៏រស់រវើកផ្សេងៗពីគ្នាដើម្បីធ្វើឱ្យសម្រស់សាច់រឿងកាន់តែល្អស្រស់ គួឱ្យចាប់ចិត្តដិតអារម្មណ៍ចង់តាមដាននិងមានភាពរីករាយ ព្រោះស្នាដៃដេលខ្វះសិល្ប៍រូបារម្មណ៍វិធីគឺជាស្នាដៃដែលពុំទាន់មានលក្ខណៈជាអក្សរសិល្ប៍នៅឡើយ។ យ៉ាងណាមិញនៅក្នុងការតាក់តែងស្នាដៃរឿងរាមកេរ្តិ៍ អ្នកនិពន្ធបានបង្កប់នូវសិល្ប៍រូបារម្មណ៍វិធីយ៉ាងរស់រវើកដូចជាការបង្ហាញពីសកម្មភាពព្រះរាមផ្ចាញ់ក្រុងកម្ព័នជាដើម៖

*ស្តេចដំស្តេចជាន់ស្តេចធាក់ ស្តេចច្រានស្តេចចាក់ស្តេចហែករុះរោយបោះបង់។*
*ឈាមហូរជ្រោះថ្លាយង់ ជោរជន់លិចលង់ រហូតសមុទ្រជលធិ។*

ក៏ដូចជាការបង្ហាញពីរូបរាងនិងកម្លាំងទូភីថា ទូភីផឹកម្តងអស់បីបឹង ស៊ីស្មៅម្តងអស់បីវាលជាដើម។

នៅក្នុងតម្លៃសិល្ប៍រូបារម្មណ៍វិធី មានតម្លៃផ្សេងៗទៀតជាច្រើនដូចជា៖

- **តម្លៃសិល្ប៍ឥន្ទ្រីយ៍រូបារម្មណ៍**

ជាតម្លៃនៃវិធីរបស់អ្នកនិពន្ធដែលកើតចេញមកអំពីការប្រើប្រាស់ពាក្យសម្ដី ឃ្លាប្រយោគ ធ្វើឱ្យរំភើបដល់ឥន្ទ្រីយ៍ទាំងឡាយមានដូចជា ភ្នែក ត្រចៀក ច្រមុះ មាត់ និងកាយជាដើម ពោលគឺជាវិធីមួយដែលអ្នកនិពន្ធបង្កើតនូវអ្វីមួយទាក់ទងទៅនិងឥន្ទ្រីយ៍ទាំងប្រាំរបស់មនុស្ស។

- **ចក្ខុរូបារម្មណ៍**៖ គឺជារូបារម្មណ៍សិល្បៈដែលជាប់ទាក់ទងទៅនឹងចក្ខុ(ភ្នែក) តាមរយៈពាក្យពេចន៍ ឃ្លាប្រយោគដែលធ្វើឱ្យចក្ខុន្ទ្រីយ៍ មានអារម្មណ៍រំភើបដូចបានឃើញច្បាស់នឹងភ្នែក ពោលគឺអ្នកនិពន្ធចេះប្រើវិធីសាស្ត្ររៀបរាប់ពាក្យពេចន៍ ឃ្លាប្រយោគធ្វើឱ្យអ្នកអានអ្នកស្ដាប់ហាក់ដូចជាបានឃើញនឹងភ្នែកនូវហេតុការណ៍ដែលកើតមានឡើង នូវទេសភាពធម្មជាតិនានា ឬ នូវរូបរាងពណ៌សម្បុរជាដើម ដូចក្នុងដំណើររឿងរបស់អ្នកអម្ចាស់(វេឡាឆាយាវង្សខ្សែទី៧៦ ទំព័រ១៤-១៥ បានបញ្ជាក់ថា៖

*ស្ដេចពីរព្រះងង្គសីហនាទ ទតអស់រុក្ខជាតិនានា*
*ត្រសំបុត្រសាយសាខា ត្រឈឹងត្រឈៃឈរ។*
*ទ្រង់ផលស្រគាលចាស់ក្ដិប ខ្លះរុះស្រទាប់កេសរ*
*ព្រះពាយផាត់ផាយខ្ចាយខ្ចរ ពិដោរគន្ធរសបុប្ផា។*
*ស្ដេចទ្រង់ដោយដងគិរី ជ្រោះច្រកទូរទិសិលា*
*មានអូរទឹកហូរជ្រះថ្លា ស្ដេចសោយសម្រាន្តព្រះកាយា។*

- **សោតរូបារម្មណ៍**៖ ជារូបារម្មណ៍សិល្បៈដែលកើតឡើងតាមរយៈការប្រើប្រាស់ពាក្យពេចន៍ឃ្លា ប្រយោគ ដែលធ្វើឱ្យអ្នកអាន អ្នកស្ដាប់ហាក់ដូចជាផ្គរ រន្ទះ ខ្យល់ ទឹកធ្លាក់ជាដើម។

ឧទាហរណ៍

*"ស្ដេចលើកកៅទ័ណ្ឌសហស្សថាម បាញ់បាននៃស្ថាន កណ្ដាលជំនុំឥសី។*
*ឮខ្ទារខ្ទរទាំងប្រពី ឮស័ព្ទអសនី គឺសែនរន្ទះគណនា។'*

(វេឡាឆាយាវង្ស រាមកេរ្តិ៍ខ្សែទី១ ទំព័រ១២)

- **ឃានរូបារម្មណ៍**៖ ជារូបារម្មណ៍សិល្បៈដែលកើតឡើងតាមរយៈការប្រើប្រាស់ពាក្យពេចន៍ឃ្លាប្រយោគ ដែលធ្វើឱ្យអ្នកអាន អ្នកស្ដាប់ហាក់ដូចជាបានស្រង់នូវក្លិនទាំងឡាយ មានដូចជាក្លិនពិដោរនៃបុប្ផាដែលមាននៅក្នុងដំណើររឿងដោយផ្ទាល់។

ឧទាហរណ៍

*"ទ្រង់ផលស្រគាលចាស់ក្ដិប ខ្លះរុះស្រទាប់កាសរ*
*ព្រះពាយផាត់ផាយខ្ចាយខ្ចរ ពិដោរគន្ធរសបុប្ផា។"*

(វណ្ណឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី១ ទំព័រ១២)

- **ជីវ្ហារូបារម្មណ៍**៖ ជារូបារម្មណ៍សិល្បៈដែលលកើតឡើងតាមរយៈការប្រើប្រាស់ពាក្យពេចន៍ឃ្លាប្រយោគដែលធ្វើឱ្យអ្នកអាន អ្នកស្ដាប់ហាក់ដូចជាបានភ្លក់នូវរសជាតិអ្វីមួយដែលអ្នកនិពន្ធបានពន្លេចឱ្យចេញឡើងជារសជាតិ ជូរ ចត់ ល្វីង ផ្អែម ប្រៃ ជាដើម។

ឧទាហរណ៏

*“មានទាំងឱជារសអាហារ ច្រើនពណ៌ប្រការ គ្រកាលអនេកនានា។*
*មានឃ្មុំសាច់សាភ្លា វុក្ខមូលបុប្ផា អធិកផលាផង។”*

(វណ្ណឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី១ ទំព័រ៥៦)

- **កាយរូបារម្មណ៍** ៖ ជារូបារម្មណ៍សិល្បៈដែលកើតឡើងតាមរយៈការប្រើប្រាស់ពាក្យពេចន៍ឃ្លាប្រយោគដែលធ្វើឱ្យអ្នកអាន អ្នកស្ដាប់ហាក់ដូចជាបានប៉ះ បានស្ទាប បានអង្អែលនូវរូបរាងអ្វីមួយ ដូចជារលោង ទន់ល្មើយ ស្រឡូន ក្ដៅ ត្រជាក់ ជាដើម។

ឧទាហរណ៍:

*បងចាំកេសីបីខ្មៅញាប់ ប្អូនក្រសោបចាប់ចងចាផ្កា*
*កែមចួតប្រួតមាលា អស់ផ្កាសរពើភ្ញី។*
*............................ ...............................*
*បងចាំចង្កេះមួយក្ដាប់ ក្រសោបចាប់ព្រហស្ដជុំ*
*ដោះរូវផ្លែទម្លាប់មាសទុំ បីចិត្តស្រទាប់ផ្ដាប់លើឧរាន្លៃ។*

(វណ្ណឆាយាវង្ស ***រាមកេរ្តិ៍ខ្មែរទី៤*** ដ.ឯ.ម ទំព័រ២៥-២៦)

- **តម្លៃសិល្ប៍និមិត្តរូបារម្មណ៍**

ជារូបារម្មណ៍សិល្បៈដែលមានលក្ខណៈទូទៅ ឬ លក្ខណៈតំណាងដើម្បីបង្ហាញពីគំនិត ទស្សនៈ គោលបំណង ព្រឹត្តិការណ៍ ឬ បាតុភូតនៃធម្មជាតិដែលមានទំនាក់ទំនងទៅនឹងន័យសព្ទវិទ្យាដែលជួនកាលនិមិត្តរូបារម្មណ៍នេះស្ថិតនៅក្នុងអត្ថបទទាំងមូល ជួនកាលស្ថិតនៅក្នុងផ្នែកណាមួយនៃអត្ថបទ តាមរយៈការលើកយកពាក្យពេចន៍សាមញ្ញមកប្រើសម្រាប់សម្គាល់ ឬបង្ហាញមតិយោបល់ គំនិត ទស្សនៈណាមួយ។ យ៉ាងណាមិញ នៅក្នុងរឿងរាមកេរ្តិ៍ តាមរយៈតួអង្គពិតរក្ខ័ស ដែលជាអាមាត្យរបស់ក្រុងរាពណ៍ បានយកពាក្យពេចន៍សាមញ្ញមកបញ្ចេញទស្សនៈទូលជំទាស់ក្រុងរាពណ៍ដែលចង់សម្លាប់នាងសីតាចោល នៅពេលដែលខ្លួនត្រូវបានបាត់បង់អាយុជីវិតកូនក៏ដូចជាមេទ័ពសំខាន់ៗជាបន្តបន្ទាប់។

*ដងនោះមានមុខមន្ត្រី មួយទៀងចេះក្ដី ពុំមើលបំណាំអម្ចាស់។*
*អាមាត្យនោះឈ្មោះពិតរក្ខ័ស ក្រាបបាទទូលទាស់ ទំនៀមក្ដីឧបមា។*

..................................... ............................ ..........................

*ទោះបៀតសីតាឱ្យអន្តរាយ ព្រះរាមទេពនាយ នូវដាច់អ្វីឯព្រះអង្គ ។*
*ព្រះរាមដូចព្រឹក្សាទ្រង់ ដុះដើមខ្ពង់ខ្ពស់ ទ្រឈើងទ្រឈៃសាខា ។*
*សីតាដុចវល្លិមួយណា ដុះក្រោមព្រឹក្សា លំពែនលំពង់វល្លិព័ន្ធ ។*
*ទោះនាបៀនឈើនោះឱ្យបាត់ រោចតែវល្លិកាត់ ឈើនោះពុំដែលអន្តរាយ ។*

....................................... ..................... ........................................

*ពស់នោះគឺព្រះរាមា សកដូចសីតា ទេពីស្រីរត័ន៍មាតយាទ*
*ទោះបីនូវបៀតបៀនសីតាឱ្យឃាត សីតាពុំអាត ពុំងាមង្គលចម្រើនរាជា ។*

(វឌ្ឍនាយាវង្ស ***រាមកេរ្តិ៍ខ្មែរទី១០*** ទំព័រ ១០-១២)

- **តម្លៃសិល្ប៍បញ្ញារូបារម្មណ៍**

ជារូបារម្មណ៍ដែលកើតឡើងដោយសារបញ្ញាញាណឬមនោដោយការត្រិះរិះពិចារណា ធ្វើឱ្យសិល្ប៍សញ្ចេតនារបស់ប្រធានវិស័យទទួលនូវអារម្មណ៍រំភើបញាប់ញ័រ ហើយវិចារណៈនេះបានផ្សារភ្ជាប់ពីមតិមួយទៅមតិមួយទៀត ចងឃ្លាឱ្យមានទំនាក់ទំនងគ្នាតាមគំនិតផ្សេងៗ

*"កើតជាក្សត្រខ្សោយខ្លៅខ្លាច ចិត្តចង់រក្សារាជ ពុំអាចដណ្តើមចេស្តា ។*
*អះហៅសរិលសត្វលោកា ពុំដែលចៀសកាឡា ព្រះម្រឹត្យូវនូវយកប្រាណ ។*
*ទោះបីនៅសុខសួស្តីក្សេមក្សាន្ត ពុំដែលហៅមាន អាយុយូរយឺនរួចកាល ។*
*អំណាចទូរយល់ទូរទាល់ អនេកសង្ខេយ្យកល្ប៍ អ្នកផងដែលដៀលថាខ្លាច ។"*

(វឌ្ឍនាយាវង្ស ***រាមកេរ្តិ៍ខ្មែរទី៣*** ទំព័រ២១)

- **តម្លៃសិល្ប៍ចេតនារូបារម្មណ៍**

ជារូបារម្មណ៍សិល្បៈដែលកើតឡើងអាស្រ័យដោយការបំផុសនូវមនោសញ្ចេតនា ដូចជាទុក្ខព្រួយ រីករាយ សប្បាយ កំហឹង ការភ័យខ្លាច ការប្រចណ្ឌ ការអាលោះអាល័យ ការសោកស្តាយ ការសង្ឃឹម ការអស់សង្ឃឹមឬក៏ការបំផុតនូវជំនឿចំពោះលទ្ធិនយោបាយ សាសនា មនោគមវិជ្ជាណាមួយ ក្នុងគោលបំណងបង្កើតបរិយាកាសចំពោះអ្នកអាន អ្នកស្តាប់ ។

*ព្រះហស្តអង្អែលឱបអនុជ ព្រះកន្សែងសោកាក្តាត់*
*ក្តៅហឫទ័យរន្ធត់ បាត់ស្មារតីតម្រង់ថ្លែង ។*

.............................. ...................................

*បានិត្យនឹងបងដូច ស្រមោលដ៏ជិតដោយខ្លួន*
*ម្លេះហើយមកជួន ចំហុតបង់កាតាស្និទ្ធ ។*

(វឌ្ឍនាយាវង្ស ***រាមកេរ្តិ៍ខ្មែរទី៩*** ទំព័រ១៥-១៦)

ដូច្នេះតាមការសិក្សាពីតំណែងនិពន្ធយើងឃើញថា អ្នកនិពន្ធរឿងរាមកេរ្តិ៍ខ្មែរយើងគឺជាកវីនិពន្ធម្នាក់ដែលពោរពេញទៅដោយទេពកោសល្យខ្ពស់ ក្នុងការតាក់តែងរឿងប្រកបទៅដោយភាពច្នៃប្រឌិតនិងទេពកោសល្យ។

## គ.តម្លៃរឿងរាមកេរ្តិ៍ជាគំរូនៃការតែងនិពន្ធ

តាមការលើកឡើងបង្ហាញពីអត្តរូបប្បត្តិតំណែងនិពន្ធខាងលើយើងឃើញថា ឯកសាររឿងរាមកេរ្តិ៍របស់អ្នកអង្គម្ចាស់ ***វឌ្ឍនាយាវង្ស*** គឺជារឿងមួយដែលសមជាគំរូនៃរឿងដទៃ។ ហេតុនេះហើយបានជាគេយកឯកសាររឿងរាមកេរ្តិ៍នេះ ទៅបញ្ចូលក្នុងកម្មវិធីសិក្សាបច្ចុប្បន្ននេះ ព្រោះថា ការតាក់តែងរបស់អ្នកនិពន្ធពោរពេញទៅដោយសិល្បវិធីដ៏រស់រវើក ភាពច្នៃប្រឌិតប៉ិនប្រសប់ដោយធ្វើឱ្យដំណើរមានភាពស៊ីចង្វាក់គ្នានិងរលូនទៅតាមដំណើរ ដូចជាដំបូងឡើយអ្នកនិពន្ធបានលើកឡើងបង្ហាញពីព្រះរាមជាតួអង្គក្សត្រប្រកបដោយភាពជោគជ័យ (សភាវល្អ) និង មានការផ្ដាញ់ផ្ដាលពីសំណាក់ពួកយក្ស(សភាវអាក្រក់)ផង និង ការផ្ដាញ់ផ្ដាលពីសំណាក់មនុស្សលោកផង គឺព្រះរាមបរាជ័យក្នុងផ្លូវលោកដោយទ្រង់មិនអាចឡើងគ្រងរាជ្យបានដោយសារតែទង្វើរបស់នាងកៃកេសីដែលជាម្ដាយចុង ដែលមានចិត្តលោភលន់ទ្រព្យសម្បត្តិ ក្បត់បវេណី ប៉ុន្តែព្រះរាមមានជ័យជម្នះខាងផ្លូវចិត្តដោយទ្រង់ចេះគោរពនូវពាក្យសច្ចៈរបស់ព្រះរាជបិតាគឺព្រះបាទទសរថ។ ម្យ៉ាងវិញទៀត អ្នកនិពន្ធចេះបង្កើតនូវបញ្ហារបស់មនុស្សដែលតែងកើតមាននៅក្នុងសង្គមយកមកច្របាច់បញ្ចូលគ្នាជាដំណើររឿងគួរជាទីចាប់ចិត្តដិតអារម្មណ៍ ចង់តាមដាន និងចង់ទស្សនា ដូចជាការប្រើឧបាយកលរបស់រាពណ៍ ដែលបាញ់មួយគ្រប់បានសត្វពីរ គឺការដែលរាពណ៍ឱ្យមហារីកកាឡាខ្លួនជាប្រើសមាស គឺអាចនឹងធ្វើឱ្យខ្លួនលួចបានទាំងប្រពន្ធនិងអាចប្រហារព្រះរាមបាន។ តាមរយៈទង្វើនេះផងដែរ អ្នកនិពន្ធចង់ឆ្លុះបញ្ចាំងឱ្យឃើញពីភាពទន់ខ្សោយខាងផ្លូវចិត្តរបស់បុរស ដែលរមែងតែងតែលង់តាមសម្ដីលួងលោម ឬសម្ដីញុះញង់ បង្ខិតបង្ខំរបស់ស្ត្រី ព្រោះព្រះរាមដឹងថាជាយក្សកាឡាដែរ តែព្រះរាមនូវតែតាមទៅបាញ់ទាល់តែខកខ្លួនដែលចំណុចនេះបានបង្ហាញពីអាវុធ (សម្ដីរបស់ស្ត្រី) ដែលប្រៀបដូចជាពិសចាក់ទម្លុះបេះដូងបុរស។ ម្យ៉ាងវិញទៀត ដើម្បីបង្ហាញឱ្យឃើញកាន់តែច្បាស់ពីសម្ដីជាអាវុធនេះ អ្នកនិពន្ធបានរំលេចថែមពីកត្តាគ្រោះថ្នាក់ដោយសារសម្ដី តាមរយៈតួអង្គជតាយុ គឺសម្ដីជាអាទិ៍កន្លង បានសុខទុក្ខផងពីព្រោះអណ្ដាត (ជតាយុបាននិយាយទៅកាន់រាពណ៍ថាខ្លួនមិនខ្លាចអ្វីទាំងអស់ ខ្លាចតែព្រះទម្រង់នាងសីតាតែប៉ុណ្ណោះ ដែលធ្វើឱ្យរាពណ៍ឮហើយ ក៏ដោះចិញ្ចៀនពីដៃនាងសីតា គប់ប្រហារជតាយុតែម្ដង)។

តាមរយៈសកម្មភាពស្វែងរកនាងសីតាដោយភ្ជាប់នឹងការប្រយុទ្ធរវាងទូភីនិងពាលី រវាងពាលីនិងសុគ្រីពវិញនោះ រឹតតែធ្វើឱ្យការតាក់តែងរបស់អ្នកនិពន្ធកាន់តែមានតម្លៃសំខាន់ចំពោះវិធីតែងនិពន្ធថែមទៀត ពោលគឺគេចាត់ទុករឿងនេះជាគំរូមួយក្នុងការតភ្ជាប់បញ្ហាផងដែរ។ យ៉ាងណាមិញ ការបង្ហាញពីចំណុចចាប់ផ្ដើមនៃទំនាក់ទំនង ក៏ដូចជាការបំពេញគ្នាទៅវិញទៅមករវាងព្រះរាមនិងសុគ្រីព គឺព្រះរាមរកកម្លាំងទ័ពដើម្បីទៅតាមយកសីតាមកវិញ ឯសុគ្រីព គឺសងសឹកចំពោះពាលីដែលពុំស្ដាប់ហេតុផល និងតាមវាយធ្វើបាបខ្លួន ពោលគឺអាស្រ័យដោយអ្នកទាំងពីរមានការបំពេញគ្នាទៅវិញទៅមកដូចគ្នា ទើបបានជាបង្កើតជាកិច្ចសហការគ្នា និងជាហេតុបន្តដំណើររឿងទៅមុខទៀតបាន ដែលសឱ្យឃើញពីសិល្បវិធីដ៏សម្បូរបែបរបស់អ្នកនិពន្ធក្នុងការតាក់តែងរឿងរាមកេរ្តិ៍នេះ ជាពិសេសគឺការចេះយកភាពអច្ឆិរយៈមកបន្តជាសាច់រឿង។ ប្រសិនបើ អ្នកនិពន្ធមិនបង្ហាញពីឫទ្ធានុភាពអស្ចារ្យរបស់ព្រះរាមដែលអាចផ្លែងសររម្លាយសាកសពទូភី និងកម្ទេចដើមត្នោតទាំង៧ (សត្តតាល) ដែលកើតដំណាលនឹងប្រថពីបានទេនោះ ក៏សុគ្រីពមិនទុកចិត្តព្រះរាមក្នុងការបំពេញបំណងរបស់ខ្លួនដែរ។ តាមរយៈសកម្មភាពរបស់ព្រះរាមប្រើហនុមានឱ្យទៅស៊ើបដំណឹងពីនាងសីតា និងយកព័ត៌មានពីក្រុងលង្កាតែប៉ុណ្ណោះ ប៉ុន្តែដោយចង់ផ្ដាប់ថៅហ្វាយនាយពេក ធ្វើឱ្យហនុមានធ្វើការហួសបញ្ជា គឺហនុមានសម្លាប់យក្សដុតក្រុងលង្កា ដើម្បីឱ្យបេសកកម្មរបស់ខ្លួនកាន់តែលេចធ្លោឡើងនោះ គឺអ្នកនិពន្ធចេះលើកយកតថភាពដែលតែងតែកើតមាននៅក្នុងសង្គមមនុស្សទូទៅ យកមករំលចសាច់រឿងឱ្យកាន់តែមានទំនាស់ធំៗឡើង ជាពិសេសគឺបង្ហាញនូវចិត្តសាស្ត្ររបស់មនុស្សដែលកំពុងក្រពុលមុខក្នុងអំពើឃោរឃៅ សម្លាប់ហើយសម្លាប់ទៀតបំផ្លាញហើយបំផ្លាញទៀតហាក់បីដូចជាសប្បាយក្នុងទង្វើឃោរឃៅនោះជាខ្លាំង។ ក្រៅពីចំណុចទាំងនេះអ្នកនិពន្ធប្រើសិល្បវិធីផ្សេងៗទៀតដើម្បីឱ្យស្នាដៃរឿងរាមកេរ្តិ៍កាន់តែមានតម្លៃឡើងដូចជា៖

- **ការចេះយកតួអង្គអច្ឆិរយៈធ្វើឱ្យទៅជាលោកិយសច្ចៈវិញ** (ព្រះរាមដែលជាអវតារព្រះវិស្ណុ ប្រែទៅជាតួអង្គធម្មតា ចេះខឹង ចេះប្រចណ្ឌ ចេះទួញសោក ក្លែងបន្លំមហាជម្ពូកំសាកលបបាញ់គេពីក្រោយខ្នង ពោលគឺព្រះរាមប្រើឧបាយកលក្នុងការសម្លាប់ពាលី ដើម្បីអូសទាញសុគ្រីពនិងពលសេនាស្វាឱ្យចុះចូលនិងខ្លួនដោយព្រះរាមទទួលពិភេកដោយក្ដីសោមនស្ស និងឱ្យរង្វាន់ទៅពិភេក ហើយសន្យាលើករាជ្យសម្បត្តិក្រុងលង្កាឱ្យពិភេក ដូចគ្នានឹងការសន្យាលើករាជ្យសម្បត្តិឱ្យសុគ្រីព និង ព្រះរាមប្រើពិភេកឱ្យទៅបញ្ចុះបញ្ចូលកុម្ភការណ៌ ដោយសន្យាថា នឹងលើកកុម្ភការណ៌ឱ្យមានឋានៈស្មើនឹងព្រះលក្ស្មណ៍ជាដើម ដែលគេអាចនិយាយបានថាព្រះរាមមិនអាចធ្វើអ្វីបានទេ ប្រសិបបើព្រះរាមមិនពឹងពាក់កម្លាំងពួកពលសេនា ពួកទេវតា និងកម្លាំងធម្មជាតិទេនោះ)។ ម្យ៉ាងវិញទៀត ចាប់ពីខ្សែទី៧៥មក អ្នកនិពន្ធមានសិល្បវិធីបង្ហាញ មិន

ត្រឹមតែព្រះរាមជាអវតារប្រែមកជាមនុស្សធម្មតាទេ មានសកម្មភាពខ្លះព្រះរាមអន់ជាងមនុស្សទៅទៀត គឺសភាពឥតមេត្តា ឥតពិចារណាដែលទ្រង់ឱ្យព្រះលក្ខណ៍យកនាងសីតាទៅសម្លាប់ដែលមានគភ៌ ព្រះរាមជាស្ដេចចក្រពត្តិមិនព្រមឱ្យមានអ្នកដទៃខ្លាំងជាងខ្លួន(គ្រាន់តែឮសម្លេងសរបស់កុមារ ព្រះរាមឱ្យហោរាគន់គូមើល។ លុះដឹងការណ៍ហើយ ទ្រង់ក៏ប្រើមធ្យោបាយបង្ក្រាបទាំងពុំទាន់បានដឹងថាជាអ្នកណានៅឡើយ ដោយទ្រង់ភ័យខ្លាចមានអ្នកខ្លាំងពូកែជាងខ្លួន)។ ម្យ៉ាងវិញទៀតដើម្បីបង្ហាញឱ្យកាន់តែច្បាស់ពីភាពអន់របស់ព្រះរាម អ្នកនិពន្ធបានប្រើសិល្បវិធីបន្ទាបព្រះរាមតាមរយៈតួអង្គកុមាររាមលក្ស្មណ៍ និង ជប្បលក្ស្មណ៍ ដោយបង្ហាញនូវលក្ខណៈអង់អាចក្លាហានរបស់កុមារដែលហ៊ានចាប់ហនុមានចង ហើយចារលើមុខហនុមានថែមទៀត។ ម្យ៉ាងទៀតការប្រយុទ្ធតតាំងយ៉ាងស្វាហាប់ជាមួយព្រះភិរុត និងសុត្រុត និង ការជជែកវែកញែករកខុសត្រូវនូវទង្វើរបស់ខ្លួនដោយបង្ហាញពីសភាពឥតទោសរបស់កុមារ និង ការដែលកុមារហ៊ានបង្ហាញនូវគំនិតចក្រពត្តិយង់ឃ្នងរបស់ព្រះរាមក៏ដូចជាការបង្ហាញពីទង្វើអមនុស្សធម៌ដ៏សាហាវឃោរឃៅ ដែលព្រះរាមបញ្ជាឱ្យគេយកកុមារតូចទៅធ្វើទារុណកម្មដោយឥតត្រាប្រណីជាដើម។

- **ការរំលេចឡើងនូវយុទ្ធសាស្ត្រសង្គ្រាមតាមផ្លូវកាយនិងផ្លូវចិត្ត** ការបង្កត់ស្បៀង ការយកព័ត៌មានក្នុងពេលសង្គ្រាម ការបំបាក់ស្មារតីមានដូចជា ការបំភ័យសត្រូវឱ្យតក់ស្លុត ការបន្ទន់ចិត្តឱ្យខ្លបខ្លាច ការបំបែកទ័ពឱ្យបែកចេញពីមេកើយ ការលបចាំឆ្មក់ ការបញ្ចិះសីតាហោះទៅលើអាកាសដើម្បីបញ្ឈឺចិត្តព្រះរាម ការឱ្យអង្គទទៅគំរាមគំហែងរាពណ៍ដោយបំបាក់មុខដូចជាទៅវាយបំបាក់ទ្វារកំពែងការបំភ័យទ័ពយក្ស ការសម្លាប់ទ័ពយក្ស និង ការពុំព្រមអង្គុយទាបជាងរាពណ៍ ហើយលើកយករឿងអាស្រូវរបស់រាពណ៍មកលាតត្រដាង ក៏ដូចជាការទះរាពណ៍ឱ្យដួលជាដើម ជាពិសេសគឺអ្នកនិពន្ធបានបង្ហាញពីការប្រយុទ្ធរវាងព្រះរាមនិងក្រុងរាពណ៍មិនមែនដើម្បីទ្រទ្រង់លោកិយនោះទេ គឺប្រយុទ្ធដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ដែលធ្វើឱ្យរឿងរាមកេរ្តិ៍មានលក្ខណៈមនុស្សនិយម ព្រោះម្នាក់ៗសុទ្ធតែខំរកល្បិចយកឈ្នះគ្នារៀងៗខ្លួន ពោលគឺច្បាំងដោយសារមនុស្សម្នាក់ ស្លាប់ជីវិតមនុស្សអស់មួយនគរ ជាចម្បាំងរបស់មេសង្គ្រាម ឬអ្នកបង្កសង្គ្រាម គឺពុំមែនជាចម្បាំងរបស់ប្រជាជាតិ ឬប្រជាជនទេ។ ក្នុងចម្បាំងនេះរាស្ត្រ និងពលសេនាមិនមានតម្លៃទេ គឺចាំតែស្លាប់ដោយសារតណ្ហារបស់គេ ឬឱ្យគេសម្លាប់ចោលតែប៉ុណ្ណោះ ដែលចំណុចទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញពីសិល្បវិធីតែងរបស់អ្នកនិពន្ធ ក្នុងការបង្ហាញពីលក្ខណៈនៃលោកិយសច្ចៈដែលកេណ្ឌរេពលឱ្យច្បាំងគ្នា ឱ្យសម្លាប់គ្នាជារឿងធម្មតា ស្របទៅនឹងភាពពិតជាក់ស្ដែងទៅនឹងចម្បាំងរបស់មនុស្សដែលមាននៅលើភពផែនដី បើទុកណាជាមេសង្គ្រាមបង្កើតចម្បាំងដោយសារបញ្ហាផ្ទាល់ខ្លួនក៏ដោយ ក៏គេពុំមែនចេញច្បាំងឱ្យស្លាប់ខ្លួនតែម្នាក់ឯងនោះទេ គឺគេ

តែងតែកេណ្ឌ ឬបង្ខំមនុស្សឯទៀតមានដូចជារាស្រ្ត និងពលសេនាស្លូតត្រង់ ឱ្យទៅច្បាំងតតាំងក្នុងការការពារប្រយោជន៍របស់គេ និងស្លាប់ជំនួសគេតែប៉ុណ្ណោះ។

- តួអង្គទាំងឡាយនៃរឿងសុទ្ធតែមានចិត្តលោភៈ ទោសៈ និង មោហៈ។

- ការបង្កើតដំណើររឿងដោយយកការទៅលេងព្រៃធ្វើជាមូលដ្ឋាន និង ជាមូលហេតុនៃការបង្កើតនូវរឿងរ៉ាវសប្បាយរីករាយ ឬក៏កើតទុក្ខព្រួយភ័យខ្លាចជាដើម (បើសិនជាព្រះមិនទៅប្រពាតព្រៃក៏មិនកើតរឿងនាងសីតាគួររូបយក្សដែរ)។

- ការដែលអ្នកនិពន្ធចេះប្រើសិល្បវិធីឱ្យព្រះរាមទទួលកំហុស ហើយក៏នៅតែដាក់ទណ្ឌកម្មឱ្យព្រះរាមជួបប្រទះនូវភាពវិនាសព្រាត់ប្រាស់ មិនបានរស់នៅជួបជុំជាមួយអគ្គមហេសីដែលចំណុចនេះអ្នកនិពន្ធមានសិល្បវិធីខ្ពស់ក្នុងការតាក់តែងរឿង ដោយយករឿងរ៉ាវពិតក្នុងសង្គមមកលាតត្រដាងថា ទង្វើរបស់បុគ្គលដែលប្រព្រឹត្តខុស មិនមែនចេះលើកលែងទោសឱ្យជាដរាបនោះទេ ព្រោះថា អ្នកសាបព្រោះពូជអ្វី វានឹងដុះពូជនោះ ដូច្នេះបើអ្នកប្រព្រឹត្តខុស អ្នកត្រូវទទួលផលនៃកំហុសនោះ។

ដូច្នេះសរុបសេចក្តីមក តាមរយៈការបកស្រាយពីភាពប៉ិនប្រសប់ក្នុងការតាក់តែងរឿងរាមកេរ្តិ៍មកយើងឃើញថា រឿងរាមកេរ្តិ៍គឺជារឿងគំរូសម្រាប់ការតាក់តែងរឿងដទៃទៀត ព្រោះថាអ្នកនិពន្ធបានប្រើប្រាស់វិធីសាស្រ្តជាច្រើនក្នុងការបង្កើតរឿង ដំណើររឿងឱ្យមានលក្ខណៈជាប់គ្នារដឹក ហើយរូបារម្មណ៍ក៏គ្រប់គ្រាន់ ពាក្យពេចន៍ឃ្លាប្រយោគចំៗ សាមញ្ញ ងាយយល់ ងាយស្តាប់ រឿងទាំងមូលមានសោភ័ណភាព កម្សត់ កំប្លែង ល្អទាំងអត្ថន័យ អត្ថរូប និង អត្ថរស ដោយបង្ហាញនូវភាពពិត អស្ចារ្យ ល្មមនិងស្តាប់មិនហួសហេតុពេក។ ចំពោះបញ្ហាចោទ និងដំណោះស្រាយ អ្នកនិពន្ធបានបង្កើតនូវសន្ទេហវិធីក្នុងដំណើររឿងធ្វើឱ្យអ្នកអានចង់តាមដានទស្សនា ធ្វើឱ្យអ្នកអានរំភើបចិត្ត ញាប់ញ័រ ភ័យព្រួយជំនួសតួអង្គ និង នៅទីបញ្ចប់អ្នកនិពន្ធបានទុកឱ្យអ្នកអាននូវចម្ងល់មួយថា តើនាងសីតាព្រមជានានឹងព្រះរាមដែរឬទេ? ដូច្នេះទាំងអត្ថន័យនៃដំណើររឿង ទាំងវិធីសាស្រ្តតែងនិពន្ធ យើងឃើញថា រឿងរាមកេរ្តិ៍មានលក្ខណៈល្អ និងសមជាគំរូនៃការតាក់តែងរឿងដទៃ។

## ៣. តម្លៃលើផ្នែកអត្ថរស

### ក.តម្លៃនៃបច្ចេករស

ជាតម្លៃមួយផ្នែកនៃអត្ថរសដែលកវី អ្នកនិពន្ធ ប្រើដើម្បីជាវិធីពិសេសក្នុងការតែងនិពន្ធដើម្បីធ្វើឱ្យអត្ថបទមានសម្រស់សម្រាប់ផ្នែកឬនៃរឿងនីមួយៗ។ នៅក្នុងតម្លៃនៃបច្ចេករសរបស់រឿងរាមកេរ្តិ៍ មានដូចជា៖ កាព្យរស ប្រលោមរស និង នាដករស។

- **តម្លៃកាព្យរស**

គឺជាការតាក់តែងកាព្យរបស់កវីនិពន្ធទាំងពាក្យ ទាំងព្យញ្ជនៈឱ្យមានភាពពិរោះ ណែងណងអន្ទងរណ្ដំចិត្តដូចជា៖

*ដងនោះកូខ័នយាត្រា យល់ព្រះរាម ធិរាជនៅស្ថានអាស្រម ។*
*កូខ័នថ្មមបំពង់ទឹកឃ្មុំ នូវត្រីបន្ទះធំ បន្សំនូវសាច់ឆ្អើរឆ្អិន ។*
*ចូរថ្វាយព្រះបាទភូមិន្ទ នារាយណ៍រាមធិបតីន្ទ ស្ដេចគង់នៅបរមសាលា ។*

(វណ្ណឆាយាវង្ស ***រាមកេរ្តិ៍ទី១*** ទំព័រ៤៥)

*ល្អរថល្អទសយោធា ល្អព្រះរាមាទ្រង់សរ*
*ល្អបុត្រដូចព្រះចន្ទចរ ល្អព្រះភិរុតក្សត្រា ។*
*ល្អទាំងព្រះលក្ស្មណ៍គង់រថ ល្អព្រះសុត្រុតថ្លៃថ្លា*
*ហេតុជាពូជពង្សវតសូរា ប្រសើរលើសលើលោកផង ។*

(វណ្ណឆាយាវង្ស ***រាមកេរ្តិ៍ទី៧៩*** ទំព័រ២៥-២៦)

*ថ្កើងកេរ្តិ៍ថ្កើងយសថ្កើងអង្គ ថ្កើងពូជថ្កើងពង្សព្រឹទ្ធឆ្ងាយ*
*ហេតុជាតិបុណ្យព្រះនារាយណ៍ រឹងឫទ្ធិលើសលោកា ។*
*អស់ស្ដំសឹងតែជិហរថ បើកបរព្រាយព្រាត់លេលា ។*
*ដោយដងគីរីបុព្វតា ពុំបានសំរានឈប់ឈរ ។*

(វណ្ណឆាយាវង្ស ***រាមកេរ្តិ៍ទី៧៩*** ទំព័រ៥១)

- **តម្លៃប្រលោមរស**

ជាតម្លៃដែលកវី អ្នកនិពន្ធចេះរៀបរៀងតុបតែងដំណើររឿងរបស់ខ្លួនតាមរយៈការបង្កើតដំណើរនិងសកម្មភាពនៃតួអង្គឱ្យមានស្នេហា ការផ្សងព្រេងប្រកបដោយលក្ខណៈអណ្ដែតអណ្ដូង សោកសង្រេង សប្បាយ កម្សត់ ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ មានអារម្មណ៍រំភើប សប្បាយទុក្ខព្រួយជាមួយដំណើររឿងនិងតួអង្គនោះដែរ។

ឧទាហរណ៍៖ ភាពសង្រេងរបស់ព្រះភិរុតនៅពេលដឹងថាព្រះបាទទសរថជាព្រះជនកបានសុគត

*ព្រះភិរុតឮព្រះជនកក្ស័យ ញ័រអស់ហឫទ័យ រន្ធត់ចំប្រប់ប្រះប្រាណ ។*
*ដួលដេកសន្លប់លើស្ថាន ប្រាសាទភិមាន នាងកៃកេសីមាតា ។*
*ទាំងព្រះសុត្រុតអនុជា សន្លប់ថ្មាស់មរណា ព្រមព្រះរៀមរងទុក្ខទល់ ។*

................................... .......................... .........................................

*មានស្មារតីដោះឡើងគង់ គរគក់ទ្រូងទ្រង់ កន្ទ្បែងសែនសោកដ៏ពិលាប*

*ទឹកព្រះនេត្រាជ្រួតជ្រាប ហូរហួសជិតដាប ឱរះឱរាប្រះប្រាណ ។*

(វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្មែរទី២ ទំព័រ៣៧-៣៨)

**- តម្លៃនាដករស**

ជាតម្លៃដែលកវី អ្នកនិពន្ធ ចេះតុបតែងរៀបរៀងដំណើររឿងឱ្យមានឆាក ឈុត ដើម្បីសម្ដែងជាទស្សនីយភាព។ ឧទាហរណ៍ ឈុតចម្បាំង (ចម្បាំងរវាងព្រះរាម និងក្រុងរាពណ៍) និងឈុតសីតាមានកូន ត្រូវបានគេយកទៅសម្ដែងជារបាំព្រះរាជទ្រព្យ ។

**ខ. តម្លៃនៃវិសេសរស**

ជាសិល្ប៍រសដែលកើតមកអំពីការធ្វើឱ្យទេវភាពប្រែក្លាយទៅជាមនុស្សភាពវិញ ពោលគឺធ្វើពីអច្ឆរិយៈឱ្យទៅជាលោកិយសច្ចៈ។ ការលើកយកបញ្ហាមនុស្សមករៀបរាប់ និងដោះស្រាយ ដូចជាការ កាន់នូវពាក្យសច្ចៈ ការកើត ការស្លាប់ ការច្រណែនឈ្នានីសនៅក្នុងក្រុមគ្រួសារ និងញាតិមិត្ត។ ការបង្ហាញ នូវសង្គមមនុស្សដែលមានតួអង្គផ្សេងៗនៅក្នុងការរស់នៅ ការប្រកបរបររកស៊ី ប្រពៃណី ទំនៀមទម្លាប់ ជាដើម។ ការធ្វើឱ្យអាទិទេព(ព្រះរាម)ក្លាយទៅជាមនុស្សបន្តិចម្តងៗ(ព្រះរាមត្រូវចេះដោះស្រាយនូវបញ្ហាសង្គមមនុស្ស)។ នៅក្នុងតម្លៃនៃវិសេសរសមានតម្លៃផ្សេងៗទៀតជាច្រើនដូចជា៖

**- តម្លៃវិហាសរូបរស**

តម្លៃដែលអ្នកនិពន្ធបង្ហាញទៅលើលក្ខណៈអាក្រក់របស់ តួអង្គក្ដី សកម្មភាពក្ដីតាមរយៈការពិពណ៌នានេះធ្វើឱ្យមានភាពប្រត្យក្សអំពីរឿងរបស់តួអង្គដើម្បីបង្កើនសោភ័ណនៃរឿង។

ឧទាហរណ៍៖ រឿងរាមកេរ្តិ៍ តួអង្គកូខ័នមានរូបកាយអាក្រក់តែមានចិត្តល្អ។

**- តម្លៃនាដ្យរស**

ជាតម្លៃដែលកើតឡើងដោយនាដ្យវិធីផ្សេងៗដូចជា តើវិបត្តិរវាងព្រះរាម និងនាងកាកនាសូរតឹងតែងកម្រិតណា?

*ដងនោះព្រះរាមស្ដេចទ្រង់ កៅទ័ណ្ឌសរទ្រង់ កោះកាំតម្រង់យក្សា ។*
*ព្រះថ្លែងអសុរកាកនា សុរក្សយ័ជន្មា ជីវិតក៏មរណ៍ដួលទៅ ។*
*សរស័ក្តិហួលហួសបីសំដៅ មុជបាតាលទៅ ក៏សរព្រះអង្គដេញដល់ ។*
*ហើរសព្វភូមិភពដ៏មណ្ឌល សរព្រះដេញដល់ ក៏លុះនូវក្សយ័ជន្មា ។*

(វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្មែរទី១ ទំព័រ៤)

☞ វិបត្តិតឹងតែងរវាងរាមបរមសូរ ជាមួយព្រះបាទទសរថ និង ព្រះរាម

*ដងនោះរាមបរមសូរសា ហ័សបានមហិមា មហាគរុសីល្បសរ ។*
*ឮតេជតេជោជ័យខ្ពរ ដើមរាមបុត្របរ បពិត្រស្ដេចទសរថ ។*

*មោះហិមាចេស្តាដ៏ប្រាកដ មោះមកសន្ធត ព្រះនាមព្រះរាមជេស្ឋជ័យ ។*
*រាមបរមសូរយក្សនោះនៃ គិតក្នុងហឫទ័យ រំពៃរំពឹងស្តាយឈ្មោះ ។*
*ក្រេវក្រោធនូវពលាផ្សារខ្លាច ខាស់ខែងហិចហោះ នូវគ្រឿងអាវុធប៉ុនប៉ង ។*
*កាន់កាំផន្ទនឹងជើងផង មុតថ្លាផ្កាញផង នៅលេងតបះចេស្តា ។*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី១ ទំព័រ២២-២៣)

☞ វិបត្តិតឹងតែងរវាងព្រះរាម ព្រះលក្ស្មណ៍ ជាមួយនាងកៃកេសី

*ក្សិណព្ទដល់ព្រះរាម នូវព្រះលក្ស្ម ធិរាជដ៏ពីរចក្រី ។*
*ព្រះលក្ស្មណ៍ស្តេចក្រោធឡើងខ្នី ដាលដូចអគ្គី ក៏ទ្រង់ព្រះខ័នពេជ្រថ្លា ។*
*ប៉ងនូវពិឃាតជន្មា ព្រះវរមាតា គឺនាមនាងកៃកេសី ។*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី១ ទំព័រ៣៨)

ពេលរាពណ៍កំពុងលួងលោមនិងឆក់យកនាងសីតា តើព្រះរាមមកទាន់ឬមិនទាន់? ពេលរាពណ៍កំពុងច្បាំងជាមួយជតាយុ តើព្រះរាមមកទាន់ឬមិនទាន់? ពេលសុគ្រីពបិទរូងភ្នំ តើពាលីចេញរួច ឬពុំរួច? ពេលដែលពិភេកបញ្ចុះបញ្ចូលកុម្ភការណ៍ឱ្យមកនៅខាងព្រះរាម តើកុម្ភការណ៍ព្រមដែរឬទេ? ពេលត្រូវសររបស់យក្ស តើព្រះលក្ស្មណ៍ស្លាប់ឬរស់?

**- តម្លៃមហត្តរស**

គឺជាតម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ដោយកវី អ្នកនិពន្ធចេះរៀបរាប់ពីរូបរាង មហិទ្ធិរិទ្ធិ អំណាច របស់តួអង្គណាមួយ ធ្វើឱ្យមានលក្ខណៈសម្បើមអស្ចារ្យ ។

ឧទាហរណ៍ ៖ នៅក្នុងរឿងរាមកេរ្តិ៍ នៅពេលហនុមានទៅរកឱសថព្យាបាលព្រះព្រះលក្ស្មណ៍ ហនុមានពុំស្គាល់ដើមថ្នាំ ក៏លើកភ្នំទាំងមូលមកតែម្តង ។

**- តម្លៃកម្សត់រស**

ជាតម្លៃដែលកវី អ្នកនិពន្ធចេះបង្ហាញឱ្យឃើញនូវភាពកម្សត់ ការខ្វះភាពកក់ក្តៅ ការកំព្រា និរាសព្រាត់ប្រាស ជាដើម។ ឧទាហរណ៍៖ ពេលដែលក្រុងរាពណ៍លួចចាប់នាងសីតាពីព្រះរាមហោះទៅ នាងសីតាបានទួញសោកបោកប្រាណផ្តែផ្តាំអស់ព្រៃព្រឹក្សា បក្សាបក្សី មានដូចជាកុកជាដើម ៖

*នាងស្រែកយំភ្លាងថា ផ្តាំកុកបក្សា ឱ្យប្រាប់ព្រះរាមប្រតិពល ។*
*កុក្កើយទោះព្រះស្តែងយល់ ព្រះនរបតីដល់ នូវព្រះអនុជមកផ្គង ។*
*ចូរទូលពណ៌ដ៏មានអញផង ឥឡូវនេះហោង អសុរក៏លួចអញណា ។*
*អង្គអញចុះឯកអាត្មា ទល់ទុក្ខអនិច្ច មហាអនាថពេកសល់ ។*

(វឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្មែរទី៤ ទំព័រ១២)

ការព្រាត់ពីនាងសីតា ធ្វើឱ្យព្រះរាមទួញសោកតាមរកនាងគ្រប់ទីកន្លែង ហើយនឹកឃើញនូវអនុស្សាវរីយ៍ទាំងឡាយដែលបានសាងជាមួយនាង។

| | |
|---|---|
| *អុះឱសីតា* | *មេជាពុំងាបងម្ដេចឡើយប្រាស* |
| *ឱមេព្រលឹងមាស* | *ម្ដេចឡើយប្រាសពីបងទៅ ។* |
| *អុះឱមេដ៏ប្អូនស្រី* | *ប្រក្រតីសព្វថ្ងៃនៅ* |
| *ម្ដេចឡើយប្អូនពៅ* | *ប្រែប្រាស់ទៅឥឡូវណា។* |
| *អុះឱរូបមេប្រសើរក្រៃ* | *ស្រីទាំងត្រៃភពសួគ៌ា* |
| *ទាំងទ្វាទសទិសា* | *ពុំអាចបីស្មើបាន ។* |
| ............................. | ...................... |
| *ស្ដេចសាយសោកាណាស់* | *ស្មើរនឹងដាច់ខ្យល់សម្ដេចនរបតី* |
| *បម្រះព្រះអង្គប័ដោយប្រថពី* | *ននៀលប្រម្មៀលបីដោយព្រៃ។* |
| *ឈឺក្នុងព្រះអង្គរន្ធត់ពុំត្រង់ចំប្រប់* | *ព្រះហប្ញទ័យដូចៗ* |
| *នូវមរណ៍ដូចនូវក្សយ* | *ឈឺក្រៃសែនជ័ដ៏សោតសល់។* |
| *ស្ដេចសោយសោកា* | *មហិមាបីឥតដល់* |
| *បទជ្រាសទេពនិមល* | *ប្រសើរព្រះអង្គបាត់។* |

(វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្សែទ័៤ ទំព័រ២៤-២៧)

**- តម្លៃទារុណរស**

ជាតម្លៃដែលកវី អ្នកនិពន្ធចេះបង្ហាញឱ្យឃើញនូវការជិះជាន់ ការព្យាបាទ ការរំលោភបំពាន ការធ្វើទុក្ខទោស ការដាក់ទណ្ឌកម្មយ៉ាងឃោរឃៅរបស់តួអង្គខ្លាំងទៅលើតួអង្គទន់ខ្សោយដែលគ្មានសមត្ថភាព ឱ្យរងទុក្ខភ័យរហូតបាត់បង់ជីវិតក៏សឹងមាន។

ឧទាហរណ៍៖ កម្លាំងព្រះរាមមួយនគរ ធ្វើបាបកូនក្មេងតែម្នាក់

| | |
|---|---|
| *លុះដល់មកព្រះរាជស្ថាន* | *ឱ្យអស់ទាហានអាសា* |
| *ដាក់ក្ដីរតន៍រាជកុមារ* | *ច្រកច្រួលច្រវាក់ណែងណង។* |
| *សព្វគ្រប់ទាំងប្រាំប្រការ* | *ហើយអស់ភ្នាក់ងារនោះហោង* |
| *នាំទៅក្រវែលជាម្ដង* | *ធ្វើដូចព្រះរាជអាជ្ញា។* |
| *សឹងកាន់គ្រប់គ្រឿងសហ័ស្ស* | *ប្រទើសប្រទាល់លើគ្នា* |
| *វាយគង់អាក្រោសដោយថ្លា* | *បណ្ដើរជុំព្រះបូរី។* |

(វឌ្ឍនាយាវង្ស រាមកេរ្តិ៍ខ្សែទី៧៧ ទំព័រ២៨-២៩)

**- តម្លៃទស្សនីយរស**

ជាតម្លៃដែលកវី អ្នកនិពន្ធចេះរៀបរាប់អំពីទេសភាពធម្មជាតិ ព្រៃព្រឹក្សា មច្ឆា បក្សា បក្សី សកម្មភាព ឬ ទីតាំងណាមួយដោយបង្កើតជាសិល្បៈបរិយាកាសដែលជាលម្អមួយចំពោះចក្ខារម្មណ៍ និងសោតារម្មណ៍របស់អ្នកអាន អ្នកស្ដាប់ ពោលគឺការរៀបចំសកម្មភាពទាំងឡាយមួយចំនួនឱ្យហាក់ដូចជាយើងបានឃើញនូវសកម្មភាពទាំងនោះពិតៗ។

ឧទាហរណ៍៖ ការពិពណ៌នាពីតួអង្គមហាជម្ពូនិងប្រាសាទរបស់មហាជម្ពូ ហនុមានច្បាំងនឹងយក្ស ហនុមានដុតក្រុងលង្កា អង្គទស្វាយកន្ទុយអង្គុយស្មើរាពណ៍ អង្គទទះរាពណ៍ដួលឱ្យដួលជាដើម"

**- តម្លៃវីររស**

ជាតម្លៃដែលកវី អ្នកនិពន្ធចេះបង្ហាញឱ្យឃើញនូវសកម្មភាពអាកប្បកិរិយា ចិត្តអង់អាចក្លាហានមោះមុតរបស់តួអង្គក្នុងបុព្វហេតុអ្វីមួយ ឬការប្រយុទ្ធតទល់ជាមួយគូបដិបក្ខដើម្បីការពារអំពើល្អ។

ឧទាហរណ៍៖

- ភាពអង់អាចក្លាហានរបស់ពាលីដែលសុខចិត្តស្លាប់ខ្លួនជាជាងរស់នៅដោយសុំជីវិតពីគេ។

- កុម្ភការណ៍មិនព្រមចុះចូលជាមួយព្រះរាមតាមការលួងលោមរបស់ពិភេក គឺសុខចិត្តស្លាប់ខ្លួនប្រសើរជាងក្បត់ជាតិ ដូចក្នុងដំណើររឿង ***រាមកេរ្តិ៍ខ្មែរទី៩*** ទំព័រ១១-១២ បញ្ជាក់ថា៖

*សូវស្លាប់អញពុំទៅជា ខ្ញុំព្រះរាមា ធិរាជនោះឡើយឥឡូវ ។*
*ចូរបារទៅទូលដោយនូវ បណ្ដាំអញកូវ ធរេន្ទ្រធិរាជពីរអង្គ។*
*សូមស្ដេចរណ្ដាប់ពលផង ចេញកណ្ដាលរឿងរង្គ ប្រយុទ្ធដណ្ដើមចេស្ដា។*
*ត្រង់អញនឹងទៅជា ខ្ញុំព្រះរាមា នោះអញពុំគិតមូតហោង ។*

- រាមលក្សណ៍ ជប្បលក្សណ៍ ប៉ានប្រយុទ្ធតតាំងយ៉ាងស្វាហាប់ជាមួយព្រះភិរុតសុត្រុត កងទ័ព និង ហនុមាន ដោយជជែកតវ៉ារកខុសរកត្រូវ មិនមានការខ្លាចញញើតអ្វីឡើយ។

*" យើងដើរមកលេងដោយព្រៃ ឥតមានទោសអ្វីប៉ុនល្អង*
*បើក្សត្រនឹងចង់ច្បាំងផង យើងសោតពិតពុំរុញរា។*

*.......................................... ..........................................*

*ម្ដេចស្ដេចពុំពិចារណា វិលវេះប្រែជាពុំត្រូវ*
*លើកមកចោមចាប់យើងទៅ យើងខ្លាចណាស់ហើយក្សត្រា។*

(វណ្ណនាយាវង្ស រាមកេរ្តិ៍ខ្សែទី៧៧ ទំព័រ១៦)

**- តម្លៃវិសិដ្ឋរស**

ជាតម្លៃដែលកវី អ្នកនិពន្ធចេះបង្ហាញឱ្យឃើញនូវសកម្មភាពដ៏អស្ចារ្យរបស់តួអង្គក្នុងការបំពេញកិច្ចការអ្វីមួយដែលមនុស្សលោកធម្មតាពុំអាចធ្វើដូច។

ឧទាហរណ៍៖ ព្រះរាមបង្ហាញនូវព្រះទ័យដ៏ខ្ពង់ខ្ពស់ក្នុងការប្រកាន់ពាក្យសច្ចៈ និងការយាងចេញពីនគរទៅនៅព្រៃ ក៏ដូចជាការមិនព្រមត្រឡប់មកគ្រងរាជ្យតាមការស្នើសុំរបស់ព្រះភិរុត។ *“ បើបងសោយរាជ្យមុនបា បង់ព្រះសត្យា សម្តេចព្រះជនកនរបតី។*

*ចូរបារឹងគ្រងដ៏បូរ មណ្ឌលធានី នគរស្រីពួយុធ្យា។*

*ឱ្យគង់បន្ទូលប្តេជ្ញា ព្រះវរបិតា ដោយសត្យធម៌ព្រះបំណង។*

*បើចង់ប្រណិបត្តិបង បារិលទៅគ្រង មហានគរពួយុធ្យា។*

*បាយកសុពណ៌បាទា នេះទៅទុកនា សម្រាប់បន្ទុំស្ថានស្ថិត។*

*ហើយបារក្សាប្រណិបត្តិ ធ្វើដោយក្រមក្រិត្យ ចម្រើនមង្គលសួស្តី។*

*បងនៅធ្វើតបៈការវុឌ្ឍី ដោយក្រមព្រះមុនី លុះបួនដណ្តប់ឆ្នាំណា។*

*ហើយបងរឹងវិលលេលា ថ្កានស្រីពួយុធ្យា ពិភពបុរីត្រាណត្រើយ។”*

(វណ្ណនាយាវង្ស រាមកេរ្តិ៍ខ្សែទី២ ទំព័រ៨៣-៨៤)

**គ. តម្លៃសាមញ្ញរស**

ជាតម្លៃដែលកវី អ្នកនិពន្ធបានលើកយកសកម្មភាពឬបញ្ហាធម្មតា សាមញ្ញៗ ដែលស្មើៗគ្នាមកប្រើប្រាស់ក្នុងអត្ថបទរឿងរបស់ខ្លួន។

ឧទាហរណ៍៖

- ការធ្វើដំណើរកាត់ព្រៃរបស់ព្រះរាមតាមរកនាងសីតា
- ចរិករប៉ិលរប៉ូចរបស់ហនុមានដែលបេះស្លឹកស្វាយទម្លាក់លើរាម
- ការធ្វើដំណើររបស់ហនុមានទៅលង្កាបានជួបនឹងសិង្ហអសុរា
- ការធ្វើដំណើររបស់ហនុមានទៅលង្កាបានជួបនឹងសប្តតាលនាគ
- ការជជែកសួររកអ្នកណាអាចទៅក្រុងលង្កាបាន
- ការស្វែងរកនាងសីតារបស់ហនុមានព័ទ្ធាមួយទៅទ្វាមួយទៀត
- ការជជែកគ្នារវាងហនុមានជាមួយនាងសីតា

**ឃ. តម្លៃនៃសព្វរស**

ជាតម្លៃដែលកវី អ្នកនិពន្ធបានលើកយកមកប្រើប្រាស់ក្នុងអត្ថបទរឿងរបស់ខ្លួនដើម្បីបង្កើត សោភ័ណរស សច្ចរស តថរស អច្ឆរិយរស កុសលរស។

**- តម្លៃសោភ័ណរសៈ**

ជាតម្លៃដែលកវី អ្នកនិពន្ធមានភាពប៉ិនប្រសប់ក្នុងការលើកយកបញ្ហា ឬ ព្រឹត្តិការណ៍ណាមួយមកបង្ហាញតាមរយៈស្នាដៃរបស់ខ្លួន។ ចំពោះតម្លៃសោភ័ណរសនៃរឿងរាមកេរ្តិ៍នេះ វាគឺជាភាពសុក្រឹត ជាការដុះខាត់សម្រិតសម្រាំងនៅក្នុងផ្នែកអត្ថន័យ និងផ្នែកអត្ថរូប ដើម្បីឱ្យស្នាដៃកាន់តែល្អ មានទាំងភាពកម្សត់ ប៉ិនប្រសប់ រូបារម្មណ៍ពីរោះ សំវាទវិធី ឯកវាទវិធី សន្ទេហវិធី ពិពណ៌នាវិធី និង វិធីផ្សេងៗទៀតដែលមាននៅក្នុងរឿង។

**- តម្លៃសច្ចរសៈ**

ជាតម្លៃដែលកវី អ្នកនិពន្ធលើកយកបញ្ហាឬព្រឹត្តិការណ៍ណាមួយដែលជាសកម្មភាពពិតនៃបុគ្គលិកលក្ខណៈរបស់តួអង្គមកបង្ហាញតាមរយៈស្នាដៃរបស់ខ្លួន។ រីឯតម្លៃសច្ចរសដែលមាននៅក្នុងរឿងរាមកេរ្តិ៍គឺការលើកឡើងបង្ហាញពីលក្ខណៈពិតរបស់កុមារដែលភាពអង់អាច និងមិនអនុលោមតាម ឬ ចំណុះតាមបុគ្គលណាមួយ ព្រោះការមិនដែលស្គាល់ និងបង្ហាញថាក្មេងមានលក្ខណៈស្មោះត្រង់ណាស់ ពោលគឺក្មេងមិនមានល្បិចកិច្ចកល ឬវិធីបោកប្រាស់ភូតកុហកនោះទេ បើគេឃើញទិដ្ឋភាពបែបណាគឺគេថាដូច្នោះ តួយ៉ាងដូចជារាមលក្សណ៍ដែលបានិយាយតវ៉ាចំពោះព្រះភិរុត និង ព្រះសុត្រុត ដែលតាមចាប់ខ្លួនជាជនឥតមានកំហុសដោយបានសួរក្សត្រទាំងពីរថា ឯណាទៅជាសត្យរបស់ស្តេចនោះ។

*“កាលអើយកាលនោះ　　រាមលក្ខណ៍ឆ្លាស់ឆ្លើយរឹងច្រើន*
*ថាវើយទាំងពីរក្សត្រក្សាន្ត　　កុំស្តេចអាងអួតតេជតៃ។*
*ក្នុងសារយើងយល់អស្ចារ្យ　　ពុំត្រូវដោយធម៌ឡើយនៃ*
*លែងសេះរកចាប់ទោសភ័យ　　នេះឬនៅក្នុងសត្យា។*

*................................　　......................................*

*រីយើងនេះពុំគឺជា　　ខ្ញុំព្រះរាមឡើយនៃ*
*មើលងាយយល់យើងតូចក្រៃ　　គឺមោះដូចពេជ្រផ្កាញផ្កា។“*

(វិវឌ្ឍឆាយាវង្ស រាមកេរ្តិ៍ខ្សែទី៧៧ ទំព័រ១៧-១៨)

**- តម្លៃតថរស ៖**

ជាតម្លៃដែលកវី អ្នកនិពន្ធ លើកយកបញ្ហា ឬ ព្រឹត្តិការណ៍ណាមួយដែលមានពិតមកបង្ហាញតាមរយៈស្នាដៃរបស់ខ្លួន។

ឧទាហរណ៍៖ រឿងរ៉ាវរបស់សង្គមមនុស្ស ការឈ្លោះទាស់ទែងរឿងទ្រព្យសម្បត្តិ(នាងកៃកេសីជំទាស់មិនឱ្យព្រះរាមឡើងគ្រងរាជ្យ គឺដោយសារចិត្តលោភរបស់នាងដែលចង់ឱ្យបុត្ររបស់នាងបានឡើងសោយរាជ្យសម្បត្តិ)។

-ការភាន់ច្រឡំរវាងបងប្អូនពាលី និងសុគ្រីព(ពាលីយល់ថាសុគ្រីពចង់បានរាជ្យសម្បត្តិ)។

-ការសងសឹក (សុគ្រីពនាំព្រះរាមមកបាញ់សម្លាប់បងរបស់ខ្លួនដើម្បីសងសឹក ពិភេករត់ចូលខាងព្រះរាម និងប្រាប់ពីអាថ៌កំបាំងនិងចំណុចខ្សោយរបស់រាពណ៍ដើម្បីសងសឹកជាមួយរាពណ៍ជាបង)។

- សេចក្តីស្នេហា ការជួប ការប្រចណ្ឌ ការភ័យខ្លាចក្រែងស្នេហាពុំស្មោះត្រង់ ការនិរាស ព្រាត់ប្រាស់ គឺជារឿងរ៉ាវដែលមានពិតនៅក្នុងសង្គមមនុស្ស។

-ធម្មជាតិរបស់មនុស្ស ចម្បាំងចង់តែឈ្នះ ចម្បាំងនាំឱ្យប្រជាជនរងទុក្ខ និងការបំផ្លិចបំផ្លាញ។

- ការគិតពីប្រយោជន៍ផ្ទាល់ខ្លួន ពោល គឺអាទិទេពផ្លាញ់សភាវអាក្រក់ ប្រែទៅជារឿងផ្ទាល់ខ្លួនគឺរឿងស្នេហា។

-ការភាន់ច្រឡំ និងការឱ្យតម្លៃទៅលើទ្រព្យសម្បត្តិធ្វើឱ្យមានវិបត្តិទំនាស់រវាងបងប្អូនឯង។

**- តម្លៃអច្ឆរិយរស ៖**

ជាតម្លៃដែលកវី អ្នកនិពន្ធលើកយកតួអង្គអរូបីមានដូចជា ៖ ទេវៈយក្ស ខ្មោច ព្រាយ បិសាច សត្វ ឬ សកម្មភាពអស្ចារ្យផ្សេងៗ ដែលហួសពីសមត្ថភាពរបស់មនុស្ស ហួសពីការពិតមកបញ្ចូលក្នុងស្នាដៃរបស់ខ្លួន ដើម្បីធ្វើឱ្យដំណើររឿងមានលក្ខណៈអស្ចារ្យមានការហោះហើរ ដើរលើអាកាស ជ្រែកទឹក ជ្រែកដី បែងភាគ កាឡាខ្លួនជាដើម។

ឧទាហរណ៍៖ ព្រះរាមផ្លាញ់កាកនាសូរ ព្រះរាមផ្លាញ់រាមបរមសូរ ព្រះរាមលើកធ្នូសររួចហើយបាញ់កក្រើករំពើកសព្វឋាន ព្រះរាមអាចកែប្រែធម្មជាតិ ការកាឡាខ្លួនរបស់នាងសូបនខា ព្រះរាមអាចរម្លាយសពទូភី និងអាចថ្លែងសរបំបាក់ដើមសប្តកាលដ៏ធំដែលមានអាយុកាលយ៉ាងយូរង្វែងមកហើយ។ ការហោះនាំយកគ្រែរបស់មហាជម្ពូ និងការហោះហើររកមហាជម្ពូរបស់ខុននិល និងខុននល( គ្រាន់តែមហាជម្ពូនឹកដើមតែបន្តិច ក៏ស្រាប់តែជ្រែកដីមកនៅជិតមហាជម្ពូតែម្តង) ឥន្ទ្រជិតថ្លែងសរកើតជានាគរុំព័ទ្ធទ័ពព្រះរាម។ កុម្ភការណ៍គ្រវីមោងសក្តិត្រូវព្រះលក្សណ៍ មោងសក្តិនោះបានដុះចាក់ឫសដល់បាតាល និងដុះស្លឹកដល់អាកាស។ ព្រះលក្សណ៍លើកព្រះខ័នកាត់កសីតា ព្រះខ័នក្លាយទៅជាកម្រងផ្កាបំពាក់ឱ្យសីតា ហើយកម្រងផ្កាក្លាយជាព្រះខ័នវិញ។ រាមលក្សណ៍ ជប្បលក្សណ៍ ថ្លែងសរបំបាក់ដើមរាំងកល្ប កក្រើកសព្វស្ថាន។ អន្តរាគមរបស់ព្រះឥន្ទ្រ និងនាងរម្ភា គឺពេលនាងទេពរម្ភាចុះមកជួយរាមលក្សណ៍ ជប្បលក្សណ៍ គ្រាន់តែរាមលក្សណ៍ទទួលយកទឹកពីនាងទៅសោយ ស្រាប់តែចិញ្ចៀនមកបំពាក់នឹងដៃ ហើយ

ទ្រូងដែកក៏របើកចេញអស់ និង សរព្រះរាមក្លាយជាភាជ និងអាហារ រីឯសរកុមារក្លាយជាកម្រង ផ្កា ជាដើម។

*"កាលអើយកាលនោះ　　រាមលក្សណ៍រីឯឫទ្ធីក្រៃ*
*ស្ដេចយល់អស្ចារ្យថ្មោះនៃ　　មានព្រះបន្ទូលត្រាស់ថា។*
*ថាហៃជប្បលក្សណ៍ភ្ញាប្រិយ៍　　យល់ហើយឬអ្វីប្អូនភ្ញា*
*សរយើងរីងឫទ្ធិចេស្ដា　　ថ្លែងទៅឱ្យផ្លាញជីវិត។*
*ហេតុម្ដេចសរក្លាយប្រែជា　　លាជភ្ញីមាលារីងថ្វាត់*
*រីងព្រះមហាក្សត្រ　　ថ្លែងមកកាន់យើងនេះណា។*
*កើតជាភាជនអាហារ　　ជាឆត្រឆាយាថ្លៃថ្លា*
*ហេតុបុណ្យបង់នូវស្ងួនភ្ញា　　មកយើងបរិភាគលេងហាង។"*

(វឌ្ឍឆាយាវង្ស ***រាមកេរ្តិ៍ខ្មែរទី៧៨*** ទំព័រ២១-២២)

**- តម្លៃកុសសរស ៖**

ជាតម្លៃដែលកវី អ្នកនិពន្ធលើកយកការអប់រំទូន្មានប្រៀនប្រដៅ មកបង្ហាញតាមរយៈសកម្មភាពតួអង្គ ឬដំណើររឿង។

ឧទាហរណ៍៖　ពេលនាងសីតាឃើញកូនទាំងពីរព្រមទៅរស់នៅជាមួយព្រះរាមជាបិតា នាងអប់រំ ទូន្មានកូនដោយផ្ដាំ ដូចក្នុង ***រាមកេរ្តិ៍ខ្មែរទី៧៩*** ទំព័រ១៣-១៥ ថា៖

*កាលនោះក្សត្រីស្រីរតន៍　　នាងយល់រាជបុត្រសង្ការ*
*ព្រមទៅនឹងព្រះភូបាល　　នាងឱនឱបបុត្រវរវង្ស។*
*ហើយមានព្រះសវនី　　ផ្ដាំបុត្រពិសីពីរពង្ស*
*កូនអើយទៅហើយផ្ចិតផ្ចង់　　បម្រើព្រះបាទក្សត្រថ្លៃ។*
*ហើយគាល់កុំឱ្យមានដាច់　　រាជការកុំភ្លេចឡើយនៃ*
*មួយព្រះអយ្យិកាថ្លាថ្លៃ　　ស្ដេចជាកំពូលធានី។*
*ចូរបាឧស្សាហ៍បណិបត្តិ　　បំរើមហាក្សត្រទាំងពីរ*
*កុំឱ្យសៅហ្មងព្រះទ័យ　　អាក់អន់ព្រះរាជចិន្ដា។*

*..................................　　..................................*

*មួយចូរកូនស្ងួនភ្ញាប្រិយ៍　　មានចិត្តប្រណីរាស្ត្រផង*
*ឱ្យដឹងទុក្ខវាជាម្ដង　　ទើបបានក្សាន្តសប្បាយ។*
*បាជាឆត្រកែវអម្ពប់　　ទាំងអស់ត្រៃភពទាំងឡាយ*
*ការអស់សត្រូវសម្ចាយ　　កុំឱ្យមកបៀតបៀនបាន។*

# សេចក្ដីសន្និដ្ឋាន

តាមរយៈខ្លឹមសារដែលបានបង្ហាញខាងលើយើងឃើញថា រឿងរាមកេរ្តិ៍ពិតជាមានតម្លៃយ៉ាងធំធេងទៅក្នុងសង្គមខ្មែរតាមរយៈតម្លៃលើផ្នែកអត្ថន័យ តម្លៃអត្ថរូប និងតម្លៃអត្ថរស។ រឿងរាមកេរ្តិ៍ គឺជារឿងមួយដែលបានឆ្លុះបញ្ចាំងវែកញែកពីតម្លៃរបស់មនុស្សនៅក្នុងជីវភាពរស់នៅដែលតែងតែជួបប្រទះនូវវិបត្តិ ឬហេតុការណ៍ណាមួយដោយចៀសមិនផុត ហើយនៅពេលដែលជួបនូវបញ្ហាទាំងនោះ តើបុគ្គលម្នាក់ៗគួររកវិធីដោះស្រាយយ៉ាងណាដើម្បីធ្វើឱ្យដំណោះស្រាយរបស់យើងមិនប៉ះពាល់ដល់អ្នកដទៃ តួយ៉ាងដូចជាការបង្ហាញពីដំណោះស្រាយបញ្ហារាជបល្ល័ង្ករបស់ព្រះរាម ដែលទ្រង់សុខចិត្តចាកចេញពីនគរក្នុងគោលបំណងបំពេញពាក្យសត្យជូនព្រះបិតាជាដើម ដែលតាយរយៈដំណោះស្រាយនេះ អ្នកនិពន្ធបានបង្ហាញពីសកម្មភាពនៃការដោះស្រាយទៅតាមកម្រិតដោយបង្កើតនូវភាពសោកសង្វេគនៃការព្រាត់ប្រាស់ ការជួបប្រទះនូវឧបសគ្គនានា លក្ខណៈរបស់បុគ្គល វិធីសាស្ត្រកំចាត់សត្រូវ និងយុទ្ធសាស្ត្រគ្រប់គ្រងមនុស្សជាដើម។

ក្រៅពីការឆ្លុះបញ្ចាំងនូវតម្លៃអត្ថន័យ អ្នកនិពន្ធក៏បានបង្ហាញពីតម្លៃអត្ថរូប ដែលមាននៅក្នុងរឿង ដូចជាការប្រើវិធីសាស្ត្រក្នុងការបង្កើតផ្ទៃរឿង ក៏ដូចជាដំណើររឿងឱ្យមានលក្ខណៈជាប់គ្នារដឹក មានរូបារម្មណ៍ និងមានសិល្បវិធីគ្រប់គ្រាន់ ជាពិសេសការប្រើពាក្យពេចន៍ល្អ ពីរោះ មានទាំងភាសាសាមញ្ញងាយយល់ ងាយស្ដាប់ ឃ្លាប្រយោគខ្លីៗ ចំបញ្ហា មានឆាក មានឈុត និងមានលក្ខណៈឯកភាពតាមដំណើររឿង។ រឿងរាមកេរ្តិ៍បានក្លាយជាជង្រុកពាក្យពេជន៍នៃភាសា និងវោហារសាស្ត្រខ្មែរដែលកវី អ្នកនិពន្ធ សិល្បករ នាដករខ្មែរយកទៅធ្វើពិពិធកម្មស្នាដៃដ៏ច្រើនបែប ច្រើនយ៉ាង។

រីឯតម្លៃអត្ថរសវិញ គឺអ្នកនិពន្ធបានរំលេចពីតម្លៃសោភណភាព មានកម្សត់ មានកំប្លែង មានពិពណ៌នាដោយបង្ហាញនូវសភាពពិត និងអស្ចារ្យ ល្មមនឹងទទួលយកបាន ពោលគឺមិនហួសហេតុពេកនោះឡើយ។ ដែលតម្លៃទាំងអស់នេះ យើងអាចចាត់ទុកថា រឿងរាមកេរ្តិ៍គឺជាសម្បត្តិបេតិកភ័ណ្ឌអរូបីរបស់ជាតិខ្មែរដែលមិនអាចកាត់ថ្លៃបាន។

# ឯកសារពិគ្រោះ

-ពុទ្ធសាសនបណ្ឌិត្យ, វចនានុក្រមខ្មែរ, ១៩៦៧។

-ពុទ្ធសាសនបណ្ឌិត្យ, រាមកេរ្តិ៍, ខ្សែ១ ដល់១០ និង៧៥ ដល់៨០, បោះពុម្ពលើកទី៣,១៩៥៩។

-ហង់ជួន ណារ៉ុន, វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរ, គ្រឹះស្ថានស៊ីប៉ា, ២០១៩។

-ឃីង ហុកឌី, ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ, បណ្ណាគារអង្គរ, ២០០៣។

-ឃីង ហុកឌី, សាស្ត្រារាមកេរ្តិ៍កាលវែយរាពណ៍សន្ទំយកព្រះរាមបាន, បណ្ណាគារអង្គរ, ២០០៤។

-ធន់ ហ៊ិន, រឿងរាមាយណៈ, ភាគ ១, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ២០០៥។

-ប្រាង់ស័រ ប៊ីហ្សូត៍, រឿងរាមកេរ្តិ៍នៃតាចក់, ភ្នំពេញ, ១៩៧៣, (ចម្លងបណ្ណាគារត្រៃរតន៍, ២០០២)។

-លាង ហាប់អាន, រឿងរាមកេរ្តិ៍, រាមកេរ្តិ៍បែបខ្មែរ, រាមាយណៈបែបឥណ្ឌា។

-លាង ហាប់អាន, សិក្សាអត្ថបទរឿងរាមកេរ្តិ៍, ខ្សែ៧៥ដល់៨០, ១៩៦៧។

-សរ សារុន, សង្ខេបរឿងរាមកេរ្តិ៍, (គ្មានកាលបរិច្ឆេទ)។

-សាគូ សាមុត, រឿងរាមកេរ្តិ៍, បណ្ណាគារអង្គរ, ២០០៧។

-អាំង ជូលាន, រឿងរាមកេរ្តិ៍ពោលដោយតាសយ, ២០០០។